សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# បទល្មើសរំលោភសេពសន្ថវៈ និងបទល្មើសបំពានផ្លូវភេទប្រហាក់ប្រហែល

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហួ ម៉េងហ៊ត់**

**ហែម លឹមឆាយ**

សាស្ត្រាចារ្យណែនាំ

លោក **មីន សំអុល**

បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ២២

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហែម លីមឆាយ** និងឈ្មោះ **ហួ ម៉េងហ៊ត់** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា២០២១-២០២២។

សូមសម្ដែង និងគារវកិច្ចគោរពដឹងគុណដ៏ខ្ពង់ខ្ពស់ជាអនេកប្បការជូនចំពោះ៖

- លោកឪពុក៖ **ហែម ខុន** និងអ្នកម្ដាយ ៖ **លី ស៊ីវឡាង**
- លោកឪពុក៖ **ម៉េង ហ៊ាង** និងអ្នកម្ដាយ ៖ **តាន់ គឹមគន់**

ដែលបានផ្ដល់កំណើត និងបានខិតខំពុះពារឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងបានផ្គត់ផ្គង់កូនគ្រប់សព្វបែបយ៉ាងទាំងសម្ភារសម្រាប់ប្រើប្រាស់រៀនសូត្រ និងស្មារតីដល់កូន ជាពិសេសលោកទាំងទ្វេបានខិតខំជំរុញឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រ។ គុណូបការៈដែលលោកទាំងទ្វេបានផ្ដល់ និងលះបង់នេះ វាជាវត្ថុដ៏មានតម្លៃបំផុតដែលមិនអាចកាត់ថ្លៃបាន និងមិនអាចរកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ។ ហើយគ្មានថ្ងៃណាដែលកូនបានតបស្នងសងគុណលោកវិញអស់ឡើយ។

យើងខ្ញុំសូមសម្ដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះ៖

ឯកឧត្តមសាកលវិទ្យាធិការ និងព្រមទាំង សាកលវិទ្យាធិការរង ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានជួយតម្រង់ទិសដៅក្នុងការសិក្សារៀនសូត្ររហូតដល់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ

ជាពិសេស លោកសាស្ត្រាចារ្យ **មីន សំអុល** ដែលបានដឹកនាំ ចង្អុលបង្ហាញ និងសម្របសម្រួលដំបូន្មាន និងអនុសាសន៍ល្អៗ ព្រមទាំងពន្យល់ពីវិធីសាស្ត្រក្នុងការស្រាវជ្រាវឯកសារ និងទិន្នន័យនានាដែលពាក់ព័ន្ធនឹងប្រធានបទខាងលើនេះ។

ជាចុងបញ្ចប់ត្រឹមខ្ញុំសូមបួងសួង ដល់វត្ថុសាកសិទ្ធទាំងអស់ក្នុងលោកសូមជួយតាមថែរក្សាលោកទាំងអស់ឱ្យជួបប្រទះតែសេចក្ដីសុខសុខភាពល្អអាយុយឺនយូរដើម្បីបន្តដឹកនាំ និងផ្ដល់ចំណេះដឹងដល់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយទៀត។

យើងខ្ញុំទាំងពីរនាក់ គឺជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី ២០ ដែលបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចចាប់តាំងពីឆ្នាំ ២០១៨ រហូតដល់ឆ្នាំ ២០២២។ បន្ទាប់ពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនពីសាស្ត្រាចារ្យទាំងឡាយ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ដល់យើងខ្ញុំ។ ហេតុដូច្នេះហើយ ដើម្បីធ្វើការវាយតម្លៃ និងវាស់ស្ទង់ទៅលើចំណេះដឹងរបស់ពួកយើងខ្ញុំដែលបានសិក្សាកន្លងមកក្នុងរយៈពេល ៤ឆ្នាំមកនេះ យើងខ្ញុំសូមលើកយកនូវប្រធានបទមួយដែលមានចំណងជើងថា " **បទរំលោភសេពសន្ថវៈ** " មកធ្វើការសិក្សាស្រាវជ្រាវដើម្បីធ្វើជាសារណាក្នុងការបញ្ចប់ការសិក្សា។

មូលហេតុដែលយើងខ្ញុំសម្រេចចិត្ត លើកយកប្រធានបទនេះមកសរសេរសារណា គឺដើម្បី ឱ្យមិត្តនិស្សិត និងមិត្តអ្នកអានដែលមានបំណងធ្វើការស្វែងយល់អំពីបទល្មើសព្ទមួយនេះ ដែលមានការចាប់អារម្មណ៍ក្នុងមួយរយៈពេលប៉ុន្មានឆ្នាំក្រោយមកនេះ។ តាមរយៈស្នាដៃនៃសារណារបស់យើងខ្ញុំនេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា អត្ថបទសារណាមួយនេះនឹងចូលរួមជាពិសេស ក្នុងការផ្សព្វផ្សាយ និងជាជំនួយដល់ស្មារតីផ្នែកច្បាប់ និងសម្រាប់បុគ្គលទូទៅមិនចំពោះតែអ្នកច្បាប់ ជាពិសេសសម្រាប់ សិស្សនិស្សិតណា ចង់ដឹង និងចង់សិក្សាស្វែងយល់អំពីបទល្មើសដែលកើតឡើងក្នុងរឿងព្រហ្មទណ្ឌ។

ដោយសារតែពេលវេលាក្នុងការសិក្សាស្រាវជ្រាវ និងសរសេរសារណាបញ្ចប់ការសិក្សាមានរយៈពេលខ្លី ហើយម្យ៉ាងវិញទៀត ដោយសារតែចំណេះដឹងពួកយើងខ្ញុំនូវមានកម្រិត យើងខ្ញុំជឿជាក់ថា កំហុសដែលកើតមានឡើងដោយអចេតនាមួយចំនួន ដែលក្នុងនោះមានដូចជា កំហុសអក្ខរាវិរុទ្ធ ខ្លឹមសារអត្ថន័យ និងភាពខ្វះចន្លោះមិនគ្រប់ជ្រុងជ្រោយតាមខ្លឹមសារច្បាប់នឹងកើតមានក្នុងសារណានេះ ជាក់ជាពុំខាន។ យើងខ្ញុំរីករាយនឹងទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនា ដើម្បីកែលំអនូវកំហុសឆ្គងពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ ក៏ដូចជា មិត្តនិស្សិតទាំងឡាយ ដើម្បីបំពេញនូវរាល់កំហុសឆ្គង និងចំណុចខ្វះខាតទាំងឡាយដោយក្តីសោមនស្សរីករាយដោយមេត្រីភាពព្រមទាំង សូមអរគុណ និងអរព្រះគុណ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................ ១

**ជំពូកទី១**

**បទល្មើសរំលោភសេពសន្ថវៈ**

១.១ និយមន័យៈ........................................................................................ ៣

១.១.១. តាមវចនានុក្រមខ្មែរៈ................................................................................ ៣

១.១.២. តាមវាក្យសព្ទគតិយុត្តៈ ................................................................................ .៣

១.២. ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ :................................................................ ៥

១.២.១. ធាតុនីត្យានុកូល ឬ ធាតុច្បាប់ :................................................................ ៥

១.២.២. ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ :................................................................ ៦

១.២.២.១. សម្ភារៈ និងសកម្មភាពប្រព្រឹត្តបទល្មើស :................................................ ៦

ក.ការបញ្ចូលអង្គជាត :................................................................................ ៦

ខ.ការបញ្ចូលឧបករណ៍ :................................................................................ ៨

គ.ប្រព្រឹត្តទៅលើអ្នកដទៃ :................................................................................ ៨

១.២.២.២. អវត្តមាននៃការព្រមព្រៀង :........................................................................ ១០

ក. សញ្ញាណទូទៅនៃការព្រមព្រៀង :................................................................ ១០

ខ. សច្ចធារណ៍នៃការព្រមព្រៀងក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ :........................................ ១១

គ. នីតិភាពនៃការរួមភេទ :................................................................................ ១២

ឃ. ការប្រើអំពើហិង្សា :................................................................................ ១៣

ង. ការបង្ខិតបង្ខំ :................................................................................ ១៤

ច. ការគំរាមកំហែង :................................................................................ ១៤

ឆ. ការឆ្មក់ឱកាស :................................................................................ ១៥

១.២.៣. ធាតុអត្តនោម័ត ឬ ធាតុផ្លូវចិត្ត :................................................................ ១៥

១.២.៣.១ កំហុសក្នុងបទរំលោភសេពសន្ថវៈ :................................................................ ១៦

ក.ចេតនាទូទៅ :................................................................................ ១៦

ខ.ចេតនាទុច្ចរិតពិសេស :................................................................................ ១៧

ខ.១. ចេតនាទុច្ចរិតពិសេស ជាមូលហេតុនៃការប្រព្រឹត្តបទល្មើស :.................................. ១៧
ខ.២.ចេតនាទុច្ចរិតពិសេសសម្តៅចង់បានលទ្ធផលជាក់លាក់ណាមួយ :.......................... ១៧
១.២.៣.២. គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ :............................................ ១៨
១.២.៣.៣ កម្មវត្ថុនៃបទល្មើសរំលោភសេពសន្ថវៈ :.......................................................... ១៨
ក. តាមទស្សនៈទី១ :..................................................................................... ១៨
ខ. តាមទស្សនៈទី២ :..................................................................................... ១៨
១.៣. ទោស និងស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវៈ :.......................................................... ១៩
១.៣.១. ទោស.................................................................................................. ១៩
១.៣.២. ស្ថានទម្ងន់ទោសៈ.................................................................................... ១៩
១.៣.២.១. ស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវៈ ...................................................... ១៩
ក. ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងជនល្មើស .................... ១៩
១.៣.២.២. ស្ថានទម្ងន់ទោសដោយឡែកចំពោះអំពើរំលោភសម្លាប់.........................................២២
ក. ធាតុនីត្យានុកូល......................................................................................២២
ខ. ធាតុសត្យានុម័ត......................................................................................២២
គ. ធាតុអត្តនោម័ត .....................................................................................២២
១.៤. អំពើប៉ុនប៉ងប្រព្រឹត្តបទរំលោភសេពសន្ថវៈ :.......................................................................២៣

## ជំពូកទី២

## បទល្មើសបំពានផ្លូវភេទផ្សេងទៀត

២.១. អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ: ..........................................................២៥
២.២. បទប្រទូស្តកេរខ្មាសៈ......................................................................................................២៧
២.២.១.និយមន័យនៃបទប្រទូសកេរខ្មាស.................................................................................. ២៧
២.២.២.ធាតុផ្សំបទល្មើស .......................................................................................................២៧
២.២.២.១. ធាតុនីត្យានុកូល ......................................................................................២៧
២.២.២.២. ធាតុសត្យានុម័ត .....................................................................................២៨
២.២.២.៣. ធាតុអត្តនោម័ត .....................................................................................២៨
២.៣. បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង១៥ឆ្នាំៈ .....................................................**២៨**
២.៤. បទបង្ហាញកេរភេទៈ ...........................................................................................................៣០

២.៤.១. ធាតុផ្សំបទល្មើស ..................................................................................... ៣១
២.៤.១.១. ធាតុនីត្យានុកូល..................................................................................... ៣១
២.៤.១.២. ធាតុសត្យានុម័ត..................................................................................... ៣១
២.៤.១.៣. ធាតុអត្តនោម័ត..................................................................................... ៣១
២.៥. បទរុកកួនខាងផ្លូវភេទៈ..................................................................................... ៣១
២.៥.១. ធាតុផ្សំបទល្មើស ..................................................................................... ៣២
២.៥.១.១. ធាតុនីត្យានុកូល..................................................................................... ៣២
២.៥.១.២. ធាតុសត្យានុម័ត..................................................................................... ៣២
២.៥.១.៣. ធាតុអត្តនោម័ត..................................................................................... ៣២
២.៦ បទរួមភេទជាមួយអនីតិជន ដោយបុព្វញាតិ..................................................................................... ៣២
២.៧ បទរួមភេទរវាងញាតិលោហិត ឬ ញាតិពន្ធ ..................................................................................... ៣៣
២.៨ អំពើរំលោភសេពសន្ថវៈលើសាកសព..................................................................................... ..៣៥
**សេចក្តីសន្និដ្ឋាន** ..................................................................................... ៣៦
**អនុសាសន៍**..................................................................................... ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. សំនាំបញ្ហា

អំពើរំលោភសេពសន្ថវៈគឺជាអំពើទុច្ចរិតមួយ ដែលប៉ះពាល់ដល់បូរណភាពនៃរាងកាយផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ដែលជាជនរងគ្រោះដោយវានឹងធ្វើ ឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរដល់កេរ្តិ៍ឈ្មោះ និងកិត្តិយសរបស់ជនរងគ្រោះហើយទង្វើនេះ ត្រូវបានប្រទេសភាគច្រើនដែលជាប្រទេសកាន់របបសេរីនិយមដូចប្រទេសយើងជាដើមបានចាត់ទុកអំពើនេះថាមានចរិតលក្ខណៈគួរ ឱ្យស្អប់ខ្ពើមយ៉ាងឃោរឃៅព្រៃផ្សៃ ព្រោះការរំលោភបំពានលើសិទ្ធអ្នកដទៃត្រូវបានការពារដោយរបបនេះយ៉ាងយកចិត្តទុកដាក់ចំពោះសេរីភាពក៏ ដូចជាស្វ័យភាពនៃសិទ្ធជាពលរដ្ឋ។ ដោយពិនិត្យទៅលើទិដ្ឋភាពនៃសិទ្ធិមនុស្សក្នុងមាត្រា៥ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សបានកំណត់ពីបូរណភាពបុគ្គល គឺគ្មានជនណាម្នាក់ត្រូវទទួលទារុណកម្ម **ឬ** ទណ្ឌកម្ម **ឬ** ប្រព្រឹត្តិកម្មកាចសាហាវឥតមនុស្សធម៌ **ឬ** ថោកទាបបានឡើយ។ បញ្ហានេះក៏ត្រូវបានលើកដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៣៨កថាខណ្ឌទី១ដោយសេចក្តីថា ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពាន លើរូបរាងកាយ បុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិត កិត្តិយស **និង**សេចក្តីថ្លៃថ្នូររបស់ពលរដ្ឋ។ មានន័យថា បុគ្គលគ្រប់ៗរូបត្រូវបានរដ្ឋធម្មនុញ្ញកម្ពុជាធ្វើការរ៉ាប់រងនឹងការពារមិន ឱ្យកើតមាននូវការរំលោភបំពាន គ្រប់រូបភាពទៅលើរូបរាងកាយរបស់បុគ្គលណាមួយឡើយ។ លើសពីនេះទៀត ច្បាប់ក៏ការពារដល់អាយុជីវិត កិត្តិយស កេរ្តិ៍ឈ្មោះ ព្រមទាំងសេចក្តីថ្លៃថ្នូររបស់ពលរដ្ឋផងដែរ។ ការការពារនេះ ធ្វើឱ្យប្រជាពលរដ្ឋ មានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន ក្នុងការដើរហើរទៅខាងក្រៅ ដោយមានទំនុកចិត្ត សុវត្ថិភាព និងមិនមានការព្រួយបារម្ភព្រមទាំងភាពភ័យខ្លាច។

## ២. ចំណោទបញ្ហា

**តើបទរំលោភសេពសន្ថវៈ ត្រូវបានកំណត់ និងផ្តន្ទាទោសយ៉ាងណា?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបនឹងចំណោទបញ្ហាខាងលើនេះ ការស្រាវជ្រាវបានចាប់ផ្តើមឡើងក្រោមគោលបំណងសិក្សាពីបទល្មើស ដែលកើតចេញពី បទរំលោភសេពសន្ថវៈ ធាតុផ្សំនៃបទល្មើស ការផ្តន្ទាទោស ក៏ដូចជាបទល្មើសប្រហាក់ប្រហែលនានា ដែលមានចែង ដើម្បីអាចយល់ពីការកំណត់របស់នីតិនិពន្ធខ្មែរជុំវិញបញ្ហានេះ។

## ៤. ទំហំស្រាវជ្រាវ

ដោយសារតែបញ្ហានេះមានវិសាលភាពទូលាយ យើងនឹងលើកយកតែបទល្មើសនៃ បទរំលោភសេពសន្ថវៈ ដែលត្រូវបានបញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ប៉ុណ្ណោះ ដើម្បីវិភាគវែក

ញែក និងសិក្សាលម្អិត។ ប៉ុន្តែ បទរំលោភសេពសន្ថវៈ ដែលបានបញ្ញត្តក្នុងច្បាប់ពិសេសផ្សេងទៀត ក៏ត្រូវបានរំលេចផងដែរក្នុងស្រាវជ្រាវនេះ ដើម្បីជាបច្ច័យទាននៃគំនិតសិក្សា។

## ៥. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងផ្តល់នូវគុណប្រយោជន៍ដល់និស្សិត អ្នកច្បាប់ ក៏ដូចជាសាធារណជនទូទៅ បានដឹងពីបទរំលោភសេពសន្ថវៈ ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ និងការផ្តន្ទាទោស។ លើសពីនេះទៅទៀត ការស្រាវជ្រាវនេះ ក៏បានចូលរួមចំណែក ដល់កសាងសង្គមដើម្បីឆ្ពោះទៅរកនីតិរដ្ឋ តាមរយៈការផ្សព្វផ្សាយច្បាប់ និងលើកកម្ពស់ការយល់ដឹងអំពីច្បាប់ផងដែរ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីសិក្សាស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំបានស្វែងរកឯកសារពីប្រភពនានា រួមមានច្បាប់ និងបទដ្ឋានគតិយុត្តនានា ក៏ដូចជាសៀវភៅ និងមេរៀន ដែលមានបោះពុម្ពផ្សាយជាសាធារណៈ។ គំនិត និងពត៌មាននានា ដែលមាននៅក្នុងអត្ថបទស្រាវជ្រាវសារណានេះគឺផ្អែកតាមការប្រមូលពីប្រភពឯកសារ ដែលបានលើកឡើងខាងលើនេះ។ ដោយឆ្លងកាត់ការជ្រើរើស និងវិភាគព្រមទាំងពិភាក្សាជាមួយដៃគូសារណា ទិន្នន័យពត៌មាន និងសំយោគកម្មនៃគំនិត ដែលប្រមូលបានពីប្រភពឯកសារទាំងនេះ ត្រូវបានយកមករៀបចំ បញ្ចូលក្នុងអត្ថបទស្រាវជ្រាវ ដែលធ្វើឱ្យសារណាមួយនេះលេចចេញជារូបរាងឡើងមក។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងប្រធានបទនេះដែរ យើងនឹងបែងចែកជំពូកសិក្សាជា**២**ធំៗ គឺ**ជំពូកទី១** នឹងសិក្សាទាក់ទងជាមួយ បទល្មើសរំលោភសេពសន្ថវៈ និង**ជំពូកទី២** នឹងបកស្រាយទាក់ទងអំពី បទល្មើសបំពានផ្លូវភេទផ្សេងទៀត។

# ជំពូកទី១

# បទល្មើសរំលោភសេពសន្ថវៈ

## ១.១ និយមន័យ :

ដើម្បីស្វែងយល់ពី**បទរំលោភសេពសន្ថវៈ** យើងគួរពិនិត្យទៅលើទិដ្ឋភាពនានានៃ និយមន័យដែលត្រូវបានផ្តល់ឱ្យកន្លងមក ក៏ដូចជានិយមន័យដែលមាននៅក្នុង**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា២៣៩**។ ក្នុងការពិចារណាយ៉ាងសព្វទស្សន៍នេះ នឹងអាចឱ្យយើងយល់បានយ៉ាងច្បាស់ពីទស្សនៈនានាចំពោះ**បទល្មើសរំលោភសេពសន្ថវៈ**នេះ។

### ១.១.១. តាមវចនានុក្រមខ្មែរ :

**រំលោភ** មានន័យថា បំពានដោយសេចក្តីលោភ បំពារបំពានទាំងអំណាច បង្រ្កបលើ ប្រព្រឹត្តល្មើសលើ។ [1]

**សេព** មានពហុន័យភាពច្រើន ប៉ុន្តែមានន័យមួយទាក់ទងនឹងការបំពានផ្លូវភេទ គឺសេពមានន័យថា រួមបវេណី។[2]

**សន្ថវៈ** សំដៅដល់ដំណើរជិតជិតនឹងគ្នា ការស្និទ្ធជិតនឹងគ្នា។ ការរួមសុខទុក្ខ ការធ្វើមេថុនសេវនកិច្ច។ [3]

ដូចនេះ **រំលោភសេពសន្ថវៈ** មានន័យថាការរួមបវេណី ឬ ធ្វើនូវមេថុនសេវនកិច្ច ដោយបំពារបំពានអ្នកដទៃ។

### ១.១.២. តាមវាក្យសព្ទគតិយុត្ត :

និយមន័យនៃ**បទល្មើសរំលោភសេពសន្ថវៈ**ត្រូវបានផ្តល់ឱ្យខុសៗគ្នាទៅតាមការវិវឌ្ឍនៃនីតិជាតិកម្ពុជា៖

- ក្រមព្រហ្មទណ្ឌឆ្នាំ១៩៣៤ មាត្រា ៤៤៣ កថាខណ្ឌទី១ *ឈ្មោះណាដែលប្រើនូវការ បង្ខំ ឬ បំភិតបំភ័យគំរាម ហើយក៏បញ្ចូល ឬ ប៉ងនឹងបញ្ចូលអង្គជាតិ(អង្គជាត)ខ្លួនទៅ ក្នុងយោនីស្ត្រី ដែលមិនសុខចិត្តផងនោះ ត្រូវមានទោសដាក់ហ៊ែងចាប់ចង*។ [4]
  - ត្រង់នេះយើងឃើញថា **បទរំលោភសេពសន្ថវៈ**នៅក្នុងឆ្នាំ ១៩៣៤ ត្រូវបានគេហៅថា **កំហែងចាប់ចង** ហើយមានបញ្ញត្តិសម្រាប់តែករណី ចារីជាបុរស ហើយជនរងគ្រោះជាស្ត្រីចំពោះធាតុសម្ភារៈយើងឃើញថាមានកំណត់តែការបញ្ចូលអង្គជាតតែប៉ុណ្ណោះ។

[1] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត។

[2] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត។

[3] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត។

[4] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

- **ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ មាត្រា ៤៤៣ កថាខណ្ឌទី ១** *ជនណាបញ្ចូល ឬ ប៉ងនឹង បញ្ចូលទាំងបង្ខំ ឬ ទាំងគំរាម នូវអង្គជាតិរបស់ខ្លួន ទៅក្នុងអង្គជាតិ(អង្គជាត)នៃស្ត្រីដែលប្រកែក មិនព្រមស្ម័គ្រផង ជននោះត្រូវទុកជាមានពិរុទ្ធក្នុងបទកំហែងរួមបវេណី។*[5]
  - នៅក្នុងទិដ្ឋភាព**ក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦** យើងឃើញថា**បទល្មើសរំលោភសេពសន្ថវៈ** ត្រូវបានគេឱ្យឈ្មោះថា **បទកំហែងរួមបវេណី** ហើយបញ្ញត្តិនេះមានអត្ថន័យមិនខុសពី**បញ្ញត្តិព្រហ្មទណ្ឌក្នុងឆ្នាំ១៩៣៤**ទេ គឺចារីជាប្រុស ជនរងគ្រោះជាស្រីហើយធាតុសម្ភារៈជាការបញ្ចូលអង្គជាត។
- **ក្រឹត្យ-ច្បាប់លេខ ០២ ក្រ.ច ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ១៩៨០ ប្រការ៧ ចំណុច គ** បានចែងថា *ជនណាប្រព្រឹត្តបទចាប់ស្ត្រីភេទសេពសន្ថវៈ ជននោះត្រូវផ្តន្ទាទោសឃុំខ្លួនពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ ករណីចាប់បង្ខំនារីជំទង់សេពសន្ថវៈ ឬ បង្ខំរួមបវេណី រួចសម្លាប់ទាំងអ្នករងគ្រោះ គឺត្រូវផ្តន្ទាទោសឃុំខ្លួនជនមានទោសនោះ ពី ២០ឆ្នាំ ដល់អស់មួយជីវិត ឬ កាត់ទោសប្រហារជីវិត។*[6]
  - ក្រឹត្យនេះគ្រាន់តែបញ្ញត្តិពីការផ្តន្ទាទោសចំពោះ**បទល្មើសរំលោភសេពសន្ថវៈ** ចំពោះបទល្មើសណាដែលកើតឡើងក្រោយថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ រហូតដល់ ថ្ងៃដែលក្រឹត្យ-ច្បាប់នេះប្រកាសប៉ុណ្ណោះ។
- **ក្រមព្រហ្មទណ្ឌសម័យអន្តរកាល ឆ្នាំ១៩៩២ មាត្រា៣៣ មាតិកា៤ ស្តីពីបទឧក្រិដ្ឋ** បានចែងថា ៖

*១.ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀត ទោះភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋ ពី៥ឆ្នាំ ទៅ១០ឆ្នាំ។ ២.បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិ(អង្គជាត)ដោយ ឃោរឃៅ ដោយបង្ខំ ឬ ដោយមិនដឹងខ្លួនជាមុន។ [...]*[7]

  - នៅក្នុងបរិបទ**ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាលនេះ** យើងឃើញថាមានភាពជឿនលឿនជាងបញ្ញត្តិច្បាប់មុនៗ ត្រង់មានការបើកទូលាយនៃវិសាលភាព **បទល្មើសរំលោភសេពសន្ថវៈ** ដោយពុំកម្រិតភេទទេ គឺចារីអាចជាស្រី ឬ ប្រុសហើយជនរងគ្រោះក៏អាចជាមានភេទដូចគ្នា ឬ ផ្ទុយគ្នា។ ជាងនេះទៀត ក្រៅពីមធ្យោបាយបង្ខំ គំរាមកំហែងជាដើម ក្នុងបញ្ញត្តិនេះក៏មានការបញ្ជាក់ពីការមិនដឹង ខ្លួនជាមុនរបស់ជនរងគ្រោះទៀតផង ដែលនេះជាចំណុចបន្ថែមពីការមិនព្រមព្រៀងដោយបដិសេធ។

[5] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។
[6] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។
[7] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

- ចំណែក**មាត្រា៥ នៃច្បាប់ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋឆ្នាំ២០០២** ដែលបានកែប្រែបញ្ញត្តិ**មាត្រា ៣៣** ខាងលើចែងថា:

*១.ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះបីភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១០ឆ្នាំ ទៅ ១៥ ឆ្នាំ។*

*២.បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាត ឬ មធ្យោបាយផ្សេងទៀត ដោយឃោរឃៅ ដោយបង្ខំ ឬ ដោយមិនដឹងខ្លួនជាមុន។*[8]

- ត្រង់នេះយើងឃើញថា បញ្ញត្តិទាក់ទងនឹង**បទល្មើសរំលោភ**កាន់តែមានភាពជឿនលឿនឡើង ព្រោះតែការបញ្ចូលនូវមធ្យោបាយផ្សេងៗ នាំឱ្យវិសាលភាពនៃការកំណត់**បទល្មើសរំលោភ**កាន់តែទូលាយ ពោលគឺមិនមែនត្រឹមតែការបញ្ចូលអង្គជាតប៉ុណ្ណោះទេ។

- ចំពោះ**ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩** យើងនេះវិញ ត្រង់**មាត្រា ២៣៩**បានកំណត់ និយមន័យនៃ**បទរំលោភសេពសន្ថវៈ**ថា *គ្រប់អំពើបញ្ចូលអង្គជាតតាមបែបណាក៏ដោយ ឬ ការបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លៀតឱកាសគឺជាបទរំលោភសេពសន្ថវៈ។*[9]

- ចំពោះក្រមព្រហ្មទណ្ឌបច្ចុប្បន្ននេះ យើងអាចសម្គាល់បានថា ការកំណត់នូវ**បទល្មើសរំលោភ**នេះកាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានភាពច្បាស់លាស់ឡើង ព្រោះមានការប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ ដោយអាស្រ័យលើបទពិសោធន៍នៃនីតិមុនៗ ក៏ដូចជាករណីជាក់ស្តែងនៃសង្គម។

## ១.២. ធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ :

តាមគោលការណ៍នៃនីតិព្រហ្មទណ្ឌ ដើម្បីចាត់ទុកថាអំពើណាមួយជាបទល្មើសបាន តម្រូវឱ្យមានការបំពេញនូវធាតុផ្សំទាំងបីធំៗ គឺ **ធាតុច្បាប់** ឬ **ធាតុនីត្យានុកូល** , **ធាតុសម្ភារៈ** ឬ **ធាតុសត្យានុម័ត** , និង**ធាតុផ្លូវចិត្ត** ឬ **ធាតុអត្តនោម័ត** យ៉ាងដាច់ខាត ពោលគឺក្នុងបណ្តាធាតុផ្សំទាំង ៣ នេះ បើមានបាត់វត្តមាននូវធាតុណាមួយនោះ គេពុំអាចចោទប្រកាន់នូវបទល្មើសព្រហ្មទណ្ឌនោះបានឡើយ។[10] ធាតុផ្សំទាំង៣នេះ ត្រូវបាននីតិករបញ្ចូលបន្សំទៅក្នុង ការចងក្រងនូវមាត្រាស្តីពីបទល្មើសព្រហ្មទណ្ឌទាំងពួង ដែលធ្វើឱ្យពាក្យពេចន៍ទាំងឡាយ

---

[8] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

[9] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៥ ដល់ ៧៦ មាត្រា ២៣៩។

[10] http://www.pheakdeylaw.com/kh/publication/45។

នៅក្នុងមាត្រាច្បាប់ទាំងនោះអាចឱ្យយើងទាញយកមកបំបែកវាជាធាតុទាំង៣បាន។ ជាក់ស្តែងការសិក្សាលើធាតុផ្សំនៃ**បទរំលោភសេពសន្ថវៈ** គឺតម្រូវឱ្យយើងលើកយកនូវខ្លឹមសារ នៃ**មាត្រា២៣៩** នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** ដែលជាអត្ថបទច្បាប់ព្រហ្មទណ្ឌ ដែលមាន នីត្យានុកូលភាពក្នុងពេលបច្ចុប្បន្ន មកធ្វើការពិចារណា។

**១.២.១.ធាតុនីត្យានុកូល ឬ ធាតុច្បាប់** :

យើងឃើញថាទាក់ទងទៅនឹងបញ្ហា**បទល្មើសរំលោភសេពសន្ថវៈ** ត្រូវបានចែង កំណត់ដោយ**ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩** នៅក្នុង**ជំពូកទី៣ ការបំពានផ្លូវភេទ មាត្រា ២៣៩** ដោយមានសេចក្តីបញ្ញត្តថា៖

*គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្លក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ។*

*បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ទៅ ១០ (ដប់) ឆ្នាំ។*

*នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ១៥(ដប់ប្រាំ) ឆ្នាំឡើងទៅ។*[11]

**១ .២.២. ធាតុសត្យានុម័ត ឬ ធាតុសម្ភារៈ** :

**ធាតុសត្យានុម័ត** ឬ ហៅថាជា**ធាតុសម្ភារៈ**គឺជាអំពើ ឬ ដំណើរនៃការប្រព្រឹត្តបទល្មើស ដែលស្តែងចេញមកខាងក្រៅរបស់ចារី ឬ អាចកំណត់ថាជាធាតុនៃបទល្មើសដែលយើងអាចមើលឃើញខាងក្រៅបាន។ ធាតុនេះជាធាតុផ្សំមួយ ដែលបង្កើតឱ្យមានជាភស្តុតាងជាប្រយោជន៍ក្នុងការដាក់បន្ទុក។ ជាងនេះទៀត ធាតុនេះក៏ជាធាតុមួយដែលជាបច្ច័យ ដែលញុាំងឱ្យគេអាចកំណត់បាននូវធាតុខាងក្នុង ដែលយើងស្គាល់បានថាជា**ធាតុអត្តនោម័ត** នោះផងដែរ។ ដើម្បីអាចបំពេញនូវធាតុសត្យានុម័តនេះ គឺតម្រូវឱ្យបំពេញនូវធាតុសំខាន់ តូចៗ៣ទៀត គឺ១.**ហេតុ** គឺហេតុដែលនាំឱ្យមានព្យសនកម្មគឺជាបទល្មើស, ២.**ព្យសនកម្ម** គឺផលវិបាកនានាដែលកើតមានដោយសារបទល្មើស, និង៣.**ទំនាក់ទំនងហេតុ និងផល** គឺតម្រូវឱ្យបទល្មើសជាហេតុដែលនាំឱ្យមានព្យសនកម្ម ហើយព្យសនកម្មដាច់ខាតជាវិបាកដែលកើតមានដោយសារបទល្មើសនោះ។ ធាតុតូចៗទាំង៣នេះបើមានអវត្តមាននូវធាតុណាមួយ នាំឱ្យធាតុសត្យានុម័តពុំបំពេញឡើយ ហើយនាំឱ្យបទល្មើសខ្វះធាតុផ្សំពុំអាចចោទប្រកាន់ពីចំពោះបទល្មើសព្រហ្មទណ្ឌនោះបានឡើយ។[12]

បើយើងពិនិត្យទៅលើពាក្យពេចន៍នៃ**មាត្រា ២៣៩** នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** យើងអាចសិក្សាដោយលម្អិតលើធាតុសត្យានុម័តនៃ**បទរំលោភសេពសន្ថវៈ**ជាចំណុចៗ ដូចតទៅ៖

[11] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ទំព័រ ៧៥ ដល់ ៧៦ មាត្រា ២៣៩។

[12] http://www.pheakdeylaw.com/kh/publication/45។

**១.២.២.១ សម្ភារៈ និងសកម្មភាពប្រព្រឹត្តបទល្មើស** :

**ក. ការបញ្ចូលអង្គជាត** :

នៅក្នុង**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** យើងឃើញថាមានការប្រើពាក្យពេចន៍ថា«**គ្រប់អំពើបញ្ចូលអង្គជាតិតាមបែបណាក៏ដោយ**» ជាពាក្យពេចន៍ដែលបើកលទ្ធភាពក្នុងការបកស្រាយឱ្យបានគ្រប់គ្រាន់ ស្របតាមវិវត្តនភាព (ដំណើរប្រែប្រួល)នៃបទល្មើសតាមសម័យ កាល។

ក្នុងឃ្លាគន្លឹះនេះ យើងឃើញពាក្យ **អង្គជាត** ជាពាក្យដ៏សំខាន់មួយដែលគប្បីឱ្យយើង យល់នូវន័យនៃពាក្យនេះផងដែរ។ ពាក្យ អង្គជាត ដែលមានការច្រឡំថា អង្គជាតិ ហើយការសរសេរ អង្គជាត ជាអង្គជាតិ នេះ យើងឃើញនៅក្នុងអត្ថបទច្បាប់ព្រហ្មទណ្ឌចាស់ៗដូចជា **ក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៣៤ ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦** ជាដើម។ ពាក្យនេះដែលត្រឹមត្រូវគឺ អង្គជាត ដែលមានន័យថា លិង្គ ឬ យោនី ដែលពាក្យនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្នុង **វចនានុក្រមខ្មែរ**។ ដូចនេះ ក្រៅពីលិង្គ និងយោនី ពុំអាចឱ្យអ្នកបកស្រាយពង្រីកវិសាល ភាពនៃន័យចំពោះពាក្យ អង្គជាត នេះបានឡើយ។ មានវិវាទមតិមួយចំនួនលើពាក្យ អង្គជាត និងពាក្យ**កេរភេទ**។ **តើពាក្យទាំងពីរនេះមានអត្ថន័យដូចគ្នា ឬ ខុសគ្នា?** ត្រង់នេះមានការបកស្រាយខ្លះយល់ថា កេរភេទ មានលក្ខណៈទូទៅជាង អង្គជាត ដែលកំណត់តែលិង្គ និងយោនី។ ការលើកឡើងនេះសំអាងទៅលើយុត្តសាស្ត្រជាក់ស្តែង ទាក់ទងនឹង **បទល្មើសបង្ហាញកេរភេទ** ក្នុងមាត្រា ២៤៩ នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** ដែលក្នុងករណី នារីម្នាក់ បង្ហាញសុដន់ និងរាងកាយរបស់ខ្លួន ដោយស្លៀកតែខោក្នុង ក៏ត្រូវបានគេចាត់ថាជាកេរភេទដែរ។[13] សុដន់ ពុំមែនជាប្រដាប់ ភេទទេ។ ត្រង់នេះ យើងអាចកំណត់នូវន័យនៃកេរភេទ ដោយសន្មតថាជាផ្នែកកេរខ្មាស នៃផ្លូវភេទ ដែលអាចបណ្តាលឱ្យមានអារម្មណ៍អៀនខ្មាសផ្នែកផ្លូវភេទ។

ឧទាហរណ៍៖ សុដន់ ជាផ្នែកដែលនារីតែងបិទបាំង ឬ ជាផ្នែកកំបាំងនៃភេទស្រី។

**ការបញ្ចូលអង្គជាត** គឺសម្តៅដល់ការធ្វើឱ្យចូលនូវអង្គជាតទៅភាគីម្ខាងទៀត។

ពាក្យថា**ចូល** គឺមានន័យថា ទៅពីខាងក្រៅកាន់ខាងក្នុង។[14] ត្រង់នេះបញ្ជាក់ពីជម្រៅនៃការបញ្ចូល។ ហេតុនេះនាំឱ្យយើងអាចទាញបានថា **ការបញ្ចូលអង្គជាត** គឺជាការធ្វើឱ្យអង្គជាត របស់ចារីចូលក្នុងជម្រៅ ទៅភាគីជនរងគ្រោះ។

---

[13] https://ams.com.kh/central/detail/33867។

[14] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ ជួន ណាត។

**ឧទាហរណ៍៖** ការបញ្ចូលអង្គជាតរបស់ជនល្មើស ទៅក្នុង**វច្ចមគ្គ**[15]របស់ជនរងគ្រោះ។ ការបញ្ចូលនេះ គឺបានដល់ជម្រៅក្នុងវច្ចមគ្គ។

ចំពោះសេចក្ដីថា«**តាមបែបណាក៏ដោយ**» គឺបានដល់គ្រប់កន្លែងទាំងឡាយនៅលើរាងកាយនៃភាគីរងគ្រោះ ដោយវិធីបញ្ចូលគ្រប់បែប ពោលគឺមិនមែនទាល់តែបញ្ចូលនូវ អង្គជាត ទៅក្នុងអង្គជាតនោះទេ។

**ឧទាហរណ៍៖** ការបញ្ចូលអង្គជាតរបស់ចារីទៅក្នុងមាត់នៃជនរងគ្រោះក៏រាប់ថាជា**បទល្មើសរំលោភសេពសន្ថវៈ**បានដែរ។

ការបញ្ចូលអង្គជាតអាចជាប្រយោជន៍ក្នុងការបន្សល់ទុកនូវភស្តុតាងជាក់បន្ទុកបានផងដែរ ដោយការពិនិត្យទៅលើ ការកកិតនៃអវយវៈភេទ វច្ចមគ្គជាអាទិ៍ ក៏ដូចជាទឹកកាម ដែលបានបន្សល់ទុកនៅខាងក្នុងនោះ។ ជាទូទៅភស្តុតាងទាំងនេះ អាចទទួលបានដោយការពិនិត្យ និងតម្រូវឱ្យមានការព្រមព្រៀងពីជនរងគ្រោះផង ដោយគោរពលើគោលការណ៍ បូរណភាពនៃរូបរាងកាយបុគ្គល។

**ខ. ការបញ្ចូលឧបករណ៍** :

ដោយផ្អែកទៅលើការបញ្ញត្តិនៅក្នុង**ក្រមព្រហ្មទណ្ឌ** យើងឃើញមានការប្រើពាក្យថា «**អំពើបញ្ចូលឧបករណ៍ណាមួយ**» ដែលត្រង់នេះគឺសំដៅដល់ឧបករណ៍ដែលប្រើប្រាស់បម្រើឱ្យតម្រេកនៃតណ្ហាក្នុងការរួមភេទ ដូចជាលិង្គសិប្បនិម្មិត យោនីសិប្បនិម្មិត ដំបង ដៃ ជាអាទិ៍។ ត្រង់ពាក្យថា ឧបករណ៍ណាមួយមិនបានកំណត់ឱ្យជាក់ទេ ដែលនេះជាការទុកលទ្ធភាពដើម្បីបកស្រាយ និងកំណត់បទល្មើសតាមជាក់ស្ដែង។ ប៉ុន្តែយើងអាចសន្មតថាជា ឧបករណ៍ដែលបម្រើឱ្យតម្រេកតណ្ហាកាម ព្រោះថាបើឧបករណ៍ទាំងនោះពុំប្រើក្នុងការសម្រេចនូវតម្រេកកាមទេវាក៏ពុំមានអ្វីទាក់ទងនឹងបទល្មើសរំលោភសេពសន្ថវៈនេះដែរ។ ជាឧទាហរណ៍ក្នុងករណីនេះមានដូចជា ជនល្មើសបញ្ចូលលិង្គសិប្បនិម្មិតទៅក្នុង អង្គជាត ឬ វច្ចមគ្គ នៃជនរងគ្រោះជាដើម។

ចំណុចនេះ យើងពុំឃើញមានកំណត់ក្នុងអត្ថបទច្បាប់ចាស់ៗនោះទេ។ ហេតុនេះ ការបញ្ចូលចំណុចនេះទៅក្នុងនិយមន័យនៃ**បទល្មើសរំលោភសេពសន្ថវៈ** គឺជាការវិវត្តទៅតាមហេតុការណ៍ជាក់ស្ដែង។

**គ. ប្រព្រឹត្តនៅលើអ្នកដទៃ** :

ការប្រព្រឹត្តបទល្មើសរំលោភនេះ ដាច់ខាតត្រូវប្រព្រឹត្តលើអ្នកដទៃ។ ដូច្នេះ ការសម្រេចកាមដោយខ្លួនឯងមិនមែនជាកម្មវត្ថុនៃ**បទល្មើសរំលោភ**ទេ ប៉ុន្តែការសម្រេចកាមដោយខ្លួនឯងក្នុងកន្លែងសាធារណៈ អាចជា**បទល្មើសបង្ហាញកេរភេទ**។ ពាក្យគន្លឹះ«**អ្នកដទៃ**» ជាអ្វីដែលយើងគួរកំណត់ឱ្យច្បាស់។ អ្នកដទៃ គឺសម្ដៅទៅលើ ទីទៃពីខ្លួន ឬ មិនមែនជាខ្លួន។ អ្នកដទៃ មិនមែនមានន័យថា អ្នកមិនជាប់សាច់ឈាមលោហិតបងប្អូន ទើបហៅថាជា

[15] វច្ចមគ្គ មានន័យថា រន្ធគូទ។

អ្នកដទៃនោះទេ។ ទោះបីញាតិក្តី ញាតិពន្ធក្តី ក៏សុទ្ធសឹងជាអ្នកដទៃទាំងអស់ ព្រោះន័យនៃអ្នកដទៃ ទីនេះ គឺសំដៅដល់អ្នកដែលមិនមែនជាខ្លួន។ ត្រង់នេះយើងមិនអាចទាញថា ការ**រំលោភសេពសន្ថវៈ** លើសាច់ញាតិឯងប្រពន្ធឯង កូនឯង មិនមែនជាការរំលោភលើអ្នកដទៃឡើយ។

ទន្ទឹមនឹងជនរងគ្រោះដែលជាអ្នកដទៃ ហើយពាក្យពេចន៍នៃ**មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ**ក៏មានសេចក្តីសម្តៅដល់ទង្វើនៃការប្រព្រឹត្តបទល្មើសនេះ ចាំរីត្រូវប្រព្រឹត្តទៅលើជនរងគ្រោះ ពោលគឺ ជនរងគ្រោះត្រូវតែទទួលរងនូវអំពើនៃបទល្មើសដែលធ្វើដោយជនល្មើស។ ផ្ទុយមកវិញ ក្នុងករណីដែលជនល្មើសបានបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តមកលើខ្លួនវិញ ករណីនេះមានវិវាទ មតិពីរបានលើកឡើង។ **មតិទី១** គឺផ្អែកលើគោលការណ៍នៃការប្រព្រឹត្តបទល្មើស អាចជាការប្រព្រឹត្តដោយសកម្ម(ជនល្មើសប្រព្រឹត្តដោយផ្ទាល់លើជនរងគ្រោះ) និងការប្រព្រឹត្ត ដោយអកម្ម(ជនល្មើសបានបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តមកលើខ្លួន)។ មតិនេះ យើងអាចសង្កេតឃើញក្នុងយុត្តសាស្ត្ររបស់តុលាការព្រហ្មទណ្ឌបារាំង ប៉ុន្តែក្រោយមកយុត្តសាស្ត្រនេះត្រូវបានគេរិះគន់ ដោយសំអាងថាខុសនឹងពាក្យពេចន៍ដែលច្បាប់កំណត់«**ប្រព្រឹត្តទៅ លើអ្នកដទៃ**»។ បន្ទាប់ពីមានការរិះគន់ សាលាវិនិច្ឆ័យបារាំង ហាក់ទទួលយកការរិះគន់នោះដែរ តែក៏នៅតែរក្សានូវនិត្យានុកូលភាពនៃសាលក្រមនោះដដែល ដែលត្រង់នេះអាចស បង្ហាញថា សាលាវិនិច្ឆ័យបារាំង នៅតែយល់ស្របក្នុងយុត្តសាស្ត្រនោះដដែល។ ដោយឡែក**មតិទី២** ដែលជាមតិរិះគន់មតិទី១នោះ បានសំអាងពីការគោរពលើពាក្យពេចន៍ច្បាប់ ជាធំនាំឱ្យការដែលប្រព្រឹត្តដោយឱ្យអ្នកដទៃធ្វើមកលើខ្លួន ពុំអាចជា**បទល្មើសរំលោភសេពសន្ថវៈ**ទេ តែជា**បទល្មើសប្រទូស្តកេរខ្មាស** ដែលកំណត់ពីករណីឱ្យអ្នកដទៃប្រព្រឹត្តមកលើ ខ្លួន តួយ៉ាងជនល្មើសបង្ខំឱ្យជនរងគ្រោះបញ្ចូលលិង្គ ទៅក្នុងមាត់ និងវច្ចមគ្គរបស់ខ្លួន។[16] បញ្ហានេះយើងអាចពិចារណាបានដែរ ដោយពិនិត្យលើស្មារតីនៃ**មាត្រា ៥ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ការបកស្រាយច្បាប់ព្រហ្មទណ្ឌ** បានចែងថា៖***ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវ បកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ។*** ស្មារតីមាត្រានេះយើងអាចយល់បានថា ការបកស្រាយតាមនិយមន័យ ដែលមាននៅក្នុងបញ្ញត្តិក្រម គួរគប្បីទទួលបានអាទិភាពជាងការបកស្រាយដោយទាញជាយុត្ត សាស្ត្រ។

ប៉ុន្តែមានចំណុចមួយដែលគួរគិតគួរផងដែរនោះ គឺក្នុងករណីដែលជនល្មើស បានបង្ខំឱ្យជនរងគ្រោះបញ្ចូលអង្គជាតខ្លួន ទៅក្នុងអង្គជាតរបស់ជនល្មើស។ ត្រង់នេះ **តើវាជាការប្រទូស្តកេរខ្មាស ឬ ជាការរំលោភសេពសន្ថវៈ?** ពិតណាស់ត្រង់ករណីនេះ វាជាការ**រំលោភសេពសន្ថវៈ** ព្រោះថាទោះបីជាជនល្មើសបង្ខំឱ្យជនរងគ្រោះបញ្ចូល អង្គជាតខ្លួនទៅក្នុងអង្គជាតរបស់ជនល្មើសក៏ដោយក្តី បើយើងទាញតាមវិធានប្រាសវិញ យើងនឹងឃើញ

[16] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

ថា អង្គជាតរបស់ជនល្មើស ក៏ត្រូវបានបញ្ចូលទៅក្នុងអង្គជាតជនរងគ្រោះដូចគ្នា។ វិចារដែលទាញមកនេះ យើងអាចយល់ថា ការបង្ខំឱ្យជនរងគ្រោះប្រព្រឹត្តមកលើជនល្មើស ចំពោះកន្លែងទីទៃពីអង្គជាត គឺជា**បទល្មើសប្រទូស្តកេរខ្មាស** ដោយសារអង្គជាតរបស់ជនល្មើសពុំបានបញ្ចូលទៅក្នុងជនរងគ្រោះ តែជនល្មើសបែរជាត្រូវបានបញ្ចូលអង្គជាតដោយជនរងគ្រោះវិញ។ រីឯករណីដែលជនរងគ្រោះត្រូវបានជនល្មើសបង្ខំឱ្យបញ្ចូលអង្គជាត ទៅក្នុងអង្គជាតនោះ ករណីនេះជា **បទល្មើសរំលោភសេពសន្ថវៈ** ព្រោះជនល្មើសក៏បានបញ្ចូលអង្គជាតខ្លួនទៅក្នុងអង្គជាតជនរងគ្រោះដែរ។ ចំណុចដែលគួរសម្គាល់មួយទៀតគឺ ការបញ្ចូលអង្គជាត ទៅក្នុងអង្គជាតអាចកើតមានតែរវាងភេទផ្ទុយគ្នាប៉ុណ្ណោះ ក្នុងករណីដែលភាគីមានភេទដូចគ្នាពុំអាចកើតមានឡើងឡើយ។

**១.២.២.២. អវត្តមាននៃការព្រមព្រៀង** :

ការរួមភេទ ដែលអវត្តមាននូវការព្រមព្រៀង គឺជា **បទល្មើសព្រហ្មទណ្ឌ រំលោភសេពសន្ថវៈ**។ ការមិនព្រមព្រៀងនាំឱ្យឈានដល់ស្ថានភាពនៃការប្រព្រឹត្តបទល្មើសដូចជា ការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ក៏ដូចជាការឆ្មក់ឱកាស ដែលសកម្មភាពទាំងនេះ ជនល្មើសធ្វើឡើងដើម្បីញុំាងឱ្យការប្រព្រឹត្តនូវអំពើរំលោភខាងលើ (បញ្ចូលអង្គជាតតាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាតអ្នកដទៃ)អាចប្រព្រឹត្តទៅបាន។

**ក . សញ្ញាណទូទៅនៃការព្រមព្រៀង** :

**ការព្រមព្រៀង** គឺជាការសុខចិត្ត អនុលោមតាម យល់តាម មិនទទឹងទាស់ រួមចិត្ត គំនិតជាមួយ ស្រុះស្រួលជាមួយ។ [17] នៅក្នុងវិស័យ**នីតិឯកជន** ការព្រមព្រៀងកើតមានឡើងដរាបណាមានសំណើ ពោលគឺបើគ្មានអ្នកណាស្នើអ្វីមកទេ ក៏មិនអាចកើតមានការព្រម ព្រៀងដែរ។ ហើយទន្ទឹមនឹងមានសំណើស្នើមកនោះ ក៏ត្រូវមានការបង្ហាញ**ស្ទីការ**[18]ផង ទើបការព្រមព្រៀងមានអត្ថិភាពឡើង។ [19]ដោយឡែកនៅក្នុងបរិបទនៃ **នីតិសាធារណៈ** ជាពិសេស**នីតិព្រហ្មទណ្ឌ** ការព្រមព្រៀងពុំចាំបាច់ទាល់តែមានសំណើនោះទេ។ ជាក់ស្តែងមានការប្រព្រឹត្តសកម្មភាពបំពានផ្លូវភេទកើតឡើង តែជនរងគ្រោះមិនបដិសេធ ហើយបង្ហាញកិរិយាបើកទូលាយព្រមតាមអំពើនោះ ក៏ជាការព្រមព្រៀងផងដែរ។ ដូចគ្នានេះដែរ ករណីបុរសជាស្វាមី បង្ហាញពីចំណង់ផ្លូវភេទទៅរកភរិយា ហើយ

[17] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត។

[18] ស្ទីការ ការសម្តែងឆន្ទៈ ដែលបុគ្គលម្នាក់បានបញ្ចេញការយល់ព្រមរបស់ខ្លួនចំពោះសំណើ ដែលបុគ្គលដទៃ បានស្នើមកខ្លួន ដើម្បីបង្កើតកិច្ចសន្យា។

[19] មាត្រា ៣៣៦ និងមាត្រា ៣៣៧ ទំព័រ ១២៣ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១២។

កិរិយាបង្ហាញសកម្មភាពជាការអនុញ្ញាតឱ្យស្វាមីរួមសមគ្គសំវាស ដែលនេះក៏ជាសញ្ញាណនៃការព្រមព្រៀងផង ដែរ ដោយពុំចាំបាច់មានសំណើមកភាគីម្ខាងទៀតទេ។

គេអាចបែងចែកការព្រមព្រៀងជា ២ប្រភេទ៖

- **ការព្រមព្រៀងដោយសកម្ម** : ជាការព្រមព្រៀង ដែលសម្តែងចេញដោយអំពើ តាមផ្លូវកាយ (កាយ និង វាចា)។ ការព្រមព្រៀងដោយសកម្ម ជាការព្រមព្រៀង ដែលជាក់ស្តែង និងច្បាស់លាស់ ងាយនឹងកំណត់ បាន។ ប៉ុន្តែវាក៏អាចត្រូវលើក ចោលបានដែរក្នុងស្ថានភាព បង្ខិតបង្ខំ គំរាមកំហែង រងហិង្សាជាដើម ពោលគឺក្នុង ស្ថានភាព ដែលការបង្ហាញ ឆន្ទៈពុំមានសេរីភាពពេញលេញ។
    - **ការព្រមព្រៀងតាមផ្លូវកាយ** : ជាការសម្តែងការព្រមព្រៀង តាមអំពើ ដែលបានសម្តែង ចេញមកដូចជា ការងក់ក្បាល ការបោយដៃ ការធ្វើសញ្ញាបញ្ជាក់ពីការព្រមព្រៀងផ្លូវភេទ សម្រាតកាយចាំជាស្រេច ជាដើម។
    - **ការព្រមព្រៀងតាមផ្លូវវាចា** : ជាការពោលពាក្យអនុញ្ញាត ឬ ពាក្យដែល មានសេចក្តី បញ្ជាក់ពីការអនុញ្ញាត ដែលភាគីអាចយល់ថាជាសញ្ញានៃ ការអនុញ្ញាត ឬ ព្រមព្រៀង ឬ អ្នកដទៃទៀតអាចដឹងបានយ៉ាងទូទៅថា ជាពាក្យបញ្ជាក់ពីការយល់ព្រមរួមភេទ។
- **ការព្រមព្រៀងដោយតុណ្ហី** : ជាការព្រមព្រៀងដោយស្ងាត់ ឥតតបត។ វាជាការព្រម ព្រៀង ដែលពុំអាច កំណត់ពីភាពច្បាស់លាស់នៃការព្រមព្រៀងបានឡើយ។ ការ ព្រមព្រៀងបែបនេះអាចមានការទទួល ស្គាល់ក្នុងករណីមួយចំនួននៅក្នុង**នីតិឯកជន** ដូចជា ការបន្តភតិសន្យា នៅពេលដែលពេលកំណត់ដួល បានផុត ភាគីទាំងសង ខាងពុំបង្ហាញឆន្ទៈក្នុងការបញ្ចប់ភតិសន្យា នាំឱ្យភតិសន្យាត្រូវបានបន្តក្នុងរូប ភាពជា ភតិសន្យាដែលពុំកំណត់រយៈពេល។[20] ដោយឡែកក្នុង**នីតិសាធារណៈ** ការយល់ថា តុណ្ហីភាព ជាការព្រមព្រៀងត្រូវបានរិះគន់យ៉ាងខ្លាំង ជាពិសេសក្នុងករណី**រំលោភ សេពសន្ថវៈ**នេះជាដើម។ ហេតុ នេះក៏ព្រោះតែតុណ្ហីភាព ជាទង្វើអកម្ម ពិបាកយកធ្វើ ជាប្រយោជន៍ក្នុងភស្តុតាងណាស់ ហើយពេលខ្លះ ជនរងគ្រោះស្ថិតក្នុងស្ថានភាពបង្ខំ ឬ គំរាមកំហែង។ ដូចជាករណីដែលជនរងគ្រោះឃើញចារី មាន កាំភ្លើងជាប់ដៃ ហើយ ជនរងគ្រោះស្ថិតក្នុងស្ថានភាព ដែលមិនអាចគេចខ្លួនបាន។ ដើម្បីការពារជីវិត ទោះបី ចារីពុំបានសម្តែងសកម្មភាពបង្ខិតបង្ខំដោយផ្ទាល់ក៏ដោយ ជនរងគ្រោះមានតែនៅ ស្ងៀម ក្នុង

[20] មាត្រា ៦១៤ នៃក្រមរដ្ឋប្បវេណីទំព័រ ២២៤ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១២។

លក្ខណៈតុណ្ហីភាព[21]ប៉ុណ្ណោះ។ ហេតុនេះ ការព្រមព្រៀងដោយតុណ្ហីភាព ជាទូទៅពុំត្រូវបានទទួលថា ជាការព្រមព្រៀងទាំងស្រុងទេក្នុង**នីតិព្រហ្មទណ្ឌ** ដែល តម្រូវឱ្យមាន ភស្តុតាងយកមកបន្ថែមទៀតរួម បញ្ជាក់។

**ខ. សច្ចធារណ៍នៃការព្រមព្រៀងក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍** :

នៅក្នុងទំនាក់ទំនងអាពាហ៍ពិពាហ៍ គេអាចសន្មតដោយសច្ចធារណ៍ថា ជាការព្រមព្រៀង។ ប៉ុន្តែដូចយើង បានដឹងពី**អានុភាពនៃសច្ចធារណ៍ក្នុងនីតិព្រហ្មទណ្ឌ**រួចមកហើយថា ពុំមានលក្ខណៈដាច់ខាតទេ គឺអាចលើក ចោលបានដោយភស្តុតាងផ្ទុយ។ ក្នុងករណីរួមសំវាសរវាងប្តីប្រពន្ធ ត្រូវបានគេសន្មតដោយសច្ចធារណ៍ប៉ុណ្ណោះ ថាជាការព្រមព្រៀង ដូចយើងធ្លាប់បានឃើញនៅក្នុងនិយមន័យនៃ **អាពាហ៍ពិពាហ៍** ក្នុង**ច្បាប់ស្តីពី អាពាហ៍ពិពាហ៍** ដែលបាន**និរាករណ៍**ដោយ **ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី**ថា ***អាពាហ៍ពិពាហ៍ គឺជាកិច្ច សន្យា ដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និងស្ត្រីម្នាក់ ដែលប្តេជ្ញាថាខ្លួននឹង រួមសមគ្គសំវាសជាមួយគ្នា តាមបញ្ញត្តិច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាម ទំនើងចិត្តរបស់ខ្លួន។*** ក្នុងនិយមន័យនេះ យើង សង្កេតឃើញពាក្យថា **សមគ្គសំវាស** ដែលពាក្យ **សមគ្គ** នេះមានន័យថា ព្រមព្រៀងនាំឱ្យសមគ្គសំវាស បាន សេចក្តីថា រួមសំវាសដោយព្រមព្រៀង។ តែទោះជាយ៉ាងណា និយមន័យនេះលែងមាននីត្យានុកូលភាពទៀត ហើ យ។ រីឯការលើកយកនិយមន័យនេះមកវែកញែក គឺគ្រាន់តែជាវិភាគទានគតិយុត្តប៉ុណ្ណោះ។ បើយើងក្រឡេកមក មើលនិយមន័យនៃ**បទល្មើសរំលោភសេពសន្ថវៈ** ដូចបានបកស្រាយនៅខាងលើត្រង់ពាក្យថា **អ្នកដទៃ** គឺសម្តៅ យកបុគ្គលដែលក្រៅពីខ្លួនឯង។ ហេតុនេះ ភរិយាក៏ជាអ្នកដទៃផងដែរ ព្រោះមានបុគ្គលភាពផ្សេងគ្នា។ ទន្ទឹមនឹង នេះដែរ **ក្រមព្រហ្មទណ្ឌ** ក៏ពុំបានបញ្ជាក់ពី**អញ្ញត្រកម្មលើកលែង**ចំពោះ**បទល្មើសរំលោភ**នេះ ក្នុងការប្រព្រឹត្តទៅ លើអ្នកនៅក្នុងគ្រួសារ ឬ ភរិយាទេ។ ដរាបណាគ្មានការកំណត់អញ្ញត្រកម្មនោះទេ ទង្វើនេះនៅតែជាបទល្មើស ព្រហ្មទណ្ឌដដែល។ ម៉្យាងវិញទៀត ដោយយោងតាមស្មារតីនៃ **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ**ដែលត្រូវបានប្រកាសឱ្យប្រើដោយ**ព្រះរាជក្រមចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥ មាត្រា ៣៥** បានចែងថា ***អំពើហិង្សាក្នុងគ្រួសារទាំងឡាយណា ដែលចូលជាបទល្មើស ព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដោយ យោងតាមច្បាប់ព្រហ្មទណ្ឌជាធរមាន។***រួមជាមួយនេះ **មាត្រា ៣** និង**មាត្រា ៧ នៃច្បាប់ដដែលនេះ**បញ្ញត្តិថា ***អំពើ រំលោភសេពសន្ថវៈ ពិសេសការប្រើអំពើហិង្សា សេពសន្ថវៈ គឺជាផ្នែកមួយនៃការឈ្លានពានផ្លូវភេទ ដែលត្រូវចាត់ ទុកជាអំពើហិង្សាក្នុងគ្រួសារ។*** [22] ដូចនេះ យើងអាចនិយាយជារួមបានថាការរួមសំវាសរវាងស្វាមី ភរិយា អាច

[21] តុណ្ហីភាព គឺជាភាពស្ងៀមស្ងាត់ក្នុងការបង្ហាញឆន្ទៈ ដោយយោងតាមសន្ទានុក្រមរដ្ឋប្បវេណី ២០០៧។
[22] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

សន្មតថាជាការព្រមព្រៀង តែបើសិនជាមានភស្តុតាងផ្ទុយណាបញ្ជាក់ផ្សេង យើងក៏អាច អនុវត្តនូវអានុភាពនៃ **បទល្មើសព្រហ្មទណ្ឌបទរំលោភសេពសន្ថវៈ** ក្នុងករណីនេះបាន ផងដែរ។ [23]

**គ . នីតិភាពនៃការរួមភេទ** :

ដោយផ្អែកលើ **កថាខណ្ឌទី៣ មាត្រា២៣៩** នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចែងថា ***នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥(ដប់ប្រាំ) ឆ្នាំឡើងទៅ*** មានន័យថា ច្បាប់ទទួលស្គាល់នូវលទ្ធភាពដែលបុគ្គលអាចសម្តែងឆន្ទៈខាងផ្លូវភេទចាប់ពី អាយុ១៥ឆ្នាំឡើងទៅ។ នៅពេលដែលបុគ្គលនោះ មានអាយុ១៥ឆ្នាំហើយ គេអាចបង្ហាញឆន្ទៈថាព្រមរួមភេទជាមួយភាគីម្ខាងទៀតបាន ដែលឆន្ទៈនេះជាឆន្ទៈដែលមានសុពលានុភាពគតិយុត្ត។[24] ដោយឡែក បើបុគ្គលនោះពុំទាន់គ្រប់១៥ឆ្នាំទេ(ក្រោមអាយុ១៥ឆ្នាំ) ការយល់ព្រម ឬ សម្តែងឆន្ទៈយល់ព្រមក្នុងរឿងរួមសំវាស ពុំមានការទទួលស្គាល់ ថាជាការព្រមព្រៀង ឡើយ ពោលគឺឆន្ទៈនោះជាឆន្ទៈអសុពលានុភាពគតិយុត្ត[25] ហើយការរួមភេទបែបនេះ ជាបទល្មើសព្រហ្មទណ្ឌមួយ ដែលមានចែងក្នុង**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា៤២ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ** ចែងថា ***ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង១៥(ដប់ប្រាំ) ឆ្នាំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ)ឆ្នាំដល់១០(ដប់)ឆ្នាំ។*** [26] ក្នុងស្មារតីនៃមាត្រាច្បាប់នេះ ការរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម១៥ឆ្នាំ ពុំបាច់មានធាតុផ្សំរំលោភសេពសន្ថវៈនោះទេ ក៏អាចផ្តន្ទាទោសបានដែរ ហើយបើទោះបីជាជនរងគ្រោះដែលជាអនីតិជន មានអាយុតិចជាង១៥ឆ្នាំនោះយល់ព្រមរួមសំវាសជាមួយចារីក៏ដោយ ក៏អំពើរបស់ចារីនៅតែជាបទល្មើសព្រហ្មទណ្ឌដដែល។ ការកំណត់ដោយ**ច្បាប់ពិសេស**បែបនេះព្រោះតែ នីតិករយល់ថា អនីតិជនដែលមានអាយុក្រោម១៥ឆ្នាំ ពុំទាន់មានការយល់ដឹងពេញលេញ ក្នុងការបង្ហាញឆន្ទៈក្នុងរឿងផ្លូវភេទនេះនៅឡើយទេ។ ដើម្បីការពារផលប្រយោជន៍របស់អនីតិជន ដែលមានអាយុក្រោម១៥ឆ្នាំពីការកេងចំណេញលើភាពខ្វះការយល់ដឹងនេះ ច្បាប់បានកំណត់ពីនីតិភាពនៃការរួមភេទគឺចាប់ពីអាយុ១៥ឆ្នាំឡើងទៅ។

បញ្ហានេះ មានមតិមួយចំនួន លើកឡើងពីការដល់នូវនីតិភាពតាមរយៈការរៀប អាពាហ៍ពិពាហ៍។ **តើអាចសង្គ្រោះបញ្ហានេះបានដែរ ឬ ទេ?** តាម**ក្រមរដ្ឋប្បវេណី មាត្រា ៩៤៨ អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍** គឺ

---

[23] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤។

[24] សុពលានុភាពគតិយុត្ត មានន័យថាសុពលភាព និងអានុភាពគតិយុត្ត។

[25] អសុពលានុភាពគតិយុត្ត មានន័យថាគ្មានសុពលភាព និងអានុភាពគតិយុត្ត។

[26] មាត្រា ៤២ ទំព័រ ១៦ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ ២០០៨។

ភាគីម្ខាងដែលជាអនីតិជន ដាច់ខាតត្រូវតែមានអាយុចាប់ពី១៦ឆ្នាំឡើងទៅ។[27] ហេតុនេះការសង្គ្រោះពុំអាចកើតមានឡើងឡើយ ព្រោះអនីតិជនដែលមានអាយុក្រោម១៥ឆ្នាំ ទោះមានការព្រមព្រៀងឱ្យរៀបការពីសំណាក់អាណាព្យាបាល ក៏ពុំអាចរាប់ថាជាការរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់ដែរ។ ហេតុនេះ នីតិភាពក៏ពុំអាចផ្តល់ឱ្យអនីតិជន ដែលមានអាយុក្រោម១៥ឆ្នាំតាមរយៈការរៀបអាពាហ៍ពិពាហ៍ដែលពុំទទួលស្គាល់ដោយច្បាប់ផងដែរ។ ករណីនេះបើមានការរួមភេទជាមួយ អនីតិជនដែលមានអាយុក្រោម១៥ឆ្នាំ អំពើនេះនៅតែជាបទល្មើសព្រហ្មទណ្ឌដដែលទោះ ចារីបានរៀបការតាមប្រពៃណីជាមួយជនរងគ្រោះក៏ដោយ។

**ឃ . ការប្រើអំពើហិង្សា** :

ការប្រព្រឹត្តនូវទង្វើបញ្ចូលអង្គជាត ឬ ឧបករណ៍ណាមួយ ដោយការប្រើហិង្សា គឺសំដៅដល់ការប្រើហិង្សាផ្នែកផ្លូវកាយទៅលើជនរងគ្រោះ។ ពាក្យថា **ហិង្សា** មានភាពទូលំទូលាយជាងពាក្យថា វាយ តប់ ទាត់ ធាក់ ពោលគឺ ហិង្សា គឺជាការបៀតបៀនលើរូបរាង កាយរបស់អ្នកដទៃ ដោយចេតនា តាមគ្រប់មធ្យោបាយទុច្ចរិត ដែលបណ្តាលឱ្យមាន ព្យសនកម្មជាផ្លូវកាយ ឬ ចិត្ត មានរបួស ឬ គ្មានរបួស។ ភាពដាច់ខាតនៃ ហិង្សា គឺត្រូវ តែជាការប្រព្រឹត្តលើជនដែលរងគ្រោះ ដូចជាការ វាយ តប់ ទាត់ ជនរងគ្រោះជាដើម។ តែក្នុងករណីមួយចំនួនរូបរាងកាយជនរងគ្រោះពុំត្រូវបានរងហិង្សាដោយផ្ទាល់ក៏ ដោយ ក៏ទុកថាជាការប្រព្រឹត្តហិង្សាដែរ ដូចជាដេញវាយ តែជនរងគ្រោះគេច ឬ ការបាញ់បញ្ឆិតត្រចៀកជនរងគ្រោះជាដើម។ ហេតុនេះព្រោះតែបំណងរបស់ចារី គឺការប្រើហិង្សាលើជនរងគ្រោះ ហើយព្យសនកម្មក៏កើតមានចំពោះជនរងគ្រោះផងដែរគឺ ព្យសនកម្មផ្លូចិត្ត ដែលធ្វើឱ្យជនរងគ្រោះភិតភ័យតក់ស្លុតជាដើម។ គួរសម្គាល់ផងដែរ ករណីនេះ អំពើហិង្សាបានចាប់កើតមានឡើងហើយ ខុសពីការគំរាមថានឹងប្រើហិង្សា គឺហិង្សាពុំទាន់កើតមានឡើងឡើយ ហើយម្យ៉ាងសកម្មភាពដែលបញ្ជាក់ពីការប៉ុនប៉ងហិង្សាក៏ពុំទាន់បានបញ្ចេញមកនៅឡើយដែរ។ រីឯករណីដែលមានការប្រព្រឹត្តលើវត្ថុនានា មានដូចជាការច្រាន ឬ បុកទម្លុះទ្វារបន្ទប់ជនរងគ្រោះ បោកសម្ភារៈរបស់ជនរងគ្រោះ ពុំមែនជាកម្មវត្ថុនៃ ការប្រព្រឹត្តហិង្សានោះទេ[28] តែក្នុងករណីខ្លះអាចជាការគំរាមកំហែង ដូចជាករណីដែលចារីចេតនាបោកកែវ ឬ ចូដើម្បីបង្កើតស្ថានភាពមួយដើម្បីឱ្យជនរងគ្រោះភ័យខ្លាច។

**ខ . ការបង្ខិតបង្ខំ** :

សញ្ញាណនៃ **ការបង្ខិតបង្ខំ** គឺជាអំពើផ្នែកផ្លូវកាយមួយ ដែលបង្កើតជាស្ថានភាពដាក់សម្ពាធដល់ជនរងគ្រោះទាំងផ្លូវកាយ ផ្លូវចិត្ត ដើម្បីឱ្យខ្លួនចារីអាចប្រព្រឹត្តនូវសកម្មភាពបញ្ចូលអង្គជាត ឬ ឧបករណ៍ណាមួយទៅលើ

[27] មាត្រា ៩៤៨ នៃក្រមរដ្ឋប្បវេណីទំព័រ ៣៤១ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១២។

[28] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤។

ជនរងគ្រោះបាន។ ការបង្ខំអាចក្រោមរូបភាព ជាច្រើន ក្នុងនោះ ការគំរាម ការគំហក ការប្រើហិង្សា ក៏ជារូបភាពនៃការបង្ខិតបង្ខំផងដែរ។ ដូចនេះ ការបង្ខិតបង្ខំ មានវិសាលភាពនៃន័យ ដែលវាជាវាក្យសព្ទមួយ ញ៉ាំងឱ្យយើងងាយយល់ពីទុច្ចរិតភាពនៃចារីបានយ៉ាងច្បាស់ ព្រមទាំងសង្កត់ន័យយ៉ាងជាក់លាក់សម្រាប់ ការកំណត់នូវធាតុផ្សំសត្យានុម័តនៃ**បទរំលោភសេពសន្ថវៈ**។

**ច . ការគំរាមកំហែង** :

**ការគំរាមកំហែង** គឺជារូបភាពមួយនៃការបង្ខិតបង្ខំ ដែលវាគឺជាអំពើសត្យានុម័ត សម្ដែងចេញលើផ្លូវកាយ និងចិត្តរបស់ជនរងគ្រោះ ដែលចារីបង្កើតឱ្យមានស្ថានភាព មួយគំរាម ឬ កំហែង ក្នុងចេតនាធ្វើឱ្យជនរងគ្រោះភ័យខ្លាច។ ដូចមានសេចក្ដីបញ្ជាក់ក្នុង **វចនានុក្រមខ្មែរ**ថា គំរាមកំហែង គឺ កំហែងឱ្យខ្លាច។ ដូចនេះ ខ្លាច គឺជាកម្មវត្ថុនៃការគំរាមកំហែង។ ការគំរាមកំហែង អាចធ្វើឡើងក្នុងសភាពជាអំពើដូចជា៖

- ការគំរាមកំហែងនឹងប្រព្រឹត្តអំពើហិង្សាដោយចារី ឬ ដោយជនសមគំនិតណាមួយ
- ការគំរាមកំហែងថានឹងប្ដឹងទៅតុលាការចំពោះរឿងណាមួយ
- ការគំរាមកំហែងថានឹងទុកចោលកណ្ដាលព្រៃស្ងាត់តែម្នាក់ឯង
- ការគំរាមកំហែងថានឹងធ្វើបាបឪពុកម្ដាយ ឬ សមាជិកគ្រួសារជនរងគ្រោះ[29]

រាល់ការគំរាមទាំងនេះ គ្រាន់តែជាលក្ខខណ្ឌដាក់សម្ពាធដល់ជនរងគ្រោះប៉ុណ្ណោះ។ ដោយឡែកការប្រព្រឹត្តជាក់ស្ដែងពុំទាន់មានឡើយ។ តួយ៉ាង ការគំរាមថាវាយជនរងគ្រោះ បើជនរងគ្រោះមិនរួមសំវាសជាមួយខ្លួន ចារីពុំទាន់បានវាយទៅលើជនរងគ្រោះនៅឡើយទេ តែបើជនរងគ្រោះពុំរួមសំវាសជាមួយចារីទេ ការគំរាមអាចកើតមានឡើងជាសកម្មភាព ជាក់ស្ដែង។

**ឆ . ការឆ្មក់ឱកាស** :

ការឆ្មក់ឱកាស គឺជាករណីមួយ ដែលត្រូវបានកំណត់ក្នុង**ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩** ដែលយោងចេញពីវាក្យសព្ទ «**ដោយមិនដឹងខ្លួនជាមុន**» ដែលមានកំណត់ក្នុងបទដ្ឋាន គតិយុត្តព្រហ្មទណ្ឌចាស់ គឺ**ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល** និង**ច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ**។ ការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ**ដោយឆ្មក់ឱកាស**សំដៅទៅលើ អំពើធ្វើឡើងដោយមិនឱ្យជនរងគ្រោះដឹងខ្លួនថា មានគេចង់ប្រព្រឹត្តអំពើមិនគប្បីមកលើជនរងគ្រោះឡើយ។ អំពើរបៀបនេះអាចប្រព្រឹត្តនៅពេលដែលជនរងគ្រោះ៖

- កំពុងដេកលក់ ដោយស្មានថាជាប្ដីរបស់ខ្លួន
- ត្រូវថ្នាំសណ្ដំ

[29] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤។

- ស្រវឹងស្រា ឬ ថ្នាំញៀនហួតដល់មិនដឹងខ្លួន
- ជាជនវិកលចរិតជាដើម។

**១.២.៣.ធាតុអត្តនោម័ត ឬ ធាតុផ្លូវចិត្ត** :

ធាតុអត្តនោម័ត គឺជាផ្នែកខាងក្នុងនៃបទល្មើស ដែលផ្ទុយទៅនឹងធាតុសត្យានុម័ត ដែលជាផ្នែកខាងក្រៅនៃបទល្មើស។ បើវិភាគតាមដំណាក់កាលនៃបទល្មើស យើងឃើញថាធាតុអត្តនោម័ត កើតមានមុនធាតុសត្យានុម័ត។ ប៉ុន្តែដោយសារនៅក្នុងដំណើរការស៊ើបអង្កេត គេអាចស្វែងយល់ពីធាតុអត្តនោម័ត តាមរយៈធាតុសត្យានុម័ត ទើបនាំឱ្យគេរៀង លំដាប់នៃធាតុផ្សំអត្តនោម័តបន្ទាប់ពីសត្យានុម័ត។ **ធាតុអត្តនោម័ត** គឺជាកិរិយាផ្លូវចិត្តរបស់ ជនល្មើសចំពោះអំពើបង្កគ្រោះថ្នាក់ដល់សង្គមដែលគេបានប្រព្រឹត្ត និងចំពោះបច្ច័យដែលកើតឡើងពីអំពើនោះ។ ធាតុផ្សំអត្តនោម័តនៃបទល្មើស គឺ កំហុស៖

- **កំហុស** : អាចជាកំហុសដែលកើតឡើងពីចេតនា ឬ អចេតនា ដែលចារីបានប្រព្រឹត្តត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។[30]

មានចំណុច **២**ទៀតដែលគួរពិចារណាផងដែរក្នុងផ្នែកអត្តនោម័តនៃបទល្មើសនេះ គឺ **គំនិតផ្តួចផ្តើមក្នុងការប្រព្រឹត្តបទល្មើស** និង**កម្មវត្ថុនៃការប្រព្រឹត្តបទល្មើស**។

- **គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស**[31]: សំដៅដល់ស្ថានភាពដែលជនល្មើសមានស្មារតី គ្រប់គ្រាន់ក្នុងការប្រព្រឹត្តបទល្មើសជាសត្យានុម័ត ដែលជំរុញដោយកត្តាខាងក្នុងចិត្ត មានន័យថាកត្តាខាងក្នុងនៃចិត្តរបស់ជនល្មើស បានជំរុញឱ្យកត្តាខាងក្រៅជាសត្យានុម័តប្រព្រឹត្តបទល្មើស ដើម្បីសម្រេចបាននូវគោលដៅប្រព្រឹត្តបទល្មើសដែលខ្លួនចង់បាន។[32]
- **កម្មវត្ថុនៃបទល្មើស** : គឺជាមុខព្រួញ ឬ ទិសដៅដែលប្រធាននៃបទល្មើស គឺជនល្មើស ចង់បង្កព្យសនកម្មលើ។ កម្មវត្ថុនៃបទល្មើស មាន**២** តាមទស្សនៈដែល បានលើកឡើង គឺទី១ **កម្មវត្ថុនៃបទល្មើស គឺជាច្បាប់ព្រហ្មទណ្ឌ**(ជនល្មើសចង់ បំពានច្បាប់ព្រហ្មទណ្ឌ) និងទី២ **កម្មវត្ថុនៃបទល្មើស គឺជាអ្វីដែលច្បាប់ការពារ**(ឧទាហរណ៍ ជនល្មើសសម្លាប់មនុស្ស ដែលជីវិតមនុស្ស គឺជាកម្មវត្ថុដែលច្បាប់ការពារ ដូចបានកំណត់ថាពលរដ្ឋគ្រប់រូបមានសិទ្ធិរស់រានមានជីវិតជាដើម)។ [33]

---

[30] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

[31] គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើស មានន័យដូចគ្នានឹង មូលហេតុនៃការប្រព្រឹត្តបទល្មើស។

[32] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

[33] មេរៀននីតិព្រហ្មទណ្ឌទូទៅ ឯកឧត្តម ហ៊ី សោភា។

**១.២.៣.១. កំហុសក្នុងបទរំលោភសេពសន្ថវៈ** :

នៅក្នុង**បទល្មើសរំលោភសេពសន្ថវៈ** ទោះបីជាបញ្ញត្តិនៅក្នុង**មាត្រា ២៣៩** នៃ **ក្រមព្រហ្មទណ្ឌ** ពុំបានបញ្ជាក់នូវវាក្យសព្ទ «**ចេតនា**» ផងទេ តែយើងអាចកំណត់បានថា បទល្មើសនេះ **មិនអាចជាបទល្មើសដែលជាកំហុសអចេតនានោះទេ** ព្រោះសកម្មភាពនៃសត្យានុម័តបទល្មើស កើតឡើងពីឆន្ទៈដោយត្រង់នៃជនល្មើសក្នុងចេតនភាព(ភាពចេតនា)ដើម្បី ប្រព្រឹត្តអំពើទុច្ចរិត។

ជនល្មើសពុំអាចលើកឡើងដោយដោះសាថា ខ្លួនដេកមមើ ឬ ស្ថិតក្នុងស្ថានភាពស្រវឹង បាត់បង់សតិម្ចាស់ការ ហើយជ្រុលជ្រួសទៅរំលោភសេពសន្ថវៈលើជនរងគ្រោះដើម្បីជាហេតុមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

**ក. ចេតនាទូទៅ** :

ចេតនាទុច្ចរិតទូទៅនៃការប្រព្រឹត្តបទល្មើស**រំលោភសេពសន្ថវៈ** ក៏មិនខុសពីចេតនា ទូទៅនៃការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនានាដែរ គឺចារីមានចេតនាប្រព្រឹត្តអំពើដែលខ្លួន បានដឹងថាច្បាប់ព្រហ្មទណ្ឌបានហាមឃាត់។ ចារីមិនអាចលើកឡើងថាខ្លួនមិនបាន ដឹងថាអំពើរំលោភសេពសន្ថវៈត្រូវបានហាមឃាត់ដោយច្បាប់នោះទេ ព្រោះតាមគោលការណ៍ គ្មាន នរណាដែលមិនស្គាល់ ឬ មិនយល់ដឹងពីច្បាប់ឡើយ។[34]

**ខ. ចេតនាទុច្ចរិតពិសេស** :

បន្ថែមពីលើចេតនាទុច្ចរិតទូទៅ អ្នកនីតិប្បញ្ញត្តអាចបន្ថែមនូវចេតនាទុច្ចរិតពិសេស សម្រាប់បទល្មើសណាមួយ។ អ្នកនីតិប្បញ្ញត្តពុំបានប្រើពាក្យចេតនាទុច្ចរិតពិសេសនៅក្នុង បញ្ញត្តិច្បាប់ឡើយ ក៏ប៉ុន្តែផ្តើមចេញពីអត្ថបទច្បាប់ដែលកំណត់បទល្មើសនីមួយៗអាចឱ្យគេយល់ពីបំណងរបស់អ្នកនីតិប្បញ្ញត្តិ ដែលទាមទារឱ្យរកភស្តុតាងអំពីចេតនាទុច្ចរិត ពិសេសមួយរបស់ចារី ដើម្បីឱ្យមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់។[35]

ចេតនាទុច្ចរិតពិសេសមានទស្សនៈ **២** តាមទស្សនវិស័យនៃអ្នកច្បាប់ ដែលមានការ បកស្រាយដូចខាងក្រោម។

**ខ.១. ចេតនាទុច្ចរិតពិសេស ជាមូលហេតុនៃការប្រព្រឹត្តបទល្មើស** :

ចេតនាទុច្ចរិតពិសេសក្នុងការប្រព្រឹត្តនូវបទល្មើស **រំលោភសេពសន្ថវៈ** គឺសំដៅ ទៅលើឆន្ទៈរបស់ជនល្មើសក្នុងការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ប្រព្រឹត្តទៅលើជនរងគ្រោះ ដោយដឹងយ៉ាងប្រាកដក្នុងចិត្តថា

[34] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

[35] នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

ជនរងគ្រោះពុំព្រមព្រៀងស្ម័គ្រចិត្ត ក្នុងការរួមសេវនកិច្ចជាមួយខ្លួន ហើយនេះក៏ជាមូលហេតុ ដែលធ្វើឱ្យជនល្មើស ចង់ប្រព្រឹត្ត បទល្មើសផងដែរ។

ចេតនានៃការប្រព្រឹត្តរបស់ជនល្មើសស្តែងតាមការប្រើអំពើឃោរឃៅ បំពារបំពាន បៀតបៀន ដូចជាការ គំរាមកំហែងដើម្បីឱ្យជនរងគ្រោះរួម**មេថុនកិច្ច**[36]ជាមួយខ្លួនជាដើម។

**ខ.២. ចេតនាទុច្ចរិតពិសេសសម្តៅចង់បានលទ្ធផលជាក់លាក់ណាមួយ** :

សម្រាប់ទស្សនៈនេះ ចេតនាទុច្ចរិតពិសេសរបស់ជនល្មើសគឺប្រាថ្នាឱ្យបានដល់នូវការសម្រេចនៃ សកម្មភាពរំលោភសេពសន្ថវៈ ជាមួយនឹងជនរងគ្រោះដោយខ្លួននឹង បញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ប្រព្រឹត្ត ទៅលើជនរងគ្រោះ ទោះបីជាជនរងគ្រោះមិនស្ម័គ្រក្តី ក៏គេប្រើគ្រប់វិធីដើម្បីធ្វើឱ្យសកម្មភាពរំលោភនោះបាន សម្រេចដែរ។

**១ .២.៣.២. គំនិតផ្តួចផ្តើមប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ** :

នៅក្នុងការប្រព្រឹត្ត**បទល្មើសរំលោភសេពសន្ថវៈ** កត្តាដែលជម្រុញឱ្យមាននូវចិត្តចង់ប្រព្រឹត្តនូវបទល្មើស នេះ គឺគ្មានអ្វីក្រៅពី**តម្រេកចំណង់ផ្នែកផ្លូវកាម**របស់ជនល្មើសនោះទេ ពោលគឺជនល្មើស មានចិត្តត្រេកត្រអាល ចង់រួមសង្វាសជាមួយជនរងគ្រោះ។ នៅក្នុងដំណាក់កាលនៃឆន្ទៈទុច្ចរិតយើងអាចបែងចែកជា២យ៉ាង៖

- **ឆន្ទៈប្រព្រឹត្តបទល្មើសកើតមានតាំងពីដំបូង** : គឺមានន័យថា ជនល្មើស មានចេតនាចង់ប្រព្រឹត្តបទល្មើស រំលោភសេពសន្ថវៈតាំងពីដំបូងមកម្ល៉េះរួចហើយខ្លួនក៏ចាប់ផ្តើមប្រព្រឹត្តបទល្មើសតែម្តង។

ឧទាហរណ៍៖ ចារីក្រោយពីបានឃើញជនរងគ្រោះដើរ តែឯងនៅក្បែរព្រៃត្រែងចារីបានកើតចិត្តចង់រំលោភសេពស ន្ថវៈលើជនរងគ្រោះ ហើយក៏បានប្រព្រឹត្តតែម្តង។

- **ឆន្ទៈប្រព្រឹត្តបទល្មើសកើតឡើងបន្ទាប់ពីការបដិសេធរបស់ជនរងគ្រោះ:** ជនល្មើសបានស្វែងរកការ យល់ព្រមពីជនរងគ្រោះក្នុងការសេពសេវនកិច្ចជាមួយខ្លួនតែដោយជនរងគ្រោះបដិសេធធ្វើឱ្យជនល្មើសកើតមាន ឆន្ទៈប្រព្រឹត្តបទល្មើស ហើយ ញ៉ាំងឱ្យកើតជាសកម្មភាពសត្យានុម័តនៃការប្រព្រឹត្តបទល្មើស។

**ឧទាហរណ៍**៖ ចារីបានស្នើសុំភរិយាឱ្យរួមសមគ្គសំវាសជាមួយខ្លួន តែភរិយាពុំព្រមនាំឱ្យចារីកើតកំហឹងហើយ បង្ខិតបង្ខំគំរាមកំហែងជនរងគ្រោះឱ្យរួមភេទជាមួយខ្លួន។

[36] រួមមេថុនកិច្ច មានន័យថារួមសំវាស។

**១.២.៣.៣ កម្មវត្ថុនៃបទល្មើសរំលោភសេពសន្ថវៈ** :

**ក . តាមទស្សនៈទី១** :

កម្មវត្ថុនៃបទល្មើស**រំលោភសេពសន្ថវៈ** គឺជនល្មើសមានចេតនាបំពាននូវច្បាប់ ព្រហ្មទណ្ឌដែលបានកំណត់ទុកថាទង្វើនេះជាបទល្មើស ហើយជនណាដែលប្រព្រឹត្តបំពាន នឹងមានទោសទណ្ឌ។ ទោះបីជាបានដឹងថា ទង្វើបែបនេះត្រូវបានហាមប្រាមដោយច្បាប់ក៏ដោយ ក៏ជនល្មើសមានចេតនាក្នុងការប្រព្រឹត្តផ្ទុយ ដើម្បីឱ្យខូចខាតដល់សណ្តាប់ធ្នាប់ ដែលបានចងក្រងក្នុងច្បាប់នោះទៀត។[37]

**ខ . តាមទស្សនៈទី២** :

ដូចបានបរិយាយក្នុងសេចក្តីផ្តើមពីបទដ្ឋានគតិយុត្តនានា ដែលបានបញ្ញត្តមកដើម្បី ការពារដល់បូរណភាពរាងកាយនៃមនុស្ស ជនល្មើសនៃបទល្មើសរំលោភសេពសន្ថវៈ មានចេតនាយ៉ាងអត្តនោម័ត ក្នុងការបំពានប៉ះពាល់ដល់បូរណភាពនៃរាងកាយ ជាពិសេសផ្នែកផ្លូវភេទនៃជនរងគ្រោះ ពោលគឺកម្មវត្ថុនៃការប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈ គឺផ្លូវភេទនៃជនរងគ្រោះ ឬ បូរណភាពរាងកាយនៃជនរងគ្រោះនោះឯង ដែលជនល្មើស ចង់បំផ្លិចបំផ្លាញ ឬ បង្កឱ្យមាននូវព្យសនកម្ម។

## ១.៣ ទោស និងស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវៈ :

**១.៣.១ ទោស** :

ដូចមានកំណត់នៅក្នុង**កថាខណ្ឌទី២ មាត្រា២៣៩** នៃ**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** ថា៖

***បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ។***

ដូចនេះ កាលណាបើអំពើល្មើសមួយបំពេញគ្រប់ធាតុផ្សំនៃ**បទល្មើសរំលោភសេពសន្ថវៈ**ហើយនោះ អំពើល្មើសនោះ គឺត្រូវបានចោទប្រកាន់ក្នុង**បទរំលោភសេពសន្ថវៈ** ដែលត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌជាការដាក់ពន្ធនាគារតាមស្ថានភាពនៃបទល្មើស ក្នុងដែនកំណត់នៃអតិបរមា និងអប្បបរមានៃទោសពន្ធនាគារដែលបានកំណត់នៅខាងលើ។

**១.៣.២ស្ថានទម្ងន់ទោស** :

**១.៣.២.១ស្ថានទម្ងន់ទោសនៃបទរំលោភសេពសន្ថវៈ**

ស្ថានទម្ងន់ទោសនៃ**បទរំលោភសេពសន្ថវៈ** គឺជាបទល្មើសដែលត្រូវបានច្បាប់កំណត់នូវទណ្ឌកម្មព្រហ្មទណ្ឌ ដែលមានលក្ខណៈធ្ងន់ធ្ងរជាង**បទរំលោភសេពសន្ថវៈ** ក្នុង**មាត្រា ២៣៩** នៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩** ដោយសារតែវាជាប្រភេទបទល្មើស ដែលមានចេតនាទុច្ចរិតធ្ងន់ធ្ងរ[38] និងមានលក្ខណៈហានិភ័យដល់

[37] មេរៀននីតិព្រហ្មទណ្ឌទូទៅ ឯកឧត្តម ហ៊ី សោភា។

[38] នីតិព្រហ្មទណ្ឌទូទៅ សាស្រ្តាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្រ្តាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១២។

សណ្តាប់ធ្នាប់សង្គម សាធារណៈខ្ពស់។ ស្ថានទម្ងន់ទោសនៃ**បទល្មើសរំលោភសេពសន្ថវៈ** នេះមានចែងក្នុង**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩** ចាប់ពី **មាត្រា២៤០** ដល់ **មាត្រា២៤៤**។

**ក . ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬ ទាក់ទងនឹងជនល្មើស**

- **យោងតាម មាត្រា ២៤០:***ទោសដាក់ពន្ធនាគារចាប់ពី ៧ឆ្នាំ ទៅ១៥ឆ្នាំ៖*

- *បទល្មើសប្រព្រឹត្តដោយការប្រើអាវុធ ឬ គំរាមកំហែងនឹងអាវុធ។*
- *បទល្មើសប្រព្រឹត្តដោយការប្រើគ្រឿងញៀន ឬ គ្រប់វិធី ដែលនាំឱ្យជន រងគ្រោះបាត់បង់ស្មារតី ឬ ខ្សោយលទ្ធភាពទប់ទល់។*
- *បុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ។*[39]

**ឧទាហរណ៍៖** វេជ្ជបណ្ឌិត គ្រូបង្រៀន ចៅហ្វាយនាយ ដែលរំលោភសេពសន្ថវៈអ្នកជំងឺរបស់ខ្លួន សិស្សរបស់ខ្លួន ឬ អ្នកធ្វើការនៅក្រោមឱវាទ របស់ខ្លួន។

- *បុគ្គលច្រើនរូបដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត។*
- *ដោយបុគ្គលដែលមានអំណាចលើជនរងគ្រោះ៖*

**ឧទាហរណ៍៖** ឪពុកមា ឪពុកធម៌ ម្តាយចុង ឪពុកចុង...។

  - បុគ្គលដែលមានអំណាចទៅលើជនរងគ្រោះតាមច្បាប់៖ គឺជាជនដែលជាបុព្វញាតិរបស់ជនរងគ្រោះ។
  - បុគ្គលដែលមានអំណាចតាមស្ថានការណ៍ជាក់ស្តែង មានដូចជា ឪពុកមា ម្តាយមីង របស់ជនរងគ្រោះជាដើម។

- **មាត្រា ២៤១:***ទោសដាក់ពន្ធនាគារពី ៧ឆ្នាំ ទៅ ១៥ឆ្នាំ(ទាក់ទងនឹងជនរងគ្រោះ)៖*

- *ជនរងគ្រោះ គឺជាបុគ្គលដែលទន់ខ្សោយពិសេសដោយមូលហេតុនៃអាយុ។ បុគ្គលទាំងនេះ គឺសំដៅទៅលើក្មេងអនីតិជន និងជនចាស់ ជរា។*[40]

**ឧទាហរណ៍៖** ក្មេងអាយុក្រោម១០ឆ្នាំ ចាស់អាយុ៧០ឆ្នាំ។

- *ជនរងគ្រោះ គឺជានារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជនល្មើសបានដឹង។*

[39] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៦ មាត្រា ២៤០។

[40] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៦ មាត្រា ២៤១។

នេះមានន័យថា លុះត្រាតែស្ថានភាពផ្ទៃពោះរបស់ស្ត្រីរងគ្រោះលេចឡើងធំដែលអាចសន្មតយ៉ាងពិតប្រាកដថាជានារីមានផ្ទៃពោះ ហើយជនល្មើសនៅតែមានចេតនាក្នុងការរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ។ មួយវិញទៀត ក្នុងករណីដែលជនល្មើសបានដឹងថាស្ត្រីរងគ្រោះមានគភ៌ហើយ ប៉ុន្តែស្ថានភាពផ្ទៃពោះរបស់ស្ត្រីរងគ្រោះពុំទាន់លេចធំឡើងជាក់ស្តែង ក៏ជាស្ថានទម្ងន់ទោសដែរ។

**ឧទាហរណ៍៖** ជនល្មើសជាអ្នកជិតខាងដែលបានដឹងថានារីរងគ្រោះចាប់ផ្តើមមានផ្ទៃពោះ ឬ ជនល្មើសគឺជាសង្សាររបស់ជនរងគ្រោះដែលបានដឹងថាសង្សាររបស់ខ្លួនមានផ្ទៃពោះហើយនៅតែមានចេតនារំលោភសេពសន្ថវៈនាងទៀត ជាដើម។

- ***បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬ ពិការភាព បើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬ កាលបើជន ល្មើសបានដឹង។***

ភាពទន់ខ្សោយពិសេសដោយមូលហេតុនៃជំងឺគឺសម្តៅទៅលើស្ថាន ភាពនៃជំងឺរបស់ជនរងគ្រោះដែលបណ្តាលឱ្យបាត់បង់ ឬ ថយចុះនូវសមត្ថភាពក្នុងការការពារខ្លួនដូចជាជំងឺស្ពឹកមួយចំហៀងខ្លួនជាដើម។

ផ្ទុយមកវិញ ការបង្ហាញអំពីអំណះអំណាងរបស់ជនរងគ្រោះថាខ្លួន មានជំងឺផ្តាសាយ ឈឺត្រចៀក ឈឺមាត់ នៅពេលដែលជនល្មើស បានរំលោភសេពសន្ថវៈ មិនអាចជាហេតុនៃស្ថានទម្ងន់ទោសរំលោភ សេពសន្ថវៈបានទេ ព្រោះជំងឺទាំងនេះមិនបានធ្វើឱ្យបាត់បង់ ឬ ចុះថមថយនូវសមត្ថភាពក្នុងការការពារខ្លួនឡើយ។

ដូចគ្នានេះដែរ តាមស្មារតីនៃ**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩**បានកំណត់ថា ពិការភាពដែលជាស្ថានទម្ងន់ទោសនេះ ត្រូវតែជាពិការភាពដែលធ្វើឱ្យជនរងគ្រោះបាត់បង់ ឬ ថមថយនូវសមត្ថភាពក្នុងការការពារខ្លួន។ ដូចក្នុងករណី ជនរងគ្រោះពិការដៃម្ខាង ឬ ពិការជើងម្ខាង ជាដើម។

ផ្ទុយមកវិញ ស្ថានភាពដូចជាដាច់ម្រាមដៃមួយ ដាច់ម្រាមជើងមួយ មិនមែនជាស្ថានភាពពិការភាព ដែលនាំឱ្យការរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ មានស្ថានទម្ងន់ទោសនោះទេ ពីព្រោះថាពិការភាព របស់ជនរងគ្រោះមិនបាននាំឱ្យបាត់បង់ ឬ ចុះថមថយនូវសមត្ថភាព ក្នុងការការពារខ្លួនឡើយ។

**មាត្រា ២៤២:** ***ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬ ពិការភាព***

***បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ)ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬ ពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។***[41]

**ឧទាហរណ៍៖** ជនល្មើសបានចាប់រំលោភសេពសន្ថវៈនារីរងគ្រោះ ដោយចាប់សង្កត់ ជើងរបស់នាងទាំងពីរយ៉ាងខ្លាំង បណ្តាលឱ្យបាក់ជើងរបស់នាង។

[41] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៦ មាត្រា ២៤២។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌ កម្រិតទណ្ឌកម្មដោយយោងទៅលើព្យសនកម្មដែលជនរងគ្រោះទទួលហើយ ធ្វើការទម្ងន់ទោស ដោយគិតគូរអំពីលក្ខណៈអចន្ត្រៃយ៍នៃពិការភាព ឬ ការកាត់អវៈយវ ដែលបណ្តាលមកពីអំពើល្មើស។[42]

- មាត្រា ២៤៣៖ *ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬ អំពើឃោរឃៅ បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១០ (ដប់) ឆ្នាំទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬ អំពើឃោរឃៅ។*[43]

**ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទល្មើសរំលោភសេពសន្ថវៈទៅលើជនរងគ្រោះហើយថែមទាំងបានធ្វើទារុណកម្មទៅលើជនរងគ្រោះដែលនាំ ឱ្យជនរងគ្រោះទទួលរងនូវព្យសនកម្មដូចជាមានលក្ខណៈអចិន្ត្រៃយ៍នៃពិការភាព ឬ ការកាត់អវយវៈដែលបណ្តាលមកពីអំពើល្មើស។

- មាត្រា ២៤៤: *បទរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំ ទៅ៣០ ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ដោយគ្មានចេតនាសម្លាប់។*[44]

ឧទាហរណ៍៖ ក្រោយពីទទួលការរំលោភសេពសន្ថវៈដោយសហចារីជាច្រើនដង ធ្វើឱ្យជនរងគ្រោះអស់កម្លាំងយ៉ាងខ្លាំង។ រួមផ្សំនឹងសុខភាពខ្សោយផង ធ្វើឱ្យជនរងគ្រោះបាត់បង់ជីវិតទៅ។[45]

### ១.៣.២.១. ស្ថានទម្ងន់ទោសដោយឡែកចំពោះអំពើរំលោភសម្លាប់

ពាក់ព័ន្ធទៅនឹងការរំលោភសម្លាប់វិញ គេឃើញមាន

- **មាត្រា ២០៥ នៃក្រមព្រហ្មទណ្ឌ ដដែលបានកំណត់ឱ្យជាប់ពន្ធនាគារមួយជីវិត។**

**ជាក់ស្តែង មាត្រានេះបានចែងថា ឃាតកម្មដែលកើតក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬ អំពើរំលោភសេពសន្ថវៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។**[46]

យ៉ាងណា គេអាចចាត់ទុកថាអំពើណាមួយជាបទល្មើសបានលុះត្រាតែអំពើនោះមានគ្រប់ធាតុផ្សំ៣សំខាន់ៗ ដែលច្បាប់បានកំណត់។

---

[42] សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីវិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៥ ទំព័រ ១៨៩ មាត្រា កម ២២២១-៥។

[43] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៦ ដល់ ៧៧ មាត្រា ២៤៣។

[44] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៧ មាត្រា ២៤៤។

[45] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៣-២០១៤។

[46] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៦១ មាត្រា ២០៥។

**ក. ធាតុផ្សំនីត្យានុកូល**

អំពើរំលោភសម្លាប់ត្រូវបានផ្ដន្ទាទោសដោយយោង ទៅតាមក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ត្រង់មាត្រា ២០៥ ដែលចែងថា ឃាតកម្មដែលកើតក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោឃៅ ឬ អំពើរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ លើសពីនេះទៅទៀត មាត្រា ២០៥ គឺជាស្ថានទម្ងន់ទោសនៃបទល្មើសឃាតកម្ម វាមិនមែនជាស្ថានទម្ងន់ទោសនៃបទល្មើសរំលោភសេពសន្ថៈទេ។

**ខ.ធាតុផ្សំសត្យានុម័ត**

- អំពើឃាតកម្មៈ តាមនិយមន័យអំពើឃាតកម្មដោយយោងតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មានន័យថាគ្រប់អំពើសម្លាប់មនុស្សដោយចេតនា ដោយប្រើអាវុធ ឬ មិនប្រើអាវុធ។
- វត្តមាននៃអំពើឃាតកម្មក្នុងពេល ឬ ក្រោយរំលោភសម្លាប់ៈ អំពើឃាតកម្មគឺជាអំពើចម្បង ជនល្មើសមានចេតនាក្នុងការសម្លាប់ជនរងគ្រោះនៅក្នុងពេល ឬ ក្រោយពេលប្រព្រឹត្តអំពើរំលោភសេពសន្ថវៈទៅលើជនរងគ្រោះ។

**គ.ធាតុផ្សំអត្តនោម័ត**

ចេតនាទុច្ចរិតរបស់ជនល្មើស គឺមានចេតនាសម្លាប់ជនរងគ្រោះ ចំណែកឯការរំលោភសេពសន្ថៈវិញ គ្រាន់តែជាមធ្យោបាយ ឬ ជាស្ថានភាពពិសេសដែលបង្កើតឱ្យមានស្ថានទម្ងន់ទោសនៃបទឃាតកម្ម។

អំពើរំលោភ និងសម្លាប់ត្រូវបានធ្វើឡើង ដោយជនល្មើសដែលមានចេតនាទោះបីជាមានមូលហេតុបែបណាក៏ដោយ ហើយជនល្មើសបានដឹងទៀតថា ជនរងគ្រោះពុំមានការព្រមព្រៀងទេ។ គេនឹងមិនអាចជឿបានទេថា ប្រសិនបើជនល្មើសឆ្លើយថា ខ្លួនគ្មានចេតនារំលោភ។ ជាងនេះ ជនល្មើសគឺសម្លាប់ក្នុងពេល ឬ ក្រោយពេលរំលោភ។

## ១.៤ អំពើប៉ុនប៉ងប្រព្រឹត្តបទរំលោភសេពសន្ថវៈ :

**ការប៉ុនប៉ង** បើយោងតាម**ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ មាត្រា ២៧** បានចែងថា *ការប៉ុន ប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្ដន្ទាទោស បាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញៈ*

- *ចារីបានចាប់ផ្ដើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង*
- *ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬ អាក់ ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន។*

*អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ។ ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ។*[47]

ដូចបានឃើញក្នុងនិយមន័យនៃ ការប៉ុនប៉ងមកយើងអាចយល់បានថា ការប៉ុនប៉ង គឺជាការចាប់ផ្តើមប្រព្រឹត្តបទល្មើស ឬ ជាការចាប់លេចឡើងនូវធាតុសត្យានុម័តនៃបទល្មើសតាមរយៈសកម្មភាពរបស់ចារី ហើយចារីទៀតសោត ក៏ពុំបានបញ្ឈប់នូវទង្វើទុច្ចរិត ខ្លួនដោយឆន្ទៈភ្ញាក់រលឹកខ្លួនឯងទេ តែត្រូវបានបញ្ឈប់ដោយឥទ្ធិពលក្រៅឆន្ទៈដូចជា ករណីជនល្មើសទើបចាប់ផ្តើមប្រព្រឹត្តបទល្មើស ហើយត្រូវបានសមត្ថកិច្ចបង្ក្រាបតាំងពីពេលដំបូងនោះ។ ផ្ទុយមកវិញ ការរៀបចំបម្រុងទុក តែពុំទាន់បានចាប់ផ្តើមសកម្មភាពទាំងឡាយណាដែលមានគោលបំណងដោយផ្ទាល់ក្នុងការប្រព្រឹត្តបទល្មើសទេនោះ គេមិនរាប់ថាជាការចាប់ផ្តើមអនុវត្តទេ ដូចករណីដែលជនល្មើសត្រៀមឧបករណ៍គាស់ទ្វារ បម្រុងថានឹងទៅគាស់ទ្វារផ្ទះគេ តែជនល្មើសពុំទាន់មានសកម្មភាពអ្វីទេ ពោលគឺគ្រាន់តែរៀបចំតែការលួច ចូលទៅគាស់ផ្ទះនោះពុំទាន់បានធ្វើនៅឡើយទេ ហើយឧបករណ៍ទាំងនោះនៅក្នុងផ្ទះជន ល្មើសនៅឡើយ។ ចំពោះបទលហុការប៉ុនប៉ងប្រព្រឹត្តបទនេះ ពុំមានទោសនោះទេ។

ដោយឡែកចំពោះការប៉ុនប៉ងប្រព្រឹត្ត**បទរំលោភសេពសន្ថវៈ** យើងអាចសម្គាល់បានដោយនៅពេល ដែលមានការរារាំងពីឥទ្ធិពលខាងក្រៅបញ្ឈប់នូវសកម្មភាពទុច្ចរិតនៃជនល្មើសនោះ គេអាចក្តាប់បាននូវភស្តុតាងដូចជា ឃើញជនល្មើសចាប់ផ្តើមប្រព្រឹត្តនូវសកម្មភាពនានា ដែលបង្កនូវលទ្ធភាពក្នុងការបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ ទៅលើជនរងគ្រោះ ដូចយ៉ាង ជនល្មើសកំពុងតែនឹងពាក់នូវស្រោមអនាម័យ ជនល្មើសបានយកឧបករណ៍ដូចជាលិង្គសិប្បនិម្មិត ដំបង បម្រុងនឹងបញ្ចូលទៅលើជនរងគ្រោះ[48] ឬ ការណ៍ដែលជនល្មើសបម្រុងបញ្ចូលអង្គជាត ឬ ឧបករណ៍ផ្សេងៗ តែពុំទាន់ដល់នូវទីជម្រៅនៅឡើយ ដូចជាការយកអង្គជាតទៅញ្ញល់នៅលើអង្គជាតនៃជនរងគ្រោះជាដើម។ ក្នុងករណីប៉ុនប៉ងនេះ បទល្មើសទោះបីជាពុំទាន់បានសម្រេច តែព្យសនកម្មបានកើតមានឡើងហើយ ដូចជាព្យសនកម្មផ្លូវចិត្តជាដើម។

បញ្ហាដែលចោទឡើងនៅពេលដែលកំណត់ថាសកម្មភាពរបស់ជនល្មើសជាការប៉ុនប៉ងរំលោភសេពសន្ថវៈនោះគឺជាការពុំដាច់ស្រេចរវាង**បទល្មើសប្រទូស្តកេរខ្មាស** និងសកម្មភាព**ប៉ុនប៉ងរំលោភសេពសន្ថវៈ** ព្រោះយើងពិបាកដឹងថា **តើជនល្មើសមានចេតនា រំលោភសេពសន្ថវៈ ឬ គ្រាន់តែប្រទូស្តកេរខ្មាស?**ហើយម្យ៉ាងទៀត ករណីទាំងពីរ គឺពុំទាន់បានដល់នូវទីជម្រៅដូចគ្នា។ ដំណោះស្រាយបញ្ហានេះ គឺមានតែពឹងផ្អែកលើភស្តុតាងដែលប្រមូលបានក្នុងករណីជាក់ស្តែង ដើម្បីរួមបញ្ជាក់ពីករណីនេះឱ្យបានច្បាស់លាស់។

[47] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១ ដល់ ១២ មាត្រា ៤២។
[48] នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ កើត រិទ្ធ ២០១៥។

# ជំពូកទី២
# បទល្មើសបំពានផ្លូវភេទផ្សេងទៀត

## ២.១ អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ:

***ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង១៥(ដប់ប្រាំ)ឆ្នាំ ត្រូវផ្តន្ទា ទោសដាក់ពន្ធនាគារពី ៥(ប្រាំ) ដល់ ១០(ដប់) ឆ្នាំ។***[49]

ចំពោះបទល្មើសនេះ គឺសំដៅដល់ការរួមសេវនកិច្ច[50]ជាមួយបុគ្គលដែលពុំទាន់ដល់នូវនីតិភាពនៃការរួមភេទដូចមានកំណត់ក្នុង **ច្បាប់ព្រហ្មទណ្ឌឆ្នាំ២០០៩ កថាខណ្ឌទី៣ មាត្រា២៣៩** ដែលថានីតិភាពនៃការរួមភេទគឺ១៥ឆ្នាំ។ ដូចនេះ ការរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម១៥ឆ្នាំ ទោះបីគ្មានធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ និងទោះបីអនីតិជននោះព្រមព្រៀងក្តី ក៏ជាបទល្មើសមួយដែរ ព្រោះឆន្ទៈនៃអនីតិជននោះជាឆន្ទៈអសុពលានុភាពគតិយុត្ត។

មាត្រានេះ ក៏ត្រូវអនុវត្តសូម្បីតែក្នុងករណីដែលអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញ ក្នុងការរួមភេទបែបនេះ ឬ មិនបានតទល់ក្នុងវិធីណាមួយក៏ដោយ។ ដោយសារតែ ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តល់ឱ្យអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ នូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ ការព្រមព្រៀងបែបណាមួយក៏ដោយមិនមែនជា " ការយល់ព្រម " ទេ។

ប្រសិនបើ ជនល្មើសបានរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ តាមមធ្យោបាយប្រើកម្លាំង អំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ បំភ័យជននោះគួរត្រូវចោទប្រកាន់ និងផ្តន្ទាទោសពីបទរំលោភសេពសន្ថវៈដោយមានស្ថានទម្ងន់ យោងតាមមាត្រា ២៤១ (ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ) នៃក្រមព្រហ្មទណ្ឌជាជាងត្រូវចោទប្រកាន់ និងផ្តន្ទាទោស យោងតាមមាត្រានេះ។ (សូមមើលក្រមព្រហ្មទណ្ឌ គន្ថីទី ២ មាតិកាទី ២ ជំពូកទី ៣ ផ្នែកទី ១ " រំលោភសេពសន្ថវៈ " )[51]។

ប្រសិនបើជនល្មើសមានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំតាមរយៈផ្តល់ ឬ សន្យាផ្តល់វត្ថុមានតម្លៃអ្វីមួយ ទៅដល់អនីតិជន ឬ តតិយជន ជននោះគួរតែត្រូវចោទប្រកាន់ និងផ្តន្ទា

[49] មាត្រា ៤២ នៃច្បាប់ស្តីពី ការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ២០០៨។
[50] រួមសេវនកិច្ច មានន័យថា រួមសំវាស។
[51] យោងតាមមាត្រា ២៣៩ និងមាត្រា ២៤៩ នៃក្រមព្រហ្មទណ្ឌ "បទរំលោភសេពសន្ថវៈ"។

ទោស ពីបទល្មើសទិញពេស្យាចារកុមារ យោងតាមមាត្រា ៣៤ បន្ថែមទៅនឹងការចោទប្រកាន់ នឹងផ្តន្ទាទោស ដែលអាចមានយោងតាមមាត្រានេះ។

ដូចមានចែងក្នុងមាត្រា ៧ ( និយមន័យនៃអនីតិជន ) នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ជនណាដែលរក្សាទុកអនីតិជននៅក្រោមការគ្រប់គ្រង ឬ ត្រួតពិនិត្យរបស់ខ្លួន នឹងត្រូវចាត់ទុកថាបានដឹងពីអាយុរបស់អនីតិជននោះ លើកលែងតែជននោះបង្ហាញឱ្យឃើញថា ខ្លួនមានការជឿជាក់ដោយសមហេតុផលថា អនីតិជននោះមានអាយុ ១៨ ឆ្នាំ ឬ ច្រើនជាង ១៨ ឆ្នាំ។ ការសន្មត់ថាបានដឹង នេះក៏អនុវត្តចំពោះសំនួរដែលទាក់ទងនឹងអាយុនៃការយល់ព្រមរួមភេទ។

**ឧទាហរណ៍** ៖ ក្នុងករណីដែលជនណាម្នាក់ មានការគ្រប់គ្រង ឬ ត្រួតពិនិត្យទៅលើអនីតិជនមានទំនាក់ទំនងផ្លូវភេទជាមួយអនីតិជននោះ មាត្រា ៧ ចាត់ទុកថាជននោះបានដឹងពីអាយុរបស់អនីតិជន និងដូច្នេះហើយជននោះមិនអាចងាយស្រួល ទាមទារការការពារដែលថាគាត់មិនបានដឹងពីអាយុរបស់អនីតិជន ថាមានអាយុក្រោម ១៥ ឆ្នាំទេ។

**ឧទាហរណ៍**៖ កុមារម្នាក់អាយុ ១៦ ឆ្នាំ និងកុមារម្នាក់អាយុ ១៤ ឆ្នាំមានទំនាក់ទំនងស្នេហាជាមួយគ្នា ហើយបានព្រមព្រៀងរួមភេទជាមួយគ្នាដោយការប្រើកម្លាំងបង្ខិតបង្ខំ ឬ បង្ករបួសស្នាម ឬ បំពានដោយអាងអំណាច។

នៅក្នុងករណីឧទាហរណ៍ខាងលើ ដោយពិចារណាទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជនដូចដែលមានចែងនៅក្នុងមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌ ព្រះរាជអាជ្ញា ឬ តុលាការអាចធ្វើការចោទប្រកាន់ ឬ មិនចោទប្រកាន់ ឬ អនុវត្តន៍វិធានការផ្សេងៗទៅលើអនីតិជន។ ក្នុងករណីមានការសម្រេចធ្វើការចោទប្រកាន់ទៅលើកុមារ តុលាការគប្បីពិចារណាអនុវត្តន៍វិធានការផ្សេងៗដើម្បីជៀសវាងការឃុំខ្លួនបណ្តោះអាសន្ន និងការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ យ៉ាងហោចណាស់ត្រូវពិចារណាអំពីស្ថានសម្រាលទោស ដូចមានចែងនៅ ក្នុងមាត្រា ៩៦នៃ ក្រមព្រហ្មទណ្ឌ។

**"ការរួមភេទ"**

ពាក្យថា "ការរួមភេទ" មានន័យថាជាការដាក់បញ្ចូលកេរភេទ ទៅក្នុងកេរភេទ មាត់ ឬ រន្ធគូទ របស់ជនម្នាក់ទៀត ឬ ការដាក់បញ្ចូលសម្ភារៈ ឬ ឧបករណ៍ ទៅក្នុងកេរភេទ របស់ជនម្នាក់ទៀត។ ការរួមភេទអាចកើតឡើងរវាងមនុស្សពីរនាក់ ឬ ច្រើនជាងពីរនាក់ដែលមានភេទដូចគ្នា ឬ ខុសគ្នា។ និយមន័យនេះ ស្របទៅនឹងសេចក្តីណែនាំរបស់ក្រសួងយុត្តិធម៌ លេខ ០១ កយ.សណន/០៩ ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០៩។

ពាក្យថា " ឧបករណ៍ " ត្រូវគេយល់ថា រាប់បញ្ចូលទាំងម្រាមដៃ ឬ ផ្នែកដទៃទៀត នៃរាងកាយមនុស្ស។

ជាទូទៅពាក្យថា " កេរភេទ " ត្រូវបានកំណត់ថាជាលិង្គ ឬ រន្ធយោនី។ ប៉ុន្តែដើម្បីពង្រឹងការការពារដល់ជនរងគ្រោះ នៅក្នុងច្បាប់នេះ ពាក្យថាកេរភេទ ត្រូវបានគេយល់ថាជាលិង្គ ឬ រន្ធគូទ។

ពាក្យថា " អំពើរួមភេទ " មានរាប់បញ្ចូលការរួមភេទតាមរន្ធយោនី ការរួមភេទតាមរន្ធគូទ និងការរួមភេទតាមមាត់[52]។

ជនល្មើសអាចត្រូវផ្តន្ទាទោសយោងតាមមាត្រាដោយមិនគិតថា តើជនល្មើសគឺជាជនដែលស៊កបញ្ចូលមកលើជនរងគ្រោះ ឬ ជនដែលត្រូវជនរងគ្រោះស៊កបញ្ចូល។

## ២ .២.បទប្រទូស្តកេរខ្មាស:

*គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកផ្សេងទៀត របស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬ បង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬ ទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើសគឺជាអំពើប្រទូស្តកេរខ្មាស។*

*អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ) ឆ្នាំទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ទៅ៦.០០០.០០០ (ប្រាំមួយលាន) រៀល។*[53]

ក្នុងបទល្មើសនេះ ភាពខុសគ្នាជាមួយនឹង**បទរំលោភសេពសន្ថវៈ** គឺពុំបានដល់ទីជម្រៅដូចការរំលោភសេពសន្ថវៈដែលជាការបញ្ចូលនោះទេ ពោលគឺក្នុង**បទប្រទូស្តកេរខ្មាស**នេះ ចារីគ្រាន់តែប៉ះពាល់ ស្ទាប អង្អែល តែផ្នែកខាងក្រៅនៃកេរភេទ(រាប់ទាំងអង្គជាត និងផ្នែកខ្មាសអៀននៃភេទផ្សេងៗទៀតដូចជាសុដន់ជាដើម) នៃជនរងគ្រោះ ឬ ឱ្យជនរងគ្រោះធ្វើមកលើខ្លួន ឬ តតិយបុគ្គលដើម្បីធ្វើឱ្យរំជួល ឬរីករាយនូវចំណង់ផ្លូវភេទនៃជន ល្មើស ឬ តតិយបុគ្គល។ នៅក្នុងបទល្មើសនេះ ក៏អវត្តមាននូវការព្រមព្រៀងរបស់ជនរងគ្រោះដូចទៅនឹងករណីនៃ**បទរំលោភសេពសន្ថវៈ**ផងដែរ គឺជនរងគ្រោះពុំស្ម័គ្រផងទេ។

### ២.១.២. និយមន័យនៃបទប្រទូសកេរខ្មាស

**អំពើប្រទូសកេរខ្មាស** គឺគ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនោះមិនស្ម័គ្រផងទេ ឬ បង្ខំបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណងផ្លូវភេទរបស់ជនល្មើស។

---

[52] ការរួមភេទតាមមាត់ ត្រូវចាត់ទុកថាជា " ការរួមភេទ " ដែរ សូម្បីតែនៅពេលដែលធ្វើឡើងទៅលើស្ត្រី និងមិនមានការស៊កបញ្ចូល ទៅក្នុងរន្ធយោនី ឬ រន្ធគូទក៏ដោយ។

[53] មាត្រា ២៤៦ នៃ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៨។

**២.២.២.ធាតុផ្សំបទល្មើស**

**២.២.២.១.ធាតុនីត្យានុកូល**

មាត្រា ២៤៦. បទប្រទូស្តកេរខ្មាស

**អំពើប្រទូស្តកេរខ្មាស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។**

**២.២.២.២. ធាតុសត្យានុម័ត**

- រាល់អំពើប្រព្រឹត្តដោយចេតនាដើម្បី ប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬ ផ្នែកភេទរបស់បុគ្គលដទៃផ្ទុយពីឆន្ទៈជនរងគ្រោះ ឬ បង្ខំជនរងគ្រោះឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬ ទៅលើតតិយបុគ្គល។
- ខ្វះអវត្តមានឆន្ទៈក្នុងការព្រមព្រៀងរបស់ជនរងគ្រោះ។
- ក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

**២.២.២.៣. ធាតុអត្តនោម័ត**

ជនល្មើសយល់ដឹងថា អំពើនោះជាអំពើអសីលធម៌ ប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ ប៉ុន្តែជនល្មើសនៅតែមានចេតនាប្រព្រឹត្តដើម្បីធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ខ្លួន។

## ២.៣ បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង១៥ឆ្នាំ:

*អំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជន ក្នុងគោលបំណងធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ជន ល្មើស។*

*ជនណាដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុតិចជាង១៥(ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ) ឆ្នាំទៅ ៣(បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។*[54]

**អំពើអាស** មានធាតុសត្យានុម័តពុំខុសពី**អំពើប្រទូស្តកេរខ្មាស**ទេ តែលក្ខខណ្ឌនៃការ ព្រមព្រៀងពុំដូចគ្នាទេ ពោលគឺអំពើអាស មិនកំណត់នូវអវត្តមាននៃការព្រមព្រៀងទេ គឺវិសាលភាពនេះ អាចឱ្យគេទាញបានទាំងព្រមព្រៀង និងមិនព្រមព្រៀង នាំឱ្យគេសន្មត ថាអំពើអាសមានលក្ខខណ្ឌទូលាយជាងអំពើប្រទូស្តកេខ្មាស ដែលកំណត់ពីអវត្តមាននៃ ការព្រមព្រៀង គឺជនរងគ្រោះពុំស្ម័គ្រព្រមជាមួយសកម្មភាពរបស់ជនល្មើសឡើយ។

[54] មាត្រា ៣៤១ នៃក្រមព្រហ្មទណ្ឌ២០០៩ និងមាត្រា ៤៣ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើ ធ្វើអាជីវកម្មផ្លូវភេទ ២០០៨។

ដោយយកគោលការណ៍ **នីត្យានុកូលភាពនៃការរួមភេទ** ដែលតម្រូវឱ្យមានអាយុចាប់ ពី១៥ឆ្នាំឡើងទៅ គឺអំពើអាសនេះ ទោះជនរងគ្រោះដែលមានអាយុក្រោម១៥ឆ្នាំ ព្រមព្រៀងនឹងជនល្មើសក៏ដោយ ក៏នៅតែជាបទល្មើសព្រហ្មទណ្ឌដដែល។ បញ្ញត្តិនេះ គឺមិន ខុសពីបញ្ញត្តិក្នុង**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មាត្រា ៤២** នោះទេ គឺមានគោលបំណងការពារនូវជនរងគ្រោះដែលមានអាយុក្រោម១៥ ឆ្នាំ ដែលមិនសូវមានការយល់ដឹងពីផ្លូវភេទនោះ ពីការសម្ដែងឆន្ទៈដោយខ្វះការពិចារណា និងយល់ដឹង។

ដោយយោងតាមមាត្រា៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានកំណត់និយមន័យ អំពើអាស ( ការប៉ះពាល់កេរភេទ ដែលមិនឈានដល់កំរិត ការរួមភេទ ដូចមានការកំណត់និយមន័យ ក្នុងមាត្រា ៤២ ) និងផ្តន្ទាទោស ជនណា ( បុរស ឬ ស្ត្រី ) ដែលចូលរួមប្រព្រឹត្តអំពើអាសទៅលើ អនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ។

កត់សំគាល់ថាមាត្រា ៤៣ កថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនេះ ដូចគ្នានឹងបទប្បញ្ញត្តិនៃមាត្រា ៣៤១ នៃក្រមព្រហ្មទណ្ឌ។

មាត្រា ៣៤១ "បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ" នៃក្រមព្រហ្មទណ្ឌ ដែលចែងពីផ្តន្ទាទោស ដាល់ពន្ធនាគារដូចគ្នាពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យ ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល។

ទោសនេះនឹងត្រូវកើនពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន)រៀល ក្នុងករណីមានស្ថានទម្ងន់ទោសដូចមាន រៀបរាប់នៅក្នុងមាត្រា ៣៤២ (ស្ថានទម្ងន់ទោស) នៃក្រមព្រហ្មទណ្ឌ។

មាត្រានេះ ត្រូវអនុវត្តសូម្បីតែក្នុងករណី ដែលអនីតិជនដែលមានអាយុក្រោម ១៥ ឆ្នាំ បានយល់ព្រមយ៉ាងពេញលេញចំពោះការប៉ះពាល់បែបនេះ ឬ មិនបានទប់ទល់ក្នុងវិធីណាមួយក៏ដោយ។ ដោយសារតែច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ មិនបានផ្តល់ឱ្យអនីតិជន ដែលមានអាយុក្រោម ១៥ ឆ្នាំនូវសមត្ថភាពក្នុងការយល់ព្រមរួមភេទ ក្នុងន័យច្បាប់ ការព្រមព្រៀងបែបណាមួយក៏ដោយ មិនមែនជា " ការយល់ព្រម " ទេ។

**" អំពើអាសនៅក្នុងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទមានន័យថា "**

មាត្រានេះ កំណត់និយមន័យអំពើអាសក្នុងវិធីជាច្រើន ដែលមានការពិភាក្សាដូចខាងក្រោម។ ទោះជាយ៉ាងណាក៏ដោយ ជាការសំខាន់គួរចងចាំថា ដើម្បីក្លាយជាអំពើអាស សកម្មភាពនោះត្រូវតែអនុវត្តដោយមានចេតនាធ្វើឱ្យរំជួល ឬ រំភើបដល់ចំណង់ខាងផ្លូវភេទ របស់អ្នកប្រព្រឹត្ត។

**" អំពើប៉ះពាល់ "**

ពាក្យថា " អំពើអាស " មានរាប់បញ្ចូល ការប៉ះពាល់ណាមួយ រវាងផ្នែកនៃរូបកាយណាមួយ របស់ជនណាម្នាក់ ទៅនឹងកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ នៅពេលដែលធ្វើឡើងមានចេតនា ធ្វើឱ្យរំជួល ឬ រំភើបដល់ចំណង់ខាងផ្លូវភេទ របស់អ្នកប្រព្រឹត្ត។

" **ការប៉ះ** " រួមមាន ទម្រង់ណាមួយនៃការប៉ះពាល់រូបកាយ ដែលរួមមានជាអាទិ៍ ការត្រដុស ការបរបោស អង្អែល ការថើប ឬ ប្រភេទនៃការប៉ះពាល់ផ្សេងទៀត។

ការប៉ះពាល់ មានរាប់បញ្ចូលការប៉ះដោយផ្ទាល់ ( ស្បែកទល់នឹងស្បែក ) ជាមួយ កេរភេទ ឬ ផ្នែកភេទផ្សេងទៀត ព្រមទាំងការប៉ះកេរភេទ ឬ ផ្នែកភេទ ឬ ផ្នែកភេទផ្សេងទៀតលើ ឬ តាមរយៈសំលៀកបំពាក់ផងដែរ។

**" អំពើនៃ...បង្ហាញឱ្យឃើញ... "**

ពាក្យថា " អំពើអាស " ក៏រាប់បញ្ចូល អំពើណាមួយដែលប្រព្រឹត្តដោយជនណាម្នាក់ បង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ នៅពេលដែលធ្វើឡើងមានចេតនាធ្វើឱ្យរំជួល ឬ រំភើបដល់ចំណង់ខាងផ្លូវភេទ របស់អ្នកប្រព្រឹត្ត។

" ការបង្ហាញឱ្យឃើញ " មានន័យថា ជាការដោះសំលៀកបំពាក់ ឬ វត្ថុបិទបាំងផ្សេងទៀតចេញ ដើម្បីឱ្យជនណាម្នាក់ ( អ្នកប្រព្រឹត្ត ឬ ជនដទៃ ) អាចមើលឃើញ កេរភេទ ឬ ផ្នែកភេទផ្សេងទៀត។

ការបង្ហាញឱ្យឃើញ ក៏រាប់បញ្ចូលស្ថានការណ៍ដែលអ្នកប្រព្រឹត្តដោះសំលៀកបំពាក់ ឬ វត្ថុបិទបាំងរបស់ជនដទៃ ឬ ក្នុងករណីដែលអ្នកប្រព្រឹត្តបញ្ជា ឬ អូសទាញជនដទៃ ឱ្យដោះសំលៀកបំពាក់របស់ខ្លួន ឬ របស់តតិយសជន។

**"....ក្នុងចេតនាធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទ របស់ជនល្មើស "**

ដើម្បីឱ្យទទួលការផ្តន្ទាទោស តាមមាត្រានេះ ជនល្មើសត្រូវតែបានប្រព្រឹត្តអំពើប៉ះពាល់ ឬ បង្ហាញឱ្យឃើញ ឬ ឱ្យជនម្នាក់ផ្សេងទៀត ប៉ះពាល់ ឬ បង្ហាញឱ្យឃើញ ក្នុងគោលដៅធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទ របស់ខ្លួន។ មិនសំខាន់ទេ ទោះបីជាវិធីមួយណាក៏ដោយ ដែលជនល្មើសព្យាយាមប្រើដើម្បីធ្វើឱ្យរំជួល ឬ រីករាយដល់ចំណង់ផ្លូវភេទរបស់ខ្លួន។ វិធីទាំងនេះ អាចមានដូចជា ប្រើសកម្មភាពផ្ទាល់ខ្លួនទៅលើជនរងគ្រោះ ឱ្យជនរងគ្រោះ ឱ្យជនរងគ្រោះធ្វើអំពើមកលើខ្លួន ឬ ទៅលើតតិយជន ឬ ឱ្យតតិយជនធ្វើអំពើមកលើជនរងគ្រោះ។

## ២.៤. បទបង្ហាញកេរភេទ:

*អំពើបង្ហាញកេរភេទ ដែលនាំអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែល សាធារណជនអាចមើលឃើញត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ថ្ងៃទៅ ៣(បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ៥០០.០០០(ប្រាំសែន) រៀល។*[55]

**ការបង្ហាញកេរភេទ** គឺបញ្ចូលទាំងការបង្ហាញអង្គជាត និងកន្លែងអាម៉ាស់នៃភេទ ដូចជាសុដន់ជាដើម ឱ្យសាធារណជនមើលឃើញ នៅ**កន្លែងសាធារណៈ**។ ពាក្យថា **កន្លែងសាធារណៈ** នេះមានវិសាលភាពនៃន័យទូលាយណាស់ តែយើងអាចយល់បានថា ជាកន្លែងដែលអ្នកផងចេញចូលដោយសេរី ផ្ទុយពីទី**កន្លែងឯកជន**។ ដូចនេះ ការបង្ហាញនូវកេរភេទ ដែលជាកម្មវត្ថុនៃបទល្មើសព្រហ្មទណ្ឌ ដាច់ខាតត្រូវតែជាការបង្ហាញនៅទីកន្លែងសាធារណៈ ដូចជាផ្សារសួនច្បារសាធារណៈ ផ្លូវសាធារណៈជាដើម។ ដោយឡែកចំពោះករណីនៅក្នុងកន្លែងឯកជន ហើយកន្លែងនោះមានប្រហោង ឬ ចន្លោះដែលអាចឱ្យអ្នកដទៃមើលពីក្រៅមកឃើញកេរភេទបាននោះ ពុំមែនជា**បទល្មើសបង្ហាញកេរភេទ** នោះទេ។ ឧទាហរណ៍ តួយ៉ាងបុរស **ក** បានស្រាតសម្លៀកបំពាក់បម្រុងនឹងចូលងូតទឹក តែចៃដន្យបង្អួចបន្ទប់របស់គាត់ត្រូវខ្យល់បក់ឱ្យរបើក ដែលនាំឱ្យនារី **ខ** រស់នៅផ្ទះក្បែរនោះមើលឃើញ។ ក្នុងករណីនេះ បុរស **ក** គាត់ពុំត្រូវបានគេចាត់ទុកថាប្រព្រឹត្តបទល្មើស ព្រហ្មទណ្ឌ **បទបង្ហាញកេរភេទ** ទេ។

### ២.៤.១. ធាតុផ្សំបទល្មើស

#### ២.៤.១.១. ធាតុនីត្យានុកូល

**មាត្រា ២៤៩.បទបង្ហាញកេរភេទ**

**អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែល សាធារណជនអាចមើលឃើញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ថ្ងៃទៅ ៣ (បី)ខែ និងពិន័យជាប្រាក់ពី ១០០.០០០(មួយសែន)រៀលទៅ ៥០០.០០០(ប្រាំសែន)រៀល។**

#### ២.៤.១.២. ធាតុសត្យានុម័ត

- អំពើបង្ហាញកេរភេទខ្លួនឯង
- នៅទីសាធារណៈ
- មានចេតនាឱ្យសាធារណៈជនមើល។

#### ២.៤.១.៣. ធាតុអត្តនោម័ត

មានឆន្ទៈចង់ឱ្យអ្នកដទៃមើលឃើញកេរភេទរបស់ខ្លួន។

[55] មាត្រា ២៤៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៩។

## ២.៥ បទរុករកួនខាងផ្លូវភេទ:

*អំពើរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ។*

*អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៥០០.០០០ (ប្រាំសែន) រៀល។[56]*

**អំពើរុកកួនខាងផ្លូវភេទ** ជាការរងការរំខានផ្នែកផ្លូវចិត្តរបស់ជនរងគ្រោះ ពីការគាបសង្កត់ជាដដែលៗរបស់ចារីដែលជាអ្នកមានអំណាចមុខងារដូចជាគ្រូពេទ្យ ចៅហ្វាយនាយ គ្រូបង្រៀន ជាដើម ដើម្បីស្នើសុំនូវមេថុនគ្រោះ[57] ឬ ការអនុគ្រោះខាងផ្លូវភេទ ដូចជាការស្នើសុំឱ្យរួមសេវនកិច្ចជាមួយចារី ឬ ស្ទាបអង្អែលកេរភេទចារីជាដើម។ គួរកត់សម្គាល់ផងដែរ អំពើរុកកួននេះ គ្រាន់តែជាសំណើដែលគាបសង្កត់រំខានផ្លូវចិត្តជនរងគ្រោះប៉ុណ្ណោះ ពុំមែន ជាការប្រព្រឹត្តនូវសកម្មភាពផ្លូវភេទដូច**ការរំលោភសេពសន្ថវៈ** ឬ **ប្រទូស្តកេរខ្មាស** នោះទេ។ ជាងនេះទៅទៀត សំណើស្នើនូវការអនុគ្រោះផ្លូវភេទនេះ ត្រូវប្រព្រឹត្តឡើងជាដដែលៗ ពោលគឺច្រើនជាងមួយដង និងជារឿយៗ។ ឧទាហរណ៍ គ្រូបង្រៀនម្នាក់បានដាក់កំហិតថាឱ្យ សិស្សស្រី **ក** រួមភេទជាមួយខ្លួន បើពុំដូច្នោះទេ ខ្លួននឹងទម្លាក់សិស្សស្រីនោះ មិនឱ្យឡើងថ្នាក់បានឡើយ។ ការដាក់កំហិតនេះ គ្រូនោះតែងតែនិយាយដាក់សិស្សស្រីនោះរាល់ ពេលម៉ោងចេញទៅផ្ទះជារឿយៗ។ សកម្មភាពដាក់សម្ពាធបែបនេះ ជាកម្មវត្ថុនៃ **បទរុកកួនខាងផ្លូវភេទ**។ ទោះបីគ្រូនោះពុំទាន់បានប្រព្រឹត្តនូវសកម្មភាពរួមភេទជាមួយ សិស្សស្រីនោះក៏ដោយ ក៏នៅតែជាបទល្មើសព្រហ្មទណ្ឌដែរ។

### ២.៥.១ ធាតុផ្សំបទល្មើស

#### ២.៥.១.១ ធាតុនីត្យានុកូល

មាត្រា ២៥០បទរុកកួនខាងផ្លូវភេទ .

**អំពើរុកកួនខាងផ្លូវភេទគឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយ ម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួល ការអនុគ្រោះខាងផ្លូវភេទ ។**

**អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធធានាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និង ពិន័យជាប្រាក់ពី ១០០,០០០ (មួយសែន) រៀល ទៅ ៥០០,០០០ (ប្រាំសែន) រៀល។**

[56] មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ៧៩។
[57] មេថុនគ្រោះ មានន័យថា ការអនុគ្រោះផ្លូវភេទ។

**២.៥.១.២ ធាតុសត្យានុម័ត**

- អំពើៈ របស់បុគ្គលដែលមានអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ
- សកម្មភាពបុគ្គលនោះរំលោភអំណាចរបស់ខ្លួន :
- មធ្យោបាយៈ រុកកួនម្តងហើយម្តងទៀតតាមរយៈ ការគា(ទាមទារ)បសង្កត់នៃមុខងារទៅលើជនក្រោមអំណាចខ្លួន
- គោលបំណងទទួលបានការអនុគ្រោះខាងផ្លូវភេទ :។

**២.៥.១.៣ ធាតុអត្ថនោម័ត**

មានចេតនា ក្នុងការរុកកួន ដើម្បីជំរិតទារយកឱ្យបានការអនុគ្រោះខាងផ្លូវភេទ។

## ២.៦ បទរួមភេទជាមួយអនីតិជន ដោយបុព្វញាតិ

**អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើចារីជាបុព្វញាតិរបស់អនីតិជននោះ។** [58]

ចំពោះបទល្មើសនេះគឺសំដៅដល់ការរួមសេវនកិច្ចរវាង**បុព្វញាតិ** ជាមួយបុគ្គលដែលជា**អនីតិជនអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ**ដូចមានកំណត់ក្នុង**ច្បាប់ព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា ៣៥១ កាលបើចារីជាបុព្វញាតិរបស់អនីតិជននោះ**។ ដូចនេះការរួមភេទជាមួយអនីតិជនដែលមានអាយុក្រោម១៨ឆ្នាំទោះបីគ្មានធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ និងទោះបីអនីតិជននោះព្រមព្រៀងក្តី ឬ មិនព្រមព្រៀងក្តី កាលណាបើកើតមានការរួមភេទរវាងអនីតិជន និងបុព្វញាតិរបស់អនីតិជននោះ វាគឺជាបទល្មើស។

ពាក្យពិបាកៈ

- បុព្វញាតិៈ ជនដែលស្ថិតក្នុងលំដាប់ថ្នាក់ញាតិខ្ពស់ជាងខ្លួន។[59]
- បច្ឆាញាតិៈ ញាតិក្រោយ ឬ ជនដែលកើតពីជនមួយពួកទៀត។[60]

ក្នុងជីវភាពសង្គមខ្មែរផ្តន្ទាទោសបទល្មើសនេះដោយទោសឧក្រិដ្ឋ មាត្រានេះពុំកំណត់ថាជាបទល្មើសទេក្នុងករណីបច្ឆាញាតិជានីតិជន។

## ២.៧. បទរួមភេទរវាងញាតិលោហិត ឬ ញាតិពន្ធ

**អំពើរួមភេទរវាងញាតិលោហិត ញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០,០០០ (មួយសែន)រៀល ទៅ ២,០០០,០០០ (ពីរលាន) រៀល។**[61]

[58] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៥ មាត្រា ៣៥១។

[59] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ឆ្នាំ២០១៧ ភាគ៣ ទំព័រ ២។

[60] សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណី ឆ្នាំ២០១៧ ភាគ៣ ទំព័រ ២។

[61] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពដោយក្រសួងយុត្តិធម៌ ឆ្នាំ២០១១ ទំព័រ ១១៥ មាត្រា ៣៥២។

មិនត្រូវចាត់ទុកជាបទល្មើសតាមកថាខណ្ឌទី ១ ខាងលើទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមភេទជាមួយសាខាញាតិពន្ធ ថ្នាក់ទី ២ ឬ ថ្នាក់ទី ៣។

ចំពោះបទល្មើសនេះគឺសំដៅដល់ការរួមសេវនកិច្ចរវាង **ញាតិលោហិត** ជាមួយបុគ្គលដែលជា **ញាតិពន្ធក្នុង៣(បី)ថ្នាក់**ដូចមានកំណត់ក្នុង**ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មាត្រា ៣៥២។** ដូចនេះការរួមភេទរវាងញាតិលោហិត ជាមួយញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ទោះបីគ្មានធាតុផ្សំនៃបទល្មើសរំលោភសេពសន្ថវៈ និងទោះបីញាតិពន្ធក្នុង ៣ (បី) ថ្នាក់ នោះព្រមព្រៀងក្តី ឬ មិនព្រមព្រៀងក្តី កាលបើមានការរួមភេទរវាងញាតិលោហិត និង ញាតិពន្ធក្នុង ៣ (បី) ថ្នាក់នោះវាគឺជាបទល្មើស។

- ពាក្យពិបាកៈ
  - ញាតិលោហិតៈ ជនដែលជាប់ខ្សែរលោហិតពីកំណើត។

    ឧទាហរណ៍៖ ឪពុកម្តាយ និងកូន; ជីដូនជីតា និងចៅ; បងប្អូនប្រុសស្រី។ ញាតិលោហិតចែកជាបីធំៗ មានដូចជា៖

    - ញាតិលោហិតធម្មតា ៖ គឺជាទំនាក់ទំនងញាតិលោហិតផ្ទាល់ និងទំនាក់ទំនងសាខាញាតិលោហិត។

      **ឧទាហរណ៍** ៖ រវាងឪពុកម្តាយ និងកូនបង្កើតរវាងបងប្អូនបង្កើត ។

      -ញាតិលោហិតផ្ទាល់ គឺជាញាតិដែលកើតពីមួយទៅមួយលំដាប់។

      **ឧទាហរណ៍** ៖ ម្តាយ=>កូន=>ចៅ=>ចៅទួត។

      -សាខាញាតិ គឺជាញាតិ ដែលបែកចេញជាមែកធាងពីបុព្វញាតិតែមួយ។

      **ឧទាហរណ៍** ៖ បងប្អូនបង្កើត, អ៊ុំ ពូមីង។
    - ញាតិលោហិតដែលច្បាប់កំណត់៖ ញាតិលោហិតដែលកំណត់ដោយច្បាប់ ឱ្យមានទំនាក់ទំនងដូច ញាតិលោហិតដែរ។

      **ឧទាហរណ៍** ៖ ទំនាក់ទំនងកូនស្មុំ និងឪពុកម្តាយចិញ្ចឹម, ទំនាក់ទំនងរវាងកូនស្មុំ និងកូនរបស់ឪពុកម្តាយចិញ្ចឹម។
  - ញាតិពន្ធៈ សម្តៅទៅលើទំនាក់ទំនង ឬ

    ចំណងគតិយុត្តជាមួយខ្លួននឹងញាតិលោហិតរបស់សហព័ទ្ធរបស់ខ្លួន ឬ ទំនាក់ទំនងរវាងញាតិលោហិតរបស់ខ្លួនជាមួយនឹងសហព័ទ្ធរបស់ខ្លួន។

**ឧទាហរណ៍** ៖ ញាតិខាងប្រពន្ធ គឺជា ញាតិពន្ធរបស់ប្ដី ដូចជា ឪពុកក្មេក ម្ដាយក្មេកជាដើម។ [62]

- ញាតិពន្ធក្នុង ៣(បី) ថ្នាក់មានដូចជា៖ ឪពុក, ម្ដាយរបស់សហព័ទ្ធ(ថ្នាក់ទី១), បងប្អូនបង្កើតរបស់សហព័ទ្ធ(ថ្នាក់ទី២), អ៊ុំ ពូមីង ដែលជាបុព្វញាតិរបស់សហព័ទ្ធ(ថ្នាក់ទី៣), និងក្មួយ ដែលជាបច្ឆាញាតិរបស់សហព័ទ្ធ(ថ្នាក់ទី៣)។

- ដោយមាត្រានេះគិតគូរអំពីតម្លៃនៃសង្គមខ្មែរ ក្រមព្រហ្មទណ្ឌផ្ដន្ទាទោស អំពើរួមភេទរវាងញាតិលោហិត ដោយពុំគិតអំពីលក្ខខណ្ឌអាយុ ឬ ភាពទន់ខ្សោយអ្វីឡើយ។

## ២.៨ អំពើរំលោភសេពសន្ថវៈលើសាកសព

**អំពើប៉ះពាល់ដល់បូរណភាពនៃសាកសព ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។**

អំពើប៉ះពាល់ដល់បូរណភាពសាកសព គឺជាអំពើដែលបំពាន ដោយការប៉ះពាល់ផ្ទាល់ទៅលើរូបរាងកាយ នៃសាកសព គ្រប់វិធីនៃការបំពានទៅលើសាកសពមានដូចជា ការប្រើអំពើហិង្សា អំពើរំលោភ និងរូបភាពផ្សេងៗនៃការប៉ះពាល់ ដល់បូរណភាពនៃសាកសពដែលត្រូវផ្ដន្ទាទោសតាមមាត្រា ២៦១។ បន្ថែមពីលើនេះជនល្មើសគឺ មានចេតនាបំពានទៅលើសាកសព ដោយកម្មវត្ថុនៃបទល្មើសគឺ សាកសព។

[62] ការគណនាថ្នាក់ញាតិ រៀបរៀងដោយ លោក ង៉ី ភីរម្យ។

# សេចក្តីសន្និដ្ឋាន

**បទរំលោភសេពសន្ថវៈ** ជាបទល្មើសព្រហ្មទណ្ឌមួយដែលគេតែងឮ និងស្គាល់ជាទូទៅគ្រប់មជ្ឈដ្ឋានយល់ដឹង។ ប៉ុន្តែអ្វីដែលគេយល់ដឹងទាំងនោះគឺត្រឹមថាវាជាបទល្មើសមួយដែលជនល្មើសបង្ខំឱ្យជនរងគ្រោះរួមភេទជាមួយខ្លួនប៉ុណ្ណោះ។ ការយល់ត្រឹមនេះ ជាការយល់ពុំពេញលេញតាមនិយមន័យនៃគតិយុត្ត ព្រោះថាបើតាមនិយមន័យ នៃបទល្មើសនេះ ការរំលោភសេពសន្ថវៈ គឺសំដៅដល់ ***គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬ អំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬ មិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬ ដោយការឆ្មក់ឱកាស***។

ពិតប្រាកដណាស់ ការស្វែងយល់ពីបទល្មើសនេះឱ្យបានស៊ីជម្រៅ វាមិនត្រឹមតែមាន ប្រយោជន៍ដល់ការកំណត់បទល្មើសប៉ុណ្ណោះទេ តែវាក៏ជាប្រយោជន៍ដល់ការណែនាំឱ្យ ប្រជាពលរដ្ឋទូទៅស្គាល់ច្បាស់ថាអំពើណាជាកម្មវត្ថុនៃ **បទរំលោភសេពសន្ថវៈ** ហើយការស្គាល់នេះ បានធ្វើឱ្យពលរដ្ឋយើងអាចរួមចំណែកជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការបង្ក្រាប តាមរយៈការរាយការណ៍ដល់សមត្ថកិច្ច ក៏ដូចជាចូលរួមបង្ការនូវបទល្មើសនេះកើតឡើងផងដែរ ពោលគឺកាលណាមានគេដឹងឮកាន់តែច្រើន ភ្នែកប្រមុះនៃនិយ័តករគតិយុត្តក៏កាន់ តែច្រើនឡើងអាចក្ដាប់ព័ត៌មានបានកាន់តែប្រសើរ រីឯជនល្មើសឯនោះវិញ ក៏ចេះតែក្រែង រអែងច្បាប់ឡើង ព្រមទាំងពុំហ៊ានប្រព្រឹត្តពាសវាលពាសកាលទេ។

ទន្ទឹមនឹងមានការសិក្សាស្វែងយល់លម្អិតពី**បទរំលោភសេពសន្ថវៈ** បទល្មើសទាក់ទងនឹងការបំពានផ្លូវភេទក៏ត្រូវបានសិក្សាក្នុងអត្ថបទស្រាវជ្រាវនេះផងដែរ ដើម្បីឱ្យការបែងចែក ក៏ដូចជាញែកនូវបទល្មើសនេះពីគ្នា នាំឱ្យកាន់តែងាយស្រួលស្វែងយល់។ ក្រៅពីការសិក្សានេះទៅ បទល្មើសព្រហ្មទណ្ឌនានា ទាំងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ក៏ដូចជាច្បាប់ពិសេសដែលមានលក្ខណៈព្រហ្មទណ្ឌនានា ក៏គួរមានការសិក្សាលម្អិតដូចគ្នា ផងដែរ ដើម្បីជាប្រយោជន៍ក្នុងការកសាងនីតិរដ្ឋដ៏រុងរឿងមួយ។

# អនុសាសន៍

ក្រោយពីបានសិក្សាយ៉ាងលម្អិតអំពើរំលោភសេពសន្ថវៈរួចមក យើងបានឃើញថាចំពោះបញ្ញត្តិច្បាប់ដែលបានកំណត់អំពីអំពើរំលោភសេពសន្ថវៈ មានទាំងចំណុចខ្លាំង និងចំណុចមួយចំនួនដែលជាបញ្ហាដែលតម្រូវឱ្យមានការពិនិត្យ និងបំពេញបន្ថែម។

- **ចំណុចខ្លាំង**

បញ្ញត្តិច្បាប់នេះ ជាបញ្ញត្តិដែលមានលក្ខណៈទាន់សម័យជឿនលឿន ដែលអាចរាប់ថាជាសមិទ្ធផល ឬជាលទ្ធផលនៃនីតិទំនើប រួមទាំងពាក្យពេចន៍នៃការតាក់តែង ទាំងរចនាសម្ព័ន្ធនៃការចងក្រងក៏មានលក្ខណៈតាមលំដាប់លំដោយ និងមានទំនាក់ទំនងគ្នាយ៉ាងល្អ។ លើសពីនេះទៅទៀត ខ្លឹមសារដែលបានបញ្ញត្តិមកនេះ គឺសុទ្ធសឹងតែស្របទៅតាមបរិបទនៃសង្គមខ្មែរយើងនាពេលបច្ចុប្បន្ន ហើយបើយើងក្រឡេកទៅមើលពីសម័យ ដែលទើបតែតាក់តែងក្រមនេះមករហូតដល់តឡូវ យើងអាចឃើញអំពីចក្ខុវិស័យដ៏វែងឆ្ងាយនៃតស្សរជនខ្មែរដែលបានចូលរួមក្នុងការតាក់តែងច្បាប់នេះ។

- **បញ្ហាមួយចំនួន**

ទោះបីជាបញ្ញត្តិច្បាប់នេះ ជាបញ្ញត្តិដែលមានលក្ខណៈទាន់សម័យជឿនលឿនក៏ដោយក្តី ក៏នូវមានបញ្ហាមួយចំនួនដែលកើតមានឡើងនៅក្នុងការអនុវត្តបញ្ញត្តិនេះផងដែរ។

តួយ៉ាងទាក់ទងនឹងបទល្មើសរំលោភសេពសន្ថវៈនេះ គឺជាបទល្មើសដែលភាគច្រើនកើតឡើងនៅទីកំបាំងភ្នែករបស់មនុស្ស ដែលសាធារណជនទូទៅមិនអាចមើលឃើញ ដូចនេះបទល្មើសនេះភាគច្រើន គឺពឹងពាក់អាស្រ័យទៅលើការដាក់ពាក្យបណ្ដឹងរបស់ជន ឬ បុគ្គលដែលបានដឹង អាចជាជនរងគ្រោះ និងសាច់ញាតិរបស់ជនរងគ្រោះ។ ដោយទាក់ទងទៅនឹងសេចក្តីថ្លៃថ្នូរ កិត្តិយស កេរ្តិ៍ឈ្មោះ នៅក្នុងសង្គម ដែលប្រជាពលរដ្ឋខ្មែរភាគច្រើនឱ្យតម្លៃ គឺនាំឱ្យជនរងគ្រោះច្រើនមានការខ្មាសអៀនមិនចង់ឱ្យខូចកិត្តិយស កេរ្តិ៍ឈ្មោះខ្លួនរួមទាំងក្រុមគ្រួសារ និងមិនចង់ឱ្យអ្នកដទៃតិះដៀល និងមិនចង់ឱ្យបែកធ្លាយរឿងអាម៉ាស់របស់ខ្លួនឱ្យអ្នកក្រៅដឹងទើបបណ្ដាលឱ្យជនរងគ្រោះភាគច្រើនលាក់បាំងរឿងរបស់ខ្លួន ហើយមិនប្ដឹងទៅកាន់នគរបាលមានសមត្ថកិច្ច។

បើយើងក្រឡេកទៅមើលភស្តុតាងក្នុងបទរំលោភសេពសន្ថវៈវិញ យើងឃើញថាភស្តុតាងក្នុងបទល្មើសនេះ គឺឆាប់ ឬ ងាយនឹងបាត់បង់ និងពិបាកស្វែងរក។ ជាទូទៅក្នុងបទល្មើសនេះ យើងឃើញមានភស្តុតាងដូចជាភស្តុតាងដែលបានបន្សល់ទុកនៅកន្លែងកើតហេតុ និងភស្តុតាងដែលជាប់នៅលើជនរងគ្រោះ ឬ ជាប់លើជនល្មើស។ ភស្តុតាងដែលបន្សល់ទុកនៅកន្លែងកើតហេតុ គឺងាយនឹងបាត់បង់ដោយសារតែរយៈពេលដែលកន្លងផុតទៅ។ ចំណែកឯភស្តុតាងដែលជាប់នៅលើជនរងគ្រោះ ជាទូទៅភស្តុតាងដែលជាប់នៅលើរូបរាងកាយនឹង

បាត់បង់ទៅតាមរយៈការជាសះស្បើយ ហើយចំពោះភស្តុតាងដែលបន្សល់ទុកនៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះវិញក៏មានកាលកំណត់របស់វាដែរ ប្រសិនបើផុតកាលកំណត់ហើយ វានឹងបាត់បង់ទៅតាមការវិវត្តន៍នៃសរីរាង្គកាយរបស់មនុស្ស។ ចំពោះភស្តុតាងដែលជាប់នៅលើជនល្មើស ជាទូទៅជនល្មើសតែងតែបំបាត់ភស្តុតាង ហើយវាកម្រមានភស្តុតាងដែលបន្សល់ទុកនៅលើជនល្មើសណាស់។ ម្យ៉ាងបុគ្គលម្នាក់ៗ មានសិទ្ធិលើបូរណភាពរូបរាងកាយ ក្នុងករណីបើសិនជាជននោះមិនយល់ព្រមឱ្យពិនិត្យលើរូបរាងកាយរបស់ខ្លួនទេ សមត្ថកិច្ចពុំមានសិទ្ធិក្នុងការចាប់បង្ខំទេ។

- **ដំណោះស្រាយ**

  ដើម្បីដោះស្រាយនូវបញ្ហាខាងលើតម្រូវឱ្យ៖

  - បង្កើនការផ្សព្វផ្សាយឱ្យប្រជាជនពលរដ្ឋយល់ដឹងអំពីបទល្មើសរំលោភសេពសន្ថវៈ
  - លើកកម្ពស់ការផ្សព្វផ្សាយអំពីបញ្ហាសុខភាពផ្លូវភេទ
  - ត្រូវពន្យល់ជនរងគ្រោះឱ្យយល់ថា បើជនរងគ្រោះមិនប្តឹង ឬ មិនធ្វើការបរិហារទៅលើករណីដែលកើតមានអំពើបំពានផ្លូវភេទទេ នោះជនល្មើសអាចនឹងប្រព្រឹត្តបទល្មើសនេះទៅលើអ្នកផ្សេងទៀត និងអាចបង្កើនចំនួនជនដែលរងគ្រោះដោយអំពើនេះថែមទៀត។
  - លើកទឹកចិត្តឱ្យជនរងគ្រោះចូលរួមជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីធ្វើការចាប់ជនល្មើសមកផ្តន្ទាទោសតាមផ្លូវច្បាប់។
  - លើកកម្ពស់ការអនុវត្តន៍ច្បាប់។
  - ត្រូវធ្វើការអភិវឌ្ឍ ទៅលើបច្ចេកទេសក្នុងការស្វែងរកភស្តុតាង។

# ឯកសារយោង

## ក. រដ្ឋធម្មនុញ្ញ ក្រម និងច្បាប់

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ បោះពុម្ពឆ្នាំ ២០១៧ ដោយអគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១១
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បោះពុម្ពផ្សាយដោយ ក្រសួងយុត្តិធម៌ ឆ្នាំ២០១២
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០០៨
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៩៧៦

## ខ. សៀវភៅបោះពុម្ព

- វចនានុក្រមខ្មែរ បោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ គ.ស. ១៩៦៧
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨
- នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ **កើត រិទ្ធ** ២០១៥
- កំណត់ពន្យល់មាត្រានីមួយៗនៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ២០១៣
- នីតិព្រហ្មទណ្ឌពិសេស សាស្ត្រាចារ្យ **វុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ២០១៣-២០១៤
- នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ **វុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ២០១២
- សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីវិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ ឆ្នាំ ២០០៥
- មេរៀននីតិព្រហ្មទណ្ឌទូទៅ ឯកឧត្តម **ហ៊ី សោភា**

## គ. គេហទំព័រ និងតំណភ្ជាប់

- http://www.pheakdeylaw.com/kh/publication/45
- https://ams.com.kh/central/detail/33867
- https://wmc.org.kh/article/79741/%E1%9E%93%E1%9E%B6%E1%9E%91%E1%9E%B8%E1%9E%85%E1%9F%92%E1%9E%94%E1%9E%B6%E1%9E%94%E1%9F%8B%E1%9F%96-%E1%9E%94%E1%9E%91%E1%9E%83%E1%9E%B6%E1%9E%8F%E1%9E%80%E1%9E%98%E1%9F%92%E1%9E%98%E1%9E%8A%E1%9F%84/amp/

# ឧបសម្ព័ន្ធ

## **មាតិកាឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១៖** រដ្ឋធម្មនុញ្ញ និងក្រម

**ឧបសម្ព័ន្ធទី២៖** ច្បាប់ផ្សេងៗ

# ឧបសម្ព័ន្ធទី១៖
# រដ្ឋធម្មនុញ្ញ និងក្រម

# រដ្ឋធម្មនុញ្ញ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

រដ្ឋសភា

# អារម្ភកថា

ក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នកំពូលមួយ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ព្រមទាំងមានសិទ្ធិពិនិត្យ និងសម្រេច អំពីករណីវិវាទកម្ម ទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ។

ក្រុមប្រឹក្សាធម្មនុញ្ញថ្វាយមតិព្រះមហាក្សត្រ ចំពោះសេចក្ដីស្នើសុំវិសោធនកម្មលើរដ្ឋធម្មនុញ្ញ ។

ដោយយល់ឃើញថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូល និង ជាមូលដ្ឋានគតិយុត្តសំខាន់បំផុតសម្រាប់ជាតិ និង ប្រជាពលរដ្ឋខ្មែរ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការផ្ទៀងផ្ទាត់ និង ចងក្រងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះឡើង ដើម្បីបម្រើសេចក្ដីត្រូវការរបស់មន្ត្រីរាជការស៊ីវិល និង យោធិន ជាអ្នកគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ យកទៅគោរពប្រតិបត្តិ ពេលបំពេញការងារតាមវិស័យ ឬ ជំនាញនីមួយៗ ដោយធានាឱ្យស្របតាមរដ្ឋធម្មនុញ្ញ ។

ការរៀបចំចងក្រងរដ្ឋធម្មនុញ្ញនេះ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានធ្វើការស្រាវជ្រាវរកសំណៅដើមពីមន្ទីររដ្ឋសភា ក្រោយពេលដែលសភាធម្មនុញ្ញបានអនុម័តរួចពីថ្ងៃ អង្គារ ៦ កើត ខែ ភទ្របទ ឆ្នាំរកា បញ្ចស័ក ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២១ ខែ កញ្ញា

គ.ស ១៩៩៣ ហើយត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមពីថ្ងៃ សុក្រ ៩ កើត ខែ ភទ្របទ ឆ្នាំរកា ព.ស ២៥៣៧ ត្រូវនឹងថ្ងៃទី ២៤ ខែ កញ្ញា គ.ស ១៩៩៣ ព្រមទាំងរកសំណៅដើមនៃព្រះរាជក្រមទាំងឡាយប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញ ចំនួន ៧ ក្រោយៗមកទៀត ។

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញសង្ឃឹមថា ការផ្សព្វផ្សាយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានេះ ចាត់ទុកជាការរួមចំណែកក្នុងការអនុវត្តនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលអាណត្តិទី៥ នៃរដ្ឋសភា ឱ្យបានជោគជ័យ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០១៥

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

**មាត្រា ៣៨.-**

ច្បាប់ហាមឃាត់ មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដែលដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមព្រហ្មទណ្ឌ

# នៃ

# ព្រះរាជាណាចក្រកម្ពុជា



២០១០

ក្រសួងយុត្តិធម៌

Ministère de la Justice

# ព្រះរាជក្រម

នស/រកម/១១០៩/០២២

# យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាម ទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀងប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិមអាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង

-ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះឬរាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើសមិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទលហុ ពុំទទួលការផ្តន្ទាទោសទេ ។

**មាត្រា ២៨.-** និយមន័យនៃអ្នកផ្តើមគំនិត

ត្រូវចាត់ទុកជាអ្នកផ្តើមគំនិតក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ចំពោះបុគ្គលណាដែល :

១-ជំរុញឱ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ តាមការណែនាំ ឬការបញ្ជា។

៣-ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី ពីព្រោះជននេះបានបរិហារពីបទល្មើស ឬសុំឱ្យផ្តួសផុលល្បុសនកម្ម ។

៤-សាក្សី ដោយមូលហេតុសាក្សីនេះបានផ្តល់ភស្តុតាងនៅពេលស៊ើបអង្កេត ស៊ើបសួរ សវនាការ ឬនៅក្នុងនីតិវិធីនៃបណ្តឹងផ្សេងទៀត ។

**មាត្រា ២០៤.-** បទឃាតកម្មប្រព្រឹត្តដោយអ្នករាជការសាធារណៈ

ឃាតកម្មត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើអំពើនេះត្រូវបានប្រព្រឹត្តដោយអ្នករាជការសាធារណៈនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា ២០៥.-** បទឃាតកម្មដោយមានទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ

ឃាតកម្មដែលកើតក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម អំពើឃោរឃៅ ឬអំពើរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ។

**មាត្រា ២០៦.-** ទោសបន្ថែម : ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះអាចត្រូវបានប្រកាស :

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទឧក្រិដ្ឋត្រូវបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

## ជំពូកទី ៣
## ការបំពានខាងផ្លូវភេទ
## ផ្នែកទី ១
## ការរំលោភសេពសន្ថវៈ

**មាត្រា ២៣៩.-** បទរំលោភសេពសន្ថវៈ

គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូលឧបករណ៍ណាមួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃ ទោះបីមានភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ដោយការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្មក់ឱកាស គឺជាបទរំលោភសេពសន្ថវៈ ។

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ ។

នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

**មាត្រា ២៤០.-** ស្ថានទម្ងន់ទោសដោយសារមធ្យោបាយប្រើប្រាស់ ឬទាក់ទងនឹងជនល្មើស

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើង :

១-ដោយការប្រើអាវុធ ឬគំរាមកំហែងនឹងអាវុធ ។

២-ដោយការប្រើគ្រឿងញៀន ឬគ្រប់វិធីដែលនាំឱ្យជនរងគ្រោះបាត់បង់ ឬចុះខ្សោយលទ្ធភាពទប់ទល់ ។

៣-ដោយបុគ្គលដែលមានអំណាចទៅលើជនរងគ្រោះ ។

៤-ដោយបុគ្គលដែលរំលោភអំណាចដែលមុខងាររបស់ខ្លួនបានប្រគល់ឱ្យ ។

៥-ដោយបុគ្គលច្រើនរូប ដែលប្រព្រឹត្តឡើងក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត ឬជាអ្នកសមគំនិត ។

**មាត្រា ២៤១.-** ស្ថានទម្ងន់ទោសទាក់ទងទៅនឹងជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ

១៥ (ដប់ប្រាំ) ឆ្នាំ កាលបើអំពើនេះប្រព្រឹត្តទៅលើ ៖

១-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុអាយុនៃបុគ្គលនោះ ។

២-នារីមានគភ៌ កាលបើគភ៌ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង ។

៣-បុគ្គលដែលទន់ខ្សោយពិសេស ដោយមូលហេតុនៃជំងឺ ឬពិការភាព កាលបើស្ថានភាពបុគ្គលនេះត្រូវបានគេឃើញជាក់ស្តែង ឬកាលបើជនល្មើសបានដឹង។

**មាត្រា ២៤២.-** ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះនាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ ។

**មាត្រា ២៤៣.-** ស្ថានទម្ងន់ទោសដោយសារការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះប្រព្រឹត្តឡើងមុនពេល ក្នុងពេល ឬក្រោយពេលប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ ។

**មាត្រា ២៤៤.-** ស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ

បទរំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ កាលបើបទល្មើសនេះបណ្តាលឱ្យជនរងគ្រោះស្លាប់ ដោយគ្មានចេតនាសម្លាប់។

**មាត្រា ២៤៥.-** ទោសបន្ថែម ៖ ប្រភេទ និងរយៈពេល

ចំពោះបទឧក្រិដ្ឋដែលមានចែងក្នុងផ្នែកនេះ ទោសបន្ថែមដូចតទៅនេះ អាចត្រូវបានប្រកាស ៖

១-ការដកសិទ្ធិខ្លះជាពលរដ្ឋ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន ។

២-ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនេះបានប្រព្រឹត្ត នៅក្នុងការប្រកបវិជ្ជាជីវៈ ឬនៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៣-ការហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ យ៉ាងច្រើន ។

៤-ការហាមឃាត់ដល់ទណ្ឌិតបរទេសចំពោះការចូល ឬការស្នាក់នៅក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជា ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ យ៉ាងច្រើន។

៦-ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែ យ៉ាងច្រើន ។

៧-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន ។

៨-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍ សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃ យ៉ាងច្រើន ។

## ផ្នែកទី ២
## ការបំពានខាងផ្លូវភេទដទៃទៀត

**មាត្រា ២៤៦.-** បទប្រទូស្តកេរខ្មាស

គ្រប់អំពើប៉ះពាល់ ស្ទាប អង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើ ខ្លួន ឬទៅលើតតិយបុគ្គល ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ ផ្លូវភេទរបស់ជនល្មើស គឺជាអំពើប្រទូស្តកេរខ្មាស។

អំពើប្រទូស្តកេរខ្មាសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ២៤៩.-** បទបង្ហាញកេរភេទ

អំពើបង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញ នៅក្នុងទីកន្លែងមួយដែលសាធារណជនអាចមើលឃើញ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ៥០០ ០០០ (ប្រាំសែន) រៀល ។

**មាត្រា ២៥០.-** បទរុកកួនខាងផ្លូវភេទ

អំពើរុកកួនខាងផ្លូវភេទ គឺជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដែលមុខងាររបស់ខ្លួនប្រគល់ឱ្យ ធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ ។

អំពើរុកកួនខាងផ្លូវភេទ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ៣ (បី) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ៥០០ ០០០ (ប្រាំសែន) រៀល ។

**មាត្រា ៣៤១.-** បទអាសប្រព្រឹត្តទៅលើអនីតិជនអាយុតិចជាង ១៥ ឆ្នាំ

អំពើអាស គឺជាអំពើនៃការប៉ះពាល់ ឬការបង្ហាញកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬការឱ្យជនដទៃប៉ះពាល់កេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬរបស់តតិយជន ក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសទៅលើអនីតិជនអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល ។

**មាត្រា ៣៥១.-** បទរួមភេទជាមួយអនីតិជន ដោយបុព្វញាតិ

អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ កាលបើចារីជាបុព្វញាតិរបស់អនីតិជននោះ ។

**មាត្រា ៣៥២.-** បទរួមភេទរវាងញាតិលោហិត ឬញាតិពន្ធ

អំពើរួមភេទរវាងញាតិលោហិត ឬញាតិពន្ធក្នុង ៣ (បី) ថ្នាក់ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងពិន័យ ជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ។

មិនត្រូវចាត់ទុកជាបទល្មើសតាមកថាខណ្ឌទី ១ ខាងលើទេ ប្រសិនបើសហព័ទ្ធណាម្នាក់ស្លាប់ ហើយសហព័ទ្ធដែលនៅរស់រួមភេទជាមួយសាខាញាតិពន្ធថ្នាក់ទី ២ ឬថ្នាក់ទី ៣។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមរដ្ឋប្បវេណី
# នៃ
# ព្រះរាជាណាចក្រកម្ពុជា

កាលបរិច្ឆេទប្រកាសឲ្យប្រើ
**០៨ ធ្នូ ២០០៧**

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# ការបង្ហាញឆន្ទៈ និង កិច្ចសន្យា

## ផ្នែកទី ១
## ការបង្កើតកិច្ចសន្យា

**មាត្រា ៣៣៦.-** ការបង្កើតកិច្ចសន្យាដោយសំណើ និង ស្ទីការ

១-កិច្ចសន្យាមានអានុភាពដោយសារសំណើ និង ស្ទីការត្រូវគ្នា ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏កិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬ ករណីយកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុ នឹងមានអានុភាព លុះត្រាតែបានធ្វើលិខិតយថាភូត ។

**មាត្រា ៣៣៧.-** និយមន័យនៃសំណើ និង ស្ទីការ

១-សំណើគឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្តក្នុងករណីដែលមានស្ទីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ ។

២-សំណើត្រូវមានអានុភាពនៅពេលដែលសំណើនោះបានដល់ភាគីម្ខាងទៀត ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកសំណើវិញ ដល់ភាគីម្ខាងទៀត នៅពេលព្រមគ្នានឹងពេលសំណើដល់ ឬ មុនពេលសំណើដល់ នោះអានុភាពសំណើមិនត្រូវកើតឡើយ ។

៣-ស្ទីការគឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើយល់ព្រមចំពោះសំណើនោះ ។

៤-ស្ទីការត្រូវមានអានុភាពនៅពេលដែលស្ទីការនោះបានដល់អ្នកស្នើ ។ ប៉ុន្តែ ប្រសិនបើដំណឹងអំពីការដកស្ទីការវិញ ដល់អ្នកស្នើ នៅពេលព្រមគ្នានឹងពេលស្ទីការដល់ ឬ មុនពេលស្ទីការដល់ នោះអានុភាពនៃស្ទីការ មិនត្រូវកើតឡើយ ។

**មាត្រា ៣៣៨.-** សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្ទីការ និង ការដកសំណើនោះ

១-សំណើអាចធ្វើឡើងបានដោយកំណត់អំឡុងពេលសម្រាប់ស្ទីការ ។ អំឡុងពេល

## ផ្នែកទី ៣
## ការបញ្ចប់ភតិសន្យា

**មាត្រា ៦១២.-** ការផុតអំឡុងពេលកំណត់

ភតិសន្យាដែលមានកំណត់អំឡុងពេល ត្រូវបញ្ចប់ដោយការផុតអំឡុងពេលដែលបានកំណត់នោះ ។

**មាត្រា ៦១៣.-** ការបដិសេធការបន្តជាថ្មី នូវភតិសន្យាអចលនវត្ថុ

ចំពោះភតិសន្យាអចលនវត្ថុ បើភាគីម្ខាងពុំបានបង្ហាញឆន្ទៈបដិសេធការបន្តជាថ្មី នៅមុនរយៈពេល ៣ (បី) ខែ មុនផុតកំណត់អំឡុងពេល ចំពោះផ្ទះ ឬ អាគារ ឬ នៅមុនរយៈពេល ១ (មួយ) ឆ្នាំ មុនផុតកំណត់អំឡុងពេល ចំពោះដីធ្លី ទៅភាគីម្ខាងទៀតទេ ត្រូវចាត់ទុកថាបានយល់ព្រមក្នុងការបន្តជាថ្មី ។ ប៉ុន្តែ ក្នុងករណីនេះ ភតិសន្យាដែលត្រូវបានបន្តជាថ្មីនេះ គឺជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ។

**មាត្រា ៦១៤.-** ការបន្តជាថ្មីដោយតុណ្ហីភាព

ចំពោះភតិសន្យាចលនវត្ថុ នៅក្នុងករណីដែលភតិកៈបានបន្តការប្រើប្រាស់ ឬ អាស្រ័យផលលើវត្ថុជួលនោះ ទោះនៅក្រោយអំឡុងពេលនៃភតិសន្យា បានផុតកំណត់ហើយក៏ដោយ បើភតិបតីបានដឹងអំពីហេតុនោះហើយ តែមិនបានធ្វើការតវ៉ាទេ ត្រូវសន្មតថាជាភតិសន្យាដែលបានបន្តជាថ្មី ដោយគ្មានកំណត់អំឡុងពេល ហើយមានលក្ខខណ្ឌដូចគ្នានឹងកិច្ចសន្យាដែលបានជួលពីមុន លើកលែងតែអំឡុងពេលចេញ ។

**មាត្រា ៦១៥.-** ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល

១-បើពុំបានកំណត់អំឡុងពេលជួលនៅក្នុងកិច្ចសន្យាទេ ភាគីនីមួយៗអាចស្នើសុំឱ្យរំលាយកិច្ចសន្យា នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលាយ មិនបានបញ្ជាក់អំពីពេលរលាយ និង ក្នុងករណីដែលអំឡុងពេលចាប់ពីពេលស្នើសុំឱ្យរំលាយរហូតដល់ពេលរលាយដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលាយនោះ តិចជាងអំឡុង

# គន្ថីទី ៧
# ញាតិ

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៩៣៨.–** ទំហំរបស់ញាតិ

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ គឺជាញាតិ :

ក-ញាតិលោហិតក្នុង ៦ (ប្រាំមួយ) ថ្នាក់ ។

ខ-សហព័ទ្ធ ។

គ-ញាតិពន្ធក្នុង៣ (បី)ថ្នាក់ ។

**មាត្រា ៩៣៩.–** ការគណនាថ្នាក់ញាតិ

១-ថ្នាក់ញាតិ ត្រូវកំណត់ដោយគណនាចំនួននៃតំណពូជរវាងញាតិ ។

២-ដើម្បីកំណត់ថ្នាក់ញាតិនៃសាខាញាតិ ត្រូវគណនាចំនួននៃតំណពូជ គិតចាប់ពីជននោះ ឬ សហព័ទ្ធរបស់ជននោះ ឡើងទៅដល់បុព្វជនដូចគ្នា និង ចំនួននៃតំណពូជ គិតចាប់ពីបុព្វជនរបស់ជននោះ ចុះរហូតមកដល់ជនម្នាក់ទៀត ។

**មាត្រា ៩៤០.–** ការកើតមានឡើងនូវទំនាក់ទំនងញាតិភាពដោយការសុំកូន

ទំនាក់ទំនងរវាងកូនចិញ្ចឹម និង ឪពុក ម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន ។

**មាត្រា ៩៤១.–** ការរលត់ទំនាក់ទំនងញាតិពន្ធ

១-ទំនាក់ទំនងញាតិពន្ធ ត្រូវបញ្ចប់ដោយការលែងលះគ្នា ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហព័ទ្ធណាម្នាងបានទទួលមរណភាព ហើយសហព័ទ្ធដែលនៅរស់ បានរៀប

ដែលកើតឡើងដោយសារការបដិសេធចោលនោះបាន ។

**មាត្រា ៩៤៧.–** អំឡុងពេលដាក់ពាក្យបណ្ដឹង

បណ្ដឹងដែលទាក់ទងទៅនឹងមាត្រា ៩៤៥ (ការសងជំនួន) ឬ មាត្រា ៩៤៦ (ការទទួលខុសត្រូវចំពោះការបដិសេធចោលដោយមិនត្រឹមត្រូវ) ខាងលើនេះ ត្រូវប្ដឹងនៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលកំជាប់ពាក្យនោះ បានរលាយ ។

## ជំពូកទី ៣
## អាពាហ៍ពិពាហ៍

## ផ្នែកទី ១
## ការបង្កើតអាពាហ៍ពិពាហ៍

### កថាភាគទី ១
### លក្ខខណ្ឌនៃអាពាហ៍ពិពាហ៍

**មាត្រា ៩៤៨.–** អាយុគ្រប់លក្ខណៈរៀបអាពាហ៍ពិពាហ៍

បុរស និង នារី ដែលមិនទាន់ដល់នីតិភាព មិនអាចរៀបអាពាហ៍ពិពាហ៍បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលភាគីម្ខាង បានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន ដោយទទួលការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់អនីតិជននោះ ។

**មាត្រា ៩៤៩.–** ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព

បុគ្គលដែលមានសហព័ទ្ធហើយ ពុំអាចរៀបអាពាហ៍ពិពាហ៍ទៀតបានឡើយ ។

**មាត្រា ៩៥០.–** អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀត

១-នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើអំឡុងពេល ១២០

# ឧបសម្ព័ន្ធទី២៖

# ច្បាប់ផ្សេងៗ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

# សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

## វិភាគទានចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ

# PROJET DE NOUVEAU CODE PENAL

## COMMENTE ET COMPARE

CONTRIBUTION A L´ETUDE DU DROIT PENAL KHMER



Sous la haute autorité de S.E ANG VONG Vathana , Ministre de la Justice

MICHEL BONNIEU

PHOV SAMPHY
HEL CHAMROEUN
CHAING SINATH
KOEUT RITH
MARION COUVIDAT

2005

## មាត្រា កម ២២២១-៥ ស្ថានទម្ងន់ដែលកើតចេញពីមានការកាត់ផ្តាច់អវៈយវៈ និងពិការភាព

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា កម.២២២១-១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីដប់ (១០) ឆ្នាំ ទៅម្ភៃ (២០)ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ ដល់ជនរងគ្រោះ ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

សេចក្តីព្រាងក្រមព្រហ្មទណ្ឌ កម្រិតទណ្ឌកម្មដោយយោងទៅលើព្យសនកម្មដែលជនរងគ្រោះទទួល ហើយធ្វើការទម្ងន់ទោស ដោយគិតគូរអំពីលក្ខណៈអចិន្ត្រៃយ៍នៃពិការភាព ឬការកាត់អវៈយវៈ ដែលបណ្តាលមកពីអំពើល្មើស ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រខ្មែរ :

ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩២៥ និង ១៩៥៥ ពុំបានកំណត់អំពីស្ថានទម្ងន់ពាក់ព័ន្ធនឹងការកាត់អវៈយវៈ ឬពិការភាពរបស់ជនរងគ្រោះទេ ។

## មាត្រា កម ២២២១-៦ ស្ថានទម្ងន់មរណភាពនៃជនរងគ្រោះ

បទឧក្រិដ្ឋដែលមានចែងនៅក្នុងមាត្រា កម.២២២១-១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីដប់ប្រាំ (១៥) ឆ្នាំ ទៅសាមសិប (៣០) ឆ្នាំ កាលបើបទឧក្រិដ្ឋនេះនាំឱ្យមានមរណភាពដល់ជនរងគ្រោះដោយ គ្មានចេតនានឹងធ្វើឱ្យស្លាប់ ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ទោសដាក់ពន្ធនាគារអាចឡើងរហូតដល់អតិបរមា ៣០ ឆ្នាំ បើអំពើល្មើសនាំឱ្យមានការស្លាប់របស់ជនរងគ្រោះ ដែលក្រៅឆន្ទៈរបស់ចារី ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រខ្មែរ :

នេះជាអំពើហឹង្សាក្នុងគ្រួសារ (រវាងមាតាបិតា សហពទ្ធ័ ជាអាទិ៍ ... ) ច្បាប់ក្រមវិវាទ កំណត់ក្នុង មាត្រា ៥ និង ១៧ ថាបើអំពើហឹង្សា នាំអោយមានរបួស ជនល្មើសត្រូវទទួលការវិនិច្ឆ័យហាក់ដូចជា គេស្ថិតនៅក្នុងគ្រួសារផ្សេងពីជនរងគ្រោះ ។ បើពុំមានរបួសទេ ត្រូវរៀបចំពិធីផ្សះផ្សារមួយ (ក្រមឆាង ដឺ) ។ អាដេម៉ាឡឺក្លែរ. ក្រមខ្មែរ. ភាគ ២. ទំព័រ ៤៥១ និងបន្តបន្ទាប់ ។

ក្រមព្រហ្មទណ្ឌឆ្នាំ ១៩២៥ និង ១៩៥៥ ពុំបានចែងអំពីស្ថានទម្ងន់បណ្តាលមកពីចារីជាសហពទ្ធ័ទេ ។

អត្ថិភាពនៃសេចក្តីព្រាងច្បាប់ឆ្នាំ ២០០៣ ស្តីពីអំពើហឹង្សាក្នុងគ្រួសារត្រូវយកមកគិតគូរ ។

## *មាត្រា កម ២២២២-៧* *ស្ថានទម្ងន់ដែលបណ្តាលមកពីមានការកាត់ផ្តាច់អវៈយវៈនិងពិការភាព*

អំពើហិង្សាដោយចេតនា ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីប្រាំ (៥) ឆ្នាំ ដល់ដប់ (១០) ឆ្នាំ កាលបើអំពើនេះនាំឱ្យមានការកាត់អវយវៈ ឬឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

ស្ថានទម្ងន់នេះ ( មានចែងក្នុងមាត្រា កម.២២១១-៧) ផ្អែកលើសភាពធ្ងន់ធ្ងរនៃការខូចខាត របស់ជនរងគ្រោះ ដែលកើតចេញពីអំពើហឹង្សា ។ ចៅក្រមត្រូវគិតគូរអំពីអន្តរាយដែលនឹងកើតឡើងទៅ អនាគតផងដែរ ហើយនឹងត្រូវអនុវត្ត ស្ថានទម្ងន់តែនៅពេលដែលមានពិការភាពព្រមទាំងសភាពកាន់ តែធ្ងន់នៃអន្តរាយតែប៉ុណ្ណោះ ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រខ្មែរ :

មាត្រា ៤៩៩ នៃក្រមឆ្នាំ ១៩២៩ ផ្តន្ទាទោសអោយធ្វើការដោយបង្ខំ ចំពោះអំពើហឹង្សាដែលបណ្តាលអោយមានពិការភាពអចិន្ត្រៃយ៍ ។

មាត្រា ៤៩៨ នៃក្រមឆ្នាំ ១៩៥៥ បានលំអិតខ្លាំងពីអំពើហឹង្សាដែលត្រូវទទួលទណ្ឌកម្មជាបទឧក្រិដ្ឋ ថ្នាក់ទី១ (ពិការភាពធ្ងន់ធ្ងរ .បាត់បង់អវៈយវៈ . បាត់បង់ស្មារតីវិកលចរិក . រលូតកូន ចំពោះស្ត្រីមានផ្ទៃពោះ ) ។

# មាតិកាទី ៣ : ការឈ្លានពានខាងផ្លូវភេទ

## ជំពូកទី ១ : ការរំលោភសេពសន្ថវៈ

***មាត្រា កម ២២៣១-១*** ***ធាតុផ្សំនៃការរំលោភសេពសន្ថវៈ***

អំពើបញ្ចូលកេរ្តិ៍ភេទ ឬឧបករណ៍ផ្សេងទៀត តាមប្រភេទណាក៏ដោយ ដែលប្រព្រឹត្តទៅលើអ្នកដទៃ ដោយប្រើហិង្សា ការបង្ខិតបង្ខំ ការកំហែងគំរាម ឬដោយការឆ្មក់ឱកាស គឺជាបទចាប់បង្ខំសេពសន្ថវៈ ។

ការចាប់រំលោភសេពសន្ថវៈ ត្រូវផ្តន្ទាទោសពីដប់ (១០) ឆ្នាំទៅដប់ប្រាំ (១៥) ឆ្នាំ ។ នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុដប់ប្រាំ (១៥) ឆ្នាំ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

តាមនិយមន័យនេះ ការរំលោភសេពសន្ថវៈ តម្រូវអោយមានការបញ្ចូលកេរ្តិ៍ភេទដោយបង្ខំ ។ អវត្តមាននៃឆន្ទៈព្រមព្រៀងរបស់ជនរងគ្រោះ ស្តែងឡើងដោយអំពើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆក់ឱកាស ។ ទៅអនាគត តុលាការនឹងធ្វើការពិចារណាសម្រេចជាអាទិ៍លើបញ្ហារំលោភសេពសន្ថវៈ ប្រព្រឹត្តដោយសហព័ទ្ធព្រមទាំងនិយមន័យ នៃសញ្ញាណអំពើហិង្សាការបង្ខិតបង្ខំការគំរាមកំហែង ឬការឆក់ឱកាស ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រខ្មែរ :

នីតិនិពន្ធខ្មែរសម័យបុរាណ មិនបានអោយនិយមន័យការរំលោភសេពសន្ថវៈទេ ប៉ុន្តែមាត្រា ៤ នៃក្រមលក្ខិណា " អំពើកំហុសប្រព្រឹត្តទៅលើ នារី ៧ ប្រភេទ " សំដៅលើការរំលោភសេពសន្ថវៈលើកុមារ " ការហូរឈាមត្រង់ប្រដាប់ភេទរបស់កុមារ " ។

នីតិនិពន្ធខ្មែរ កំណត់សភាពធ្ងន់ធ្ងរនៃការរំលោភសេពសន្ថវៈដោយផ្អែកទៅលើគុណភាពនៃជនរងគ្រោះ ( កុមារ . ទាសករ . ស្ត្រីបំរើក្នុង រាជវាំង . ស្ត្រីមានប្តី. មេម៉ាយ . ស្ត្រីភ្ជាប់ពាក្យរួច ) និង គុណភាពរបស់ចារី ( ភ្នាក់ងារតុលាការ មន្ត្រីរាជការ ប្រើសិទ្ធរបស់ព្រះមាហាក្សត្រ ): សូមមើល មាត្រា ៤៩ នៃ ក្រមឧកញ៉ាហ្លួង ឬច្បាប់ស្តីពីប្រើសិទ្ធរបស់ព្រះមហាក្សត្រ ។ អាដេម៉ាឡឺក្លែរ. ក្រមខ្មែរ. ភាគ ២. ទំព័រ ២៥០ និងបន្តបន្ទាប់ ។

ការរំលោភសេពសន្ថវៈមិនធ្លាប់ទទួល ទណ្ឌកម្មដាក់គុកទេ តែត្រូវទទួលពិន័យ និងការវាយនឹងរំពាត់ផ្តៅ ។ នៅកម្ពុជា ការរំលោភសេពសន្ថវៈលើស្ត្រីមានប្តី ត្រូវបានចាត់ទុកថា មានលក្ខណៈធ្ងន់ធ្ងរ ជាងការរំលោភលើនារីមិនទាន់មានប្តី ព្រោះប្តីរបស់ស្ត្រីនោះ ត្រូវចាត់ទុកថាបានទទួលនូវព្យសនកម្មដែរ ។ ការប៉ុនប៉ងក្នុងបទល្មើសរំលោភ

### មាត្រា កម ២២៣១-៤ ស្ថានទម្ងន់បណ្ដាលមកពីមានការកាត់អវយវៈ ឬពិការភាព

ការរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាប់ពន្ធនាគារពីដប់ (១០) ឆ្នាំ ទៅម្ភៃ (២០) ឆ្នាំ កាលបើអំពើនេះ នាំឱ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់ ជនរងគ្រោះ ។

**សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ :**

សូមមើលអត្ថាធិប្បាយក្នុងមាត្រា កម.២២២១-៥ និង កម.២២២២-៧ ។

**អត្ថបទយោង :**

**ប្រភពប្រវត្តិសាស្ត្រខ្មែរ :**

លោក **អាដេម៉ាឡើក្លែរ** បានបញ្ជាក់ថា ក្នុងសម្មតិកម្មនេះទោសទី២ ដែលសមាមាត្រទៅនឹងសភាព ធ្ងន់ធ្ងរនិងចំនួនរបួសដែលកើតឡើង អាចត្រូវប្រកាសដោយតុលាការ ។

### មាត្រា កម ២២៣១-៥ ស្ថានទម្ងន់បណ្ដាលមកពីការធ្វើទារុណកម្ម ឬអំពើឃោរឃៅ

ការរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាប់ពន្ធនាគារពីដប់ប្រាំ (១៥) ឆ្នាំ ទៅសាមសិប (៣០) ឆ្នាំ កាលបើអំពើនេះបានកើតឡើងមុនក្នុងពេល ឬក្រោយពីបានប្រព្រឹត្តអំពើទារុណកម្ម ឬអំពើឃោរឃៅ។

**សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ :**

សូមមើលកំណត់ក្នុងមាត្រា កម.២២១១-៧ និង កម.២២២២-៧ ។

**អត្ថបទយោង :**

**ប្រភពប្រវត្តិសាស្ត្រខ្មែរ :**

មាត្រា ៥០០ ក្នុងក្រមឆ្នាំ ១៩២៩ និង ១៩៥៥ បានកំណត់អំពើឃោរឃៅ ឬទារុណកម្ម ជាបទល្មើសឯករាជ្យតែមិន បានចែងអំពីស្ថានទម្ងន់ ដោយសារការប្រើទារុណកម្ម ឬអំពើឃោរឃៅឡើយ ។ សូមមើលកំណត់នៅក្នុងមាត្រា កម. ២២២១-១ ។

### មាត្រា កម ២២៣១-៦ ស្ថានទម្ងន់បណ្ដាលមកពីមរណភាពនៃជនរងគ្រោះ

ការរំលោភសេពសន្ថវៈ ត្រូវផ្ដន្ទាទោសដាប់ពន្ធនាគារពីដប់ប្រាំ (១៥) ឆ្នាំ ទៅសាមសិប (៣០) ឆ្នាំ កាលបើអំពើនេះនាំឱ្យជនរងគ្រោះស្លាប់ដោយគ្មានបំណង នឹងឱ្យស្លាប់ទេ ។

## មាត្រា ក៣ ២៣១៦-២ ការប៉ះពាល់ខាងផ្លូវភេទដល់អនីតិជន ដោយបុព្វញាតិ

អំពើរួមភេទជាមួយអនីតិជនក្រោមដប់ប្រាំបី (១៨) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំ (៥) ទៅដប់ (១០) ឆ្នាំ កាលបើ ចារីជាបុព្វញាតិមានខាន់ស្លា អត់ខាន់ស្លា ឬថិញ្ញើម របស់អនីតិជននោះ។

### សេចក្តីព្រាងក្រមព្រហ្មទណ្ឌ :

មាត្រានេះ គិតគូរអំពីសភាពធ្ងន់ធ្ងរនៃអំពើទាស់មុខស្ទន់ (ជាពិសេសទំនាក់ទំនងផ្លូវភេទរវាង បុព្វញាតិ និងបច្ឆាញាតិអាយុតិចជាង ១៨ ឆ្នាំ) ក្នុងជីវភាពសង្គមខ្មែរផ្តន្ទាទោសបទល្មើសនេះដោយទោសឧក្រិដ្ឋ ។ មាត្រានេះពុំកំណត់ថាជាបទល្មើសទេ ក្នុងករណីបច្ឆាញាតិ ជានីតិជន ។

### អត្ថបទយោង :

### ប្រភពប្រវត្តិសាស្ត្រខ្មែរ :

នៅក្នុងនីតិខ្មែរសម័យបុរាណ អ្នកតែងច្បាប់បានចែងអំពីសម្មតិកម្មផ្សេងៗ នៃការប៉ះពាល់ផ្លូវភេទ នៅក្នុងគ្រួសារ : ជាឧទាហរណ៍ សូមមើល "លក្ខិណា ទាក់ទិននឹងកំហុសប្រព្រឹត្តទៅលើស្ត្រី ៧ ប្រភេទ " ដែលជាផ្នែកមួយនៃក្រម ទោសភរិយា **Tous Piriyear** ។ **អាដេម៉ាឡឺក្លែរ**. ក្រមខ្មែរ. ភាគ ១. ទំព័រ ២៦៤ ។

មាត្រា ៤៤៧ និង ៤៤៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩២៩ និង ១៩៥៥ ផ្តន្ទាទោសអំពើទាស់មុខស្ទន់ដែលមាននិយមន័យ នៅក្នុងមាត្រា ៤៤៨ ។

សូមមើល មាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញខ្មែរ ១៩៩៣ ប្រកាសអំពីការធានា និងការពារដោយព្រះរាជាណាចក្រកម្ពុជា នូវសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីកុមារ ។

### ប្រភពអន្តរជាតិផ្សេងទៀត :

សូមមើលមាត្រា ១៩ (ការការពារកុមារប្រឆាំងនឹងអំពើហឹង្សាផ្លូវភេទ កាលបើកុមារស្ថិត ក្នុងការថែរក្សារបស់មាតាបិតា ឬអ្នកតំណាងតាមច្បាប់របស់វា) និង មាត្រា ៣៤ (ការការពារកុមារ ដោយរដ្ឋ ជាភាគីប្រឆាំងនឹងគ្រប់ទម្រង់នៃអាជីវកម្មផ្លូវភេទ និងអំពើហឹង្សាផ្លូវភេទ) នៃ អនុសញ្ញាអន្តរជាតិ ស្តីពីកុមារ ។

**មាត្រា កម ២៣១៦-៣ *ការប៉ះពាល់ខាងផ្លូវភេទរវាងញាតិលោហិត***

អំពើរួមភេទ រវាងញាតិលោហិត ក្នុងបី (៣) ថ្នាក់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពីមួយ (១) ឆ្នាំ ដល់បី (៣)ឆ្នាំ និងពិន័យជាប្រាក់ពីពីរលាន (២.០០០.០០០) រៀល ទៅប្រាំមួយលាន (៦.០០០.០០០) រៀល។

**សេចក្ដីព្រាងក្រមព្រហ្មទណ្ឌ :**

ដោយគិតគូរអំពីតម្លៃនៃសង្គមខ្មែរ ក្រមព្រហ្មទណ្ឌ ផ្ដន្ទាទោស អំពើរួមភេទរវាងញាតិលោហិត ដោយពុំគិតអំពីលក្ខខណ្ឌ អាយុ ឬភាពទន់ខ្សោយអ្វីឡើយ ។

**អត្ថបទយោង :**

**ប្រភពប្រវត្តិសាស្ត្រខ្មែរ :**

មាត្រា ៤៤៧ និង៤៤៨ នៃក្រមឆ្នាំ ១៩២៩ និង ១៩៥៥ បង្ក្រាបអំពើរួមភេទ រវាងញាតិលោហិត។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់ស្តីពី

# ការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ



ឆ្នាំ ២០០៨

ក្រសួងយុត្តិធម៌

Ministry of Justice

# ព្រះរាជាណាចក្រកម្ពុជា


មីសែល បូនីញើ

ចៅក្រម

ទីប្រឹក្សារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគំរោង « គាំទ្រនីតិរដ្ឋ »

សហប្រតិបត្តិការបារាំង


# សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី

## អត្ថាធិប្បាយ និងប្រៀបធៀប

## វិភាគទាន ចំពោះការសិក្សានីតិព្រហ្មទណ្ឌខ្មែរ


ផូវ សំភី

ហ៊ែល ចំរើន

ចាំង ស៊ីណាត

កើត រិទ្ធ

ម៉ារីយ៉ុង គូរីដាត៍

## ជំពូកទី ៦
## អំពើអាសអាភាសលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ

**មាត្រា ៤២.- អំពើរួមភេទជាមួយអនីតិជនអាយុក្រោម ១៥ ឆ្នាំ**

ជនណារួមភេទជាមួយជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ)ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

**មាត្រា ៤៣.- អំពើអាសអាភាសលើអនីតិជនអាយុក្រោម ១៥ ឆ្នាំ**

អំពើអាសអាភាសនៅក្នុងច្បាប់នេះ មានន័យថា ជាអំពើនៃការប៉ះពាល់ ឬ ការបង្ហាញកេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនដទៃ ឬ ការឱ្យជនដទៃប៉ះពាល់កេរភេទ ឬ ផ្នែកភេទផ្សេងទៀតរបស់ជនល្មើសខ្លួនឯង ឬ របស់តតិយជនក្នុងចេតនាធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស ។

ជនណាដែលប្រព្រឹត្តអំពើអាសអាភាសទៅលើជនដទៃ ដែលមានអាយុតិចជាង ១៥ (ដប់ប្រាំ) ឆ្នាំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១(មួយ)ឆ្នាំ ដល់ ៣ (បី) ឆ្នាំ និង ពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤២ ឬ មាត្រានេះ បើមិនរាងចាលទេ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារទ្វេដង ។

**មាត្រា ៤៤.- ការលើកលែងពីការផ្តន្ទាទោស**

ជនណាដែលមានអាយុក្រោម ១៥ ឆ្នាំ នឹងត្រូវលើកលែងពីការផ្តន្ទាទោស ចំពោះបទល្មើសដូចមានចែងនៅក្នុងមាត្រា ៤២ និងមាត្រា ៤៣ នៃច្បាប់នេះ ។

## ជំពូកទី ៧
## សំណងរដ្ឋប្បវេណី

**មាត្រា ៤៥.- កិច្ចសន្យាសម្រាប់អំពើលក់-ដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ**

កិច្ចសន្យាណាមួយនឹងត្រូវចាត់ទុកជាមោឃៈ ប្រសិនបើកិច្ចសន្យានោះត្រូវបានធ្វើឡើង ដោយមានគោលដៅបំពេញនូវអំពើលក់-ដូរមនុស្ស ឬ អំពើធ្វើអាជីវកម្មផ្លូវភេទ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ

# ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ

# សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល

# និង

# ច្បាប់ ស្តីពី ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ




# PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD

# and

# LAW ON THE AGGRAVATING CIRCUMSTANCES FOR FELONIES

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល

សេចក្តីសំរេចចុះថ្ងៃទី ១០ កញ្ញា ១៩៩២

**ក្រុមប្រឹក្សាជាតិជាន់ខ្ពស់** ដែលចាប់ពីពេលនេះទៅហៅថា «SNC» អេស អិន ស៊ី

- ដោយសំអាងលើអំណាចទាំងឡាយ ដែលប្រគល់ឡើងតាមមាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចុះថ្ងៃទី ២៣ តុលា ១៩៩១ ដែលចាប់ពីពេលនេះទៅហៅថា «កិច្ចព្រមព្រៀង» ទុកដូចជាអង្គការពេញច្បាប់តែមួយគត់ ហើយជាប្រភពនៃអាជ្ញាធរកម្ពុជា,
- ដោយរំលឹកឡើងវិញនូវមាត្រា៦ នៃកិច្ចព្រមព្រៀងដែលនៅក្នុងនោះ SNC បានប្រគល់ជូនដល់អង្គការសហប្រជាជាតិ នូវអំណាចទាំងអស់ដែលចាំបាច់សំរាប់អនុវត្តកិច្ចព្រមព្រៀង,
- ដោយរំលឹកបន្ថែមទៀតថា ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេចចិត្ត ៧៤៥ (១៩៩២) បានរៀបចំអាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ដែលចាប់ពីពេលនេះតទៅហៅថា «អ៊ុនតាក់» ស្របតាមមាត្រា ២ នៃកិច្ចព្រមព្រៀង ដើម្បីបំពេញតួនាទីភារកិច្ច ដែលចែងឡើងក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀង,
- ដោយយល់ថា អ៊ុនតាក់ ត្រូវបានទទួលបេសកកម្មមួយ, ស្របតាមមាត្រា ៦ និង ១៦ នៃកិច្ចព្រមព្រៀងប៉ារីស និងផ្នែក ខ និង ង នៃឧបសម្ព័ន្ធទី១, ក្នុងការត្រួតពិនិត្យផ្ទាល់ ឬ ការពិនិត្យត្រួតត្រាលើវិស័យទាំងឡាយ ស្តីអំពីការរក្សារបៀបរៀបរយ និងការគោរពច្បាប់, ការការពារសិទ្ធិមនុស្ស, ការអនុវត្តន៍ច្បាប់ និងដំណើរការក្នុងប្រព័ន្ធតុលាការ,
- ដោយយល់ឃើញថែមទៀតថា ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង បានទទួលស្គាល់ដោយជាក់លាក់, ក្នុងមាត្រា១៥, ថាមនុស្សគ្រប់រូបនៅប្រទេសកម្ពុជា និងជនភៀសខ្លួនទាំងអស់ និងជនផ្លាស់ប្តូរទីកន្លែងទាំងអស់នៅកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស

# មាតិកា បួន : ចេឧឧក្រិដ្ឋ

## មាត្រា ៣១ : ឃាដកម្មគិតទុកជាមុន

១ : ជនណាដែលសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬ ដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាដគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ២០ឆ្នាំ ។

២ : ការគិតទុកជាមុន គឺគំរោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់ គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលមួយរយៈ ដើម្បីប្រព្រឹត្តហិង្សាទៅលើបុគ្គលនោះ ។

## មាត្រា ៣២ : អំពើមនុស្សឃាតដោយចេតនា

ជនណាដែលសម្លាប់មនុស្សដោយចេតនា ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតដោយចេតនាដោយគ្មានស្ថានទម្ងន់ណាមួយដែលចែងក្នុងមាត្រា ៣១ ដោយបានប្រើ ឬមិនបានប្រើអាវុធក្តី ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវផ្តន្ទាទោសដាក់ជាបទឧក្រិដ្ឋពី ៨ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៣ : បទរំលោភសេពសន្ថវៈ

១ : ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬ ប៉ុនប៉ងរំលោភសេពសន្ថវៈលើជនម្នាក់ទៀតទោះភេទដូចគ្នា ឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទសេពសន្ថវៈ ហើយផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

២ ៖ បទរំលោភសេពសន្ថវៈ គឺគ្រប់អំពើបញ្ចូលអង្គជាតិដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។ ប្រសិនបើការរំលោភសេពសន្ថវៈបានត្រូវប្រព្រឹត្តឡើង ដោយការគំរាមកំហែងនឹងអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬ ជនមានសតិវិបល្លាស ឬ ពិការរាងកាយ ឬធ្វើឡើងដោយមានអ្នកប្រព្រឹត្តពីរនាក់ ឬច្រើននាក់ ឬដោយមានអ្នកសមគំនិត ឬបើការសេពសន្ថវៈនោះត្រូវប្រព្រឹត្តឡើង ដោយជនដែលមានអំណាចលើអ្នករងគ្រោះទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់គុកជាបទឧក្រិដ្ឋពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

## មាត្រា ៣៤ ៖ អំពើប្លន់

១ ៖ ជនណាដែលបានលួច ឬប៉ុនប៉ងនឹងលួចជនណាម្នាក់ទៀត ដោយមានស្ថានទម្ងន់ទោសទាំងនេះ ៖

- ការលួចធ្វើដោយអំពើហិង្សា, មានអាវុធ ឬឥតអាវុធ, បណ្តាល ឬមិនបណ្តាលឲ្យមានរបួស

- ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយមានគាស់ទំលុះទំលាយ, ត្រូវមានទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋពី ៣ឆ្នាំ ទៅ ១០ឆ្នាំ ។

២ ៖ អំពើលួចប្លន់គឺការបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

## មាត្រា ៣៥ ៖ ការបង្ខាំងមនុស្សដោយខុសច្បាប់

ជនណាដោយគ្មានបញ្ជាពីអាជ្ញាធរតុលាការបានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស ៖

- ដាក់គុកជាបទឧក្រិដ្ឋ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬ ការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ

- ដាក់គុកពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈតិចជាង ១ខែ